asean

# កញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំសម្រាប់ការធ្វើមូលដ្ឋានីយកម្មផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ




In partnership with Canada

Ministry of Gender Equality and Family

UK International Development
Partnership | Progress | Prosperity

UN WOMEN

# កញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំ សម្រាប់ការធ្វើមូលដ្ឋានីយកម្ម ផែនការ សកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ

**អាស៊ាន (គណៈកម្មាធិការ អាស៊ានដើម្បីស្ត្រី គណៈកម្មការ អាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ ក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ) និង ភ្នាក់ងារសហប្រជាជាតិ UN Women**

**លេខាធិការដ្ឋានអាស៊ាន**

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) បានបង្កើតឡើងនៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៦៧ ដែលរដ្ឋជាសមាជិករួមមាន ព្រុយណេដារូសាឡឹម កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម។ លេខាធិការដ្ឋានអាស៊ានមានមូលដ្ឋាននៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី។

សម្រាប់ការសាកសួរព័ត៌មាន សូមទាក់ទង ៖
លេខាធិការដ្ឋានអាស៊ាន
ផ្នែកទំនាក់ទំនងសហគមន៍ (CRD) 70A Jalan Sisingamangaraja, Jakarta 12110 Indonesia
Phone: (62 21) 724-3372, 726-2991
Fax: (62 21) 739-8234, 724-3504
E-mail: public@asean.org

បញ្ជីក្នុងការបោះពុម្ពផ្សាយទិន្នន័យ
កញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំសម្រាប់ការធ្វើមូលដ្ឋានីយកម្មផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ទីក្រុងហ្សាការតា លេខាធិការដ្ឋានអាស៊ាន ខែ ធ្នូ ឆ្នាំ ២០២៣

ISBN 978-623-5429-33-5 (PDF)
9 786235 429335

អាស៊ាន ៖ សហគមន៍ដែលនាំមកនូវឱកាសសម្រាប់ប្រជាជនទាំងអស់

អត្ថបទក្នុងឯកសារបោះពុម្ពផ្សាយនេះ អាចត្រូវបានដកស្រង់ ឬបោះពុម្ពឡើងវិញដោយសេរី ឱ្យតែមានសេចក្តីថ្លែងអំណរគុណសមស្រប និងផ្ញើច្បាប់ចម្លងឯកសារដែលបានបោះពុម្ពឡើងវិញ ទៅផ្នែកទំនាក់ទំនងសហគមន៍ (CRD) នៃលេខាធិការដ្ឋានអាស៊ាន ដែលមានទីស្នាក់ការនៅទីក្រុងហ្សាការតា។ ព័ត៌មានទូទៅស្តីពីអាស៊ាន អាចរកបានតាមគេហទំព័រអាស៊ាន ៖ www.asean.org

©២០២៣ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)
រក្សាសិទ្ធិគ្រប់យ៉ាង

ការបោះពុម្ពនេះទទួលបានការឧបត្ថម្ភគាំទ្រពី ៖

In partnership with Canada
Ministry of Gender Equality and Family
UK International Development — Partnership | Progress | Prosperity
UN WOMEN

ភ្នាក់ងារសហប្រជាជាតិ UN Women បោះពុម្ពផ្សាយឯកសារនេះក្រោមគម្រោងថ្នាក់តំបន់ស្តីពី "ការបង្កើនភាពអង់អាចដល់ស្ត្រីដើម្បី សន្តិភាពប្រកបដោយចីរភាព៖ ការទប់ស្កាត់អំពើហិង្សា និងការលើកកម្ពស់សាមគ្គីភាពសង្គមនៅអាស៊ាន" ក្រោមការគាំទ្រពីរដ្ឋាភិបាលកាណាដា សាធារណរដ្ឋកូរ៉េ និងចក្រភព អង់គ្លេស។ Sharmistha Dasbarwa និង Mirsad Jacevic ដែលជាទីប្រឹក្សាឯករាជ្យ បានព្រាងឯកសារនេះឡើង ដើម្បីសម្រួលដល់ការអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងចំណោមរដ្ឋសមាជិកអាស៊ាន។ ផែនការសកម្មភាពនេះដឹកនាំរៀបចំដោយអ្នកតំណាងគណៈកម្មាធិការស្ត្រី អាស៊ាន មកពីប្រទេសកម្ពុជា ដែលជាប្រធានក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

ឯកសារបោះពុម្ពផ្សាយនេះបង្ហាញពីកញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំដែលចេញពីការពិគ្រោះយោបល់ជាមួយអ្នកតំណាងស្ថាប័នតាមវិស័យរបស់ អាស៊ាន រួមមានគណៈកម្មាធិការអាស៊ានដើម្បីស្ត្រី គណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ និងក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលមាន ១១វិស័យក្នុងសសរស្តម្ភទាំង ៣ របស់សហគមន៍អាស៊ាន។ បន្ថែមពីនេះ មានការប្រមូលព័ត៌មានតាមរយៈការស្ទង់មតិពីអ្នកតំណាងរបស់ពីគណៈកម្មាធិការ អាស៊ានដើម្បីស្ត្រី។ ព័ត៌មានទាំងនេះជួយបំពេញបន្ថែមដល់ការពិនិត្យ និងការវិភាគលើឯកសារពាក់ព័ន្ធយ៉ាងច្រើនផ្សេងទៀត។

ទស្សនៈយល់ឃើញដែលបានលើកឡើងក្នុងឯកសារបោះពុម្ពផ្សាយនេះ ជាទស្សនៈយល់ឃើញរបស់អ្នកនិពន្ធ និងមិនតំណាងឱ្យទស្សនៈយល់ឃើញ និងគោលនយោបាយផ្លូវការរបស់ភ្នាក់ងារសហប្រជាជាតិ UN Women អង្គការសហប្រជាជាតិ ឬអង្គការដែលជាសម្ព័ន្ធរបស់អង្គការសហប្រជាជាតិ ឬទស្សនៈយល់ឃើញរបស់រដ្ឋាភិបាលកាណាដា សាធារណរដ្ឋកូរ៉េ ឬចក្រភពអង់គ្លេសឡើយ។ ការរចនា និងការបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនបង្ហាញពី ទស្សនៈយល់ឃើញរបស់ភ្នាក់ងារសហប្រជាជាតិ UN Women ដែលពាក់ព័ន្ធនឹងភាពស្របច្បាប់របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ណាមួយ ឬអាជ្ញាធររបស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ណាមួយ ឬពាក់ព័ន្ធនឹងការកំណត់ព្រំដែន ឬព្រំប្រទល់របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ណាមួយឡើយ។

# មាតិកា


បុព្វកថា 2

សេចក្តីសង្ខេប 8

អំពីកញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំ 9

សេចក្តីផ្តើម 9

និយមន័យនៃការធ្វើមូលដ្ឋានីយកម្ម 10

គោលបំណង និងរចនាសម្ព័ន្ធនៃកញ្ចប់ឧបករណ៍នេះ 10

ទិដ្ឋភាពរួមនៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ 11

ក្របខណ្ឌសកល 11

ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ 13

ជម្រើសផ្សេងៗក្នុងការបង្កើតផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ 14

គម្រូផែនការសកម្មភាពជាតិ 16

ជំហានទី ១ ៖ ការរៀបចំផែនការសកម្មភាព 17

១.បង្កើតរចនាសម្ព័ន្ធសម្រាប់ត្រួតពិនិត្យការសម្របសម្រួល សេចក្តីពង្រាង និងការអនុវត្ត 17

២.កសាង និងបញ្ជ្រាបការយល់ដឹងដល់ភាគីពាក់ព័ន្ធសំខាន់ៗស្តីពីការទទួលខុសត្រូវ និងភាពម្ចាស់ការ 17

៣.កំណត់តួនាទី និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធសំខាន់ៗ 18

៤.វិភាគស្ថានភាព 20

៥.គូសផែនទីភាគីពាក់ព័ន្ធ 21

៦.បង្កើតវេទិកាពិគ្រោះយោបល់ប្រកបដោយបរិយាបន្នសម្រាប់ភាគីពាក់ព័ន្ធដែលមានសាវតារចម្រុះ ដើម្បីចែករំលែកព័ត៌មានជាប្រចាំ និងធានាតម្លាភាព 22

៧.សម្របសម្រួលការចូលរួមប្រកបដោយអត្ថន័យរបស់សង្គមស៊ីវិល នៅក្នុងការបង្កើត និងអនុវត្តផែនការសកម្មភាពជាតិ 26

៨.កំណត់ចំណុចសំខាន់ៗ សម្រាប់ការបន្សីគោលនយោបាយ និងក្របខណ្ឌកម្រិតសកល និងក្របខណ្ឌកម្រិតតំបន់ ដែលមានស្រាប់ ទៅនឹងផែនការសកម្មភាពជាតិ 28

៩.ជ្រើសរើសសកម្មភាពអាទិភាព ដោយផ្អែកតាមសមាសភាគសំខាន់ៗនៃផែនការសកម្មភាព ជាតិដែលផ្តល់ផលជះកម្រិតខ្ពស់ 29

១០.ធានាតម្លាភាព និងគណនេយ្យភាព 32

២.ជំហានទី ២ ៖ ការធ្វើសេចក្តីពង្រាងផែនការសកម្មភាពជាតិ 33

១.បង្កើតគណៈកម្មាធិការ ឬក្រុមការងារ ដើម្បីចាប់ផ្តើមព្រាងផែនការសកម្មភាពជាតិ 33

២.ព្រាងផែនការជាតិដែលបន្សីគ្នានឹងផែនការសកម្មភាពតំបន់អាស៊ាន 36

៣.រៀបចំផែនការពិនិត្យតាមដាន និងវាយតម្លៃ

៤.បង្កើតយន្តការសម្រាប់ការពិនិត្យតាមដាន និងការធ្វើរបាយការណ៍ 44

៥.ទទួលស្គាល់គុណតម្លៃនៃការពិនិត្យតាមដានលើយោបល់ត្រឡប់ នៅក្នុងដំណើរការ គោលនយោបាយ 47

៦.ផ្តល់ធនធានដល់ផែនការពិនិត្យតាមដាន និងវាយតម្លៃ 48

៧.បញ្ហាប្រឈមដែលបន្តលេចឡើង និងដំណោះស្រាយដែលមានប្រសិទ្ធភាព នៅក្នុងការពិនិត្យ តាមដាន និងការរៀបចំ\ របាយការណ៍ 48

៨.បន្សីក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃដែលមានស្រាប់ ឱ្យស្របទៅនឹង គោលការណ៍ថ្នាក់តំបន់ 50

៩.គណនាចំណាយ និងរៀបចំថវិកាសម្រាប់ផែនការសកម្មភាពជាតិ 51

១០.កំណត់រកប្រភពហិរញ្ញប្បទានថ្មីៗ 52

ជំហានទី ៣ ៖ ការអនុវត្តផែនការសកម្មភាពជាតិ 54

១.ផ្តល់សុពលភាពដល់សេចក្តីព្រាងផែនការសកម្មភាពជាតិ អនុម័ត និងប្រកាសឱ្យប្រើប្រាស់ ជាផ្លូវការ 54

២.កសាងការយល់ដឹងស្តីពីផែនការសកម្មភាពជាតិ រក្សាការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល និងបង្កើនសមត្ថភាពរបស់ភាគីពាក់ព័ន្ធសំខាន់ៗ 56

៣.ចងក្រងការអនុវត្តល្អ និងមេរៀន 57

សទ្ទានុក្រម 59

ឯកសារយោង 62

# បុព្វកថា

សេចក្តីសម្រេចលេខ ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនឹងឈានចូលគម្រប់ខួបលើកទី ២៥ ឆ្នាំ យើងសង្កេតឃើញមានការគំរាមកំហែងកាន់តែច្រើនឡើងលើសន្តិសុខមនុស្សជាតិ។ ដូច្នេះ នេះជាពេលវេលាដ៏សមស្របក្នុងការប្រារព្ធពិធី ក៏ដូចជារៀបចំយុទ្ធសាស្ត្រល្អបំផុតសម្រាប់ពង្រឹងតួនាទីដ៏សំខាន់របស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាអ្នកឆ្លើយតបចម្បងទៅនឹងបញ្ហាប្រឈមនានា។ ទោះបីជាពួកគេមានតួនាទីយ៉ាងសំខាន់នៅក្នុងបរិបទសន្តិភាព និងសន្តិសុខ ប៉ុន្តែការចូលរួមរបស់ពួកនៅមិនទាន់មានការ ការទទួលស្គាល់ពេញលេញនោះទេ។

យើងត្រូវតែទទួលស្គាល់ថា រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងអង្គការសង្គមស៊ីវិល និងស្ថាប័នផ្សេងទៀត កំពុងដើរតួនាទីកាន់តែសំខាន់ក្នុងការទប់ស្កាត់ និងឆ្លើយតបនឹងការគំរាមកំហែងសន្តិសុខមនុស្សជាតិនាពេលបច្ចុប្បន្ន។ ហេតុនេះ ការធ្វើមូលដ្ឋានីយកម្មរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (WPS) ជាការទទួលស្គាល់ការដឹកនាំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជាសមត្ថភាពរបស់អង្គការសង្គមស៊ីវិល ក្នុងការបំពេញតម្រូវការកាន់តែប្រសើរដល់ប្រជាជនដែលរងផលប៉ះពាល់ និងការបង្កើតយន្តការសមស្របដើម្បីដោះស្រាយបញ្ហាសន្តិសុខនាពេលអនាគត។

ចាប់តាំងពីការប្រកាសឱ្យប្រើប្រាស់ជាផ្លូវការសេចក្តីសម្រេចលេខ ១៣២៥ (UNSCR 1325) ក្នុងឆ្នាំ ២០០០មក ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានអំពាវនាវជាច្រើនលើកច្រើនសារឱ្យរដ្ឋសមាជិករៀបចំផែនការសកម្មភាពជាតិ ដើម្បីពន្លឿនរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងបង្កើតសកម្មភាពចំគោលដៅ ដែលផ្តោតលើប្រទេស ទីតាំង បរិបទ និងយុទ្ធសាស្ត្រឆ្លើយតបជាក់លាក់។ ការធ្វើមូលដ្ឋានីយកម្មរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ គឺជាអនុសាសន៍មួយក្នុងចំណោមអនុសាសន៍ ៤សំខាន់ផ្សេងទៀត ពីការសិក្សាក្នុងតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ មានការបង្ហាញពីភាពចាំបាច់ក្នុងការជម្រុញឱ្យមាន ការធ្វើមូលដ្ឋានីយកម្មរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខក្នុងចំណោមរដ្ឋសមាជិកអាស៊ាន សម្រាប់ "ការបង្កើននិម្មាបនកម្មសន្តិភាព និងសន្តិសុខរបស់តំបន់អាស៊ាន" និងបន្តដាក់បញ្ចូល ទៅក្នុងសកម្មភាពអាទិភាពមួយនៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ជាពិសេសដើម្បីសម្រេចបានការចូលរួមរបស់ស្ត្រីប្រកបដោយអត្ថន័យ នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចស្តីពីសន្តិសុខ និងសន្តិភាព។

ផ្អែកតាមការលើកឡើងខាងលើ ការរៀបចំកញ្ចប់ឧបករណ៍ការធ្វើមូលដ្ឋានីយកម្ម នឹងផ្តល់ធនធានដ៏មានតម្លៃដល់រដ្ឋសមាជិកអាស៊ានក្នុងការជ្រើសរើស និងកំណត់អាទិភាពលើជម្រើសដែលមានស្រាប់ ដើម្បីដោះស្រាយបញ្ហាសន្តិសុខស្របតាមគោលដៅអភិវឌ្ឍន៍ជាតិ។ ក្រៅពីនេះ វាបានផ្តល់ឱកាសទាន់ពេលវេលាក្នុងការរៀបចំផែនទីតម្រង់ទិសសម្រាប់ការអនុវត្តសកម្មភាពប្រកបដោយបរិវត្តកម្ម ស្របតាមសកម្មភាពសំខាន់ៗនៅក្នុងផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ កញ្ចប់ឧបករណ៍នេះនឹងក្លាយជាធនធានដ៏មានតម្លៃសម្រាប់រដ្ឋាភិបាល ក៏ដូចជាសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀតដែលមានសាវតារចម្រុះ ព្រោះសកម្មភាពដែលបានកំណត់ ផ្អែកលើកិច្ចខិតខំប្រឹងប្រែងរួមគ្នា រវាង ភាគីពាក់ព័ន្ធដែលមានសាវតារចម្រុះ តាមរយៈដំណើរការដែលមានការចូលរួម និងបរិយាបន្ន។

កញ្ចប់ឧបករណ៍នេះលើកកម្ពស់ចក្ខុវិស័យរួមរបស់ ភាគីពាក់ព័ន្ធសំខាន់ៗ ក្នុងការរៀបចំផែនការសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ឯកសារនេះផ្តល់ព័ត៌មាន និងសេចក្តីណែនាំជាក់ ស្តែងសម្រាប់ការដាក់សកម្មភាពអាទិភាពក្នុងផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ទៅជាសកម្មភាពអនុវត្តន៍ ជាមួយនឹងលទ្ធផលជាក់ស្តែង និងការមិនទុកនរណាម្នាក់ចោល។

ដំណើរការនៃការធ្វើមូលដ្ឋានីយកម្មផែនការទាំងនេះ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គឺជាការសាកល្បងសម្រាប់ភាគីពាក់ព័ន្ធសំខាន់ៗ ជាពិសេសរដ្ឋាភិបាលតែម្តង។ ការរៀបចំផែនការ និងថវិកាសម្រាប់កម្មវិធី/គម្រោងស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ចេញពីទស្សនៈយេនឌ័រ រួមជាមួយការតាមដានផលប៉ះជះ គឺជាការបោះជំហានដ៏សំខាន់មួយ។ ទន្ទឹមនឹងនេះប្រសិនបើមានការអនុវត្តប្រកបដោយប្រសិទ្ធភាព វានឹងធានាឱ្យមានការបន្សុំ រវាងផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ជាមួយនិងអាទិភាពជាតិ ដើម្បីរក្សាសន្តិភាព និងសន្តិសុខនៅគ្រប់កម្រិត។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈកម្មាធិការអាស៊ានដើម្បីស្ត្រី (ACW) សម្រាប់ការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការពន្លឿនរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងភ្នាក់ងារសហប្រជាជាតិ UN Women ដែលបន្តធ្វើជាដៃគូសហការជាយូរមកហើយ។

ខ្ញុំសូមលើកទឹកចិត្តឱ្យមានការប្រើប្រាស់កញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំនេះប្រកបដោយប្រសិទ្ធភាព ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយជាតិស្តីពីសន្តិភាព និងសន្តិសុខ និងផែនការសកម្មភាពអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ព្រោះនេះជាការទទួលខុសត្រូវរួមរបស់យើងក្នុងការបង្កបរិយាកាសអំណោយផល និងមានសុវត្ថិភាព ដែលពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ស្ត្រីឆ្ពោះទៅរកអនាគតដែលប្រកបដោយសន្តិភាព។

លោកជំទាវ អ៊ឹង កន្ថាផាវី



រដ្ឋមន្ត្រីក្រសួងកិច្ចការនារីនៃព្រះរាជាណាចក្រកម្ពុជា

# សេចក្តីសង្ខេប

តំបន់អាស៊ីអាគ្នេយ៍មានប្រវត្តិជាយូរមកហើយលើការអនុវត្តអភិក្រមបែបនវានុវត្តន៍នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់សន្តិភាព និងសន្តិសុខ ដែល ជាញឹកញាប់ដឹកនាំដោយស្ត្រី ។ ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ បានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការក្នុងឆ្នាំ ២០២២ ដោយផ្អែកលើការ បញ្ចូលគ្នានូវការងារពីមុន និងការងារដែលកំពុងបន្តធ្វើនៅក្នុងអាស៊ាន លើបញ្ហាពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ និងបញ្ជាក់ពីភាពចាំបាច់ក្នុងការ "បង្កើតគោលការណ៍ណែនាំដើម្បីជាជំនួយដល់អាជ្ញាធរមូលដ្ឋាន និងដៃគូអនុវត្តន៍នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ...ក្នុងការអនុវត្ត (និងពិនិត្យតាមដាន និងវាយតម្លៃផែនការនេះ)"។ ចំណុចនេះទាមទារឱ្យមានការពង្រឹងតួនាទីរបស់រដ្ឋាភិបាលក្នុងការធានាថា ប្រជាជនដែលរងផលប៉ះពាល់ និងងាយរងគ្រោះបំផុត ជាពិសេសស្ត្រី ទទួលបានព័ត៌មាន និងកំណត់ការទប់ស្កាត់ជម្លោះ និងសន្តិភាពប្រកបដោយចីរភាព។ ក្រៅពីនេះ ការវិវត្តនៃទស្សនទានសន្តិសុខដែលមានគោលដៅជំរុញឱ្យរដ្ឋសមាជិកប្រកាន់ខ្ជាប់សន្តិសុខមនុស្សជាតិជាចម្បង អំពាវនាវឱ្យមានការបង្កើតក្របខណ្ឌអន្តរវិស័យមួយ ដែលផ្តោតការយកចិត្តទុកដាក់លើមនុស្ស។

មានតែអភិក្រមនេះទេទើបអាចដោះស្រាយបញ្ហាប្រឈមផ្សេងៗ មានដូចជា អំពើហិង្សាជ្រុលនិយម ការ បណ្តេញចេញដោយបង្ខំ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ អំពើជួញដូរមនុស្ស និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្នុងចំណោមការគំរាមគំហែងសន្តិសុខថ្មីៗផ្សេងទៀត[1]។ ការគំរាមកំហែងទាំងនេះនៅតែបង្កបញ្ហាប្រឈមដល់រដ្ឋសមាជិកអាស៊ានក្នុងការលើកកម្ពស់សមភាពយេនឌ័រ ការបង្កើនភាពអង់អាចដល់ស្ត្រី និងបរិយាបន្ន ក្នុង បរិបទនៃសន្តិភាព និងសន្តិសុខក្នុងតំបន់ចម្រុះមួយ[2]។

កញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំសម្រាប់ធ្វើមូលដ្ឋានីយកម្មនេះនឹងផ្តល់ការណែនាំផ្នែកបច្ចេកទេសស្តីពី "របៀប" សម្របសម្រួលការអនុវត្តផែនការសកម្មភាពតំបន់អាស៊ាន តាមរយៈការកែសម្រួលប្រការដែលបានចែងសំខាន់ៗក្នុងផែនការនេះទៅតាមបរិបទជាតិនីមួយៗ។ ផ្នែកទី ១ ពន្យល់ពីកញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំ និងនិយមន័យនៃការធ្វើមូលដ្ឋានីយកម្ម។ ផ្នែកទី ២ ផ្តល់ទិដ្ឋភាពរួមស្តីពីគោលនយោបាយ និងក្របខណ្ឌសកល និងតំបន់ ដែលពាក់ព័ន្ធនឹងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

ផ្នែកទី ៣ បង្ហាញពីអភិក្រមផ្សេងៗសម្រាប់ការអនុវត្តផែនការសកម្មភាពតំបន់អាស៊ាន។ រដ្ឋសមាជិកអាស៊ានអាចជ្រើសរើសអភិក្រមផ្សេងៗពីគ្នាយកទៅអនុវត្តទៅតាមបរិបទរបស់ខ្លួន។ រដ្ឋសមាជិកខ្លះអាចដាក់បញ្ចូលបញ្ហាស្តីពីស្ត្រី សន្តិភាព និងសន្តិសុខទៅក្នុងច្បាប់ គោលនយោបាយ និងផែនការដែលមានស្រាប់ ដូចជា ផែនការអភិវឌ្ឍន៍ជាតិ ដើម្បីធានាចីរភាពយូរអង្វែង។ រដ្ឋសមាជិកផ្សេងទៀតអាចបង្កើតផែនការសកម្មភាពជាតិដាច់ដោយឡែកស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ កញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំនេះបង្ហាញពីគុណសម្បត្តិ និងគុណវិបត្តិនៃអភិក្រមទាំង ២ ខាងលើ និងរៀបរាប់ពីជំហានសំខាន់ៗសម្រាប់ការរៀបចំកសាងផែនការសកម្មភាពជាតិ ដូចជា ដំណាក់កាលរៀបចំផែនការ ដំណាក់កាលធ្វើសេចក្តីព្រាង និងដំណាក់កាលអនុវត្ត។ ជំហានសំខាន់ៗរួមមានការកសាងការយល់ដឹង និងការបញ្ជ្រាបការយល់ដឹងដល់ភាគីពាក់ព័ន្ធសំខាន់ៗ ការវិភាគស្ថានភាព និងការគូសផែនទីបង្ហាញពីភាគីពាក់ព័ន្ធ ការបន្សុីផែនការសកម្មភាពជាតិទៅនឹងគោលនយោបាយជាតិ ផែនការសកម្មភាពតំបន់ អាស៊ាន និងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ តាមរយៈការជ្រើសរើសសកម្មភាពអាទិភាព និងវិធានការដែលធានាតម្លាភាព និងគណនេយ្យភាពឱ្យបានខ្ពស់។ ជំហានទាំងនេះមានអមជាមួយនឹងការព្រាងផែនការសកម្មភាពជាតិ ដែលគ្របដណ្តប់លើការពិនិត្យតាមដាន និងវាយតម្លៃ ក៏ដូចជាការគណនាចំណាយ និងការរៀបចំថវិកា។ បន្ទាប់មក ផែនការនេះត្រូវបានផ្តល់សុពលភាព អនុម័ត និងប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ និងចាប់ផ្តើមសកម្មភាពអនុវត្ត។ ការចងក្រងការអនុវត្តល្អ និងមេរៀន នឹងបង្កើនការរៀនសូត្រ និងផ្តល់មូលដ្ឋានព័ត៌មានដល់ការអនុវត្តនាពេលអនាគត។

កញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំនេះមានភាពងាយស្រួលសម្រាប់អ្នកប្រើប្រាស់ ដោយសារមាន ការគាំទ្រជាជំហានសម្រាប់រដ្ឋសមាជិកអាស៊ាន និងភាគីពាក់ព័ន្ធផ្សេងៗ ដូចជា អាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល និងតួអង្គផ្សេងទៀត ដើម្បីធានាភាពម្ចាស់ការពេញលេញលើផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងបង្កើតជាកិច្ចសហការឆ្លងវិស័យសម្រាប់ទ្រទ្រង់ការអនុវត្តប្រកបដោយប្រសិទ្ធភាព។

# អំពីកញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំ

## សេចក្តីផ្តើម

ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ របៀបវារៈជាប្រវត្តិសាស្ត្រស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ តាមរយៈការអនុម័តសេចក្តីសម្រេចលេខ ១៣២៥ នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០០។ ការអនុម័តនេះបានបញ្ជាក់ឡើងវិញពីតួនាទីសំខាន់របស់ស្ត្រីក្នុងការទប់ស្កាត់ និងដោះស្រាយវិវាទ និងការកសាងសន្តិភាព ក៏ដូចជាគូសបញ្ជាក់ពីការចូលរួមដោយស្មើភាពរបស់ស្ត្រីនៅក្នុងកិច្ចខិតខំប្រឹងប្រែងទាំងអស់ ដើម្បីរក្សា និងលើកកម្ពស់សន្តិភាព និងសន្តិសុខ។ បន្ទាប់មក ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានអនុម័តសេចក្តីសម្រេចចំនួន ៩ បន្ថែមទៀតស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ[3]។ សេចក្តីសម្រេចទាំងនេះផ្តល់សេចក្តីណែនាំកាន់តែលម្អិតអំពីទិដ្ឋភាពជាក់លាក់នៃសង្គ្រាម និងផលប៉ះពាល់ពីសង្គ្រាមលើស្ត្រី ទន្ទឹមនឹងការដោះស្រាយបញ្ហានានា ដូចជា អំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ការជួញដូរមនុស្ស និងទិដ្ឋភាពដែលពាក់ព័ន្ធនឹងយេនឌ័រនៅក្នុងការរក្សាសន្តិភាព។ ក្នុងប្រការ ២៥ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ រដ្ឋសមាជិកអង្គការសហប្រជាជាតិទាំងអស់ "យល់ព្រមអនុវត្ត និងទទួលយកសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ អនុលោមតាមធម្មនុញ្ញបច្ចុប្បន្ន"។ ដូច្នេះ រដ្ឋសមាជិកត្រូវអនុវត្តតាមសេចក្តីសម្រេចនេះជាចាំបាច់។

បរិបទសន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ានមានការប្រែប្រួលយ៉ាងឆាប់រហ័ស និងមានភាពប្រសព្វគ្នាជាមួយការរើសអើងយេនឌ័រជាប្រព័ន្ធ និងវិសមភាព ដែលបង្កផលប៉ះពាល់លើសិទ្ធិស្ត្រី និងការបង្កើនភាពអង់អាចដល់ស្ត្រី[4]។ ថ្មីៗនេះ កង្វះនៃការដាក់បញ្ចូលទស្សនៈយេនឌ័រទៅក្នុងការឆ្លើយតបបញ្ហាសន្តិសុខ និងវិបត្តិកូវីដ-១៩ បានធ្វើឱ្យមានវិសមភាពយេនឌ័រកាន់តែខ្លាំង[5]។ ការព្រួយបារម្ភថ្មីៗ និងបន្តលេចឡើង ទាមទារឱ្យមានយុទ្ធសាស្ត្រថ្នាក់ជាតិ និងផ្អែកតាមទីតាំង ក្នុងការឆ្លើយតបនឹងបញ្ហាប្រឈមដែលមិនធ្លាប់មានពីមុន និងនាំទៅរកសន្តិភាពយូរអង្វែង[6]។

ប្រទេសនីមួយៗត្រូវរិះរកវិធីអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលសមស្រប និងពាក់ព័ន្ធបំផុតទៅនឹងបរិបទរបស់ខ្លួន។ ប្រទេសភាគច្រើនព្យាយាមដាក់បញ្ចូលបញ្ហាទាំងនេះទៅក្នុងច្បាប់ គោលនយោបាយ និងផែនការដែលមានស្រាប់ស្តីពីសន្តិភាព និងសន្តិសុខ ដូចជា ផែនការអភិវឌ្ឍន៍ជាតិ ដើម្បីជំរុញការអនុវត្តគ្រប់ជ្រុងជ្រោយក្នុងរយៈពេលវែង[7]។

កញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំនេះ ផ្តល់ការណែនាំផ្នែកបច្ចេកទេសដល់តួអង្គថ្នាក់ជាតិដែលមានតួនាទីអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ តួអង្គទាំងនេះគាំទ្រដល់កិច្ចខិតខំបង្កើនការចូលរួមរបស់ស្ត្រី នៅក្នុងការដោះស្រាយការគំរាមកំហែងផ្នែកសន្តិសុខដែលកំពុងលេចឡើង និងដាក់បញ្ចូលទស្សនៈយេនឌ័រទៅក្នុងផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដោយបន្សុីខ្លាំងទៅនឹងក្របខណ្ឌតំបន់ និងក្របខណ្ឌសកល។ ផែនការសកម្មភាពជាតិនេះជាឱកាសពិសេសមួយក្នុងការបង្កើនការចូលរួម និងបរិវត្តកម្ម ដើម្បីឱ្យស្ត្រី និងក្មេងស្រីដើរតួនាទីសមស្របក្នុងនាមជាតួអង្គដឹកនាំលើបញ្ហាសន្តិភាព និងសន្តិសុខ នៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ[8]។

កញ្ចប់ឧបករណ៍នេះបង្ហាញពីរបៀបអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅថ្នាក់ជាតិ និងផ្តល់ឱកាសសម្រាប់ឱ្យស្ត្រី និងក្រុមងាយរងគ្រោះចូលរួមយ៉ាងសកម្ម និងដឹកនាំដំណើរការនានា ដោយផ្អែកលើការយល់ដឹងស៊ីជម្រៅអំពីបញ្ហាប្រឈម និងឱកាសនៅក្នុងមូលដ្ឋាន។

កញ្ចប់ឧបករណ៍នេះ ក៏ជួយដល់រដ្ឋសមាជិកអាស៊ានក្នុងការអនុវត្តក្របខណ្ឌគោលនយោបាយកម្រិតតំបន់ និងកម្រិតសកល ដោយជោគជ័យផងដែរ (ឧ. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)។ តាមការអះអាង ធាតុផ្សំសំខាន់ៗនៃសេចក្តីសម្រេចទាំងនេះ អាចដាក់បញ្ចូលទៅក្នុងផែនការរបស់ក្រសួងទទួលបន្ទុកអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ការពារជាតិ ការបរទេស យេនឌ័រ មហាផ្ទៃ និងយុត្តិធម៌។ល។ ការបង្កើតផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ គឺជាវិធីអនុវត្តន៍មួយក្នុងចំណោមវិធីអនុវត្តន៍ជាច្រើនផ្សេងទៀត ដែលអាចជំរុញឱ្យមានការវិភាជថវិកាសម្រាប់ ពន្លឿនគោលនយោបាយ ផែនការ និងកម្មវិធីនានា[9]។

## និយមន័យនៃការធ្វើមូលដ្ឋានីយកម្ម

ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ គ្របដណ្តប់លើសកម្មភាពអាទិភាពគ្រប់ជ្រុងជ្រោយ ឱកាស និងបញ្ហាប្រឈមដែលផ្សារភ្ជាប់នឹងបរិបទជាតិ។ ការអនុវត្តសកម្មភាពអាទិភាពប្រកបដោយប្រសិទ្ធភាព ទាមទារឱ្យមានការអន្តរាគមន៍ដែលឆ្លើយតបនឹងអាទិភាពរបស់ប្រជាជន និងគាំទ្រការដឹកនាំថ្នាក់ជាតិ[10]។

កញ្ចប់ឧបករណ៍នេះគាំទ្រដល់ការធ្វើមូលដ្ឋានីយកម្ម និងការអនុវត្តផែនការសកម្មភាពតំបន់អាស៊ាន នៅក្នុង បរិបទចម្រុះរបស់រដ្ឋសមាជិកអាស៊ាន និងកំណត់ពីគោលដៅជារួមនៃការធ្វើមូលដ្ឋានីយកម្ម នៅក្នុងបរិបទនៃបញ្ហាសន្តិភាព និងសន្តិសុខ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តសេចក្តីសម្រេចទាំង ១០ របស់ក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិដែលបង្កើតបានជារបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ នៅកម្រិតមូលដ្ឋាន ជាតិ តំបន់ និងសកល ជាពិសេសតាមរយៈការពង្រឹងតួនាទីស្នូលរបស់អាស៊ាន និងភាពម្ចាស់ការរបស់អាស៊ានលើការធ្វើ មូលដ្ឋានីយកម្មផែនការសកម្មភាពតំបន់អាស៊ាន។ គោលបំណងជាក់លាក់គឺការកសាងចំណេះដឹង និងការយល់ដឹងអំពីសេចក្តីសម្រេចទាំងនោះ ក្នុងចំណោមអាជ្ញាធររដ្ឋាភិបាល អ្នកដឹកនាំបែបប្រពៃណី អ្នកដឹកនាំរបស់ស្ត្រី អ្នកដឹកនាំជាយុវជន សមាជិកសហគមន៍ និងអ្នកពាក់ព័ន្ធ និងការជួយដល់ការកំណត់ និងឆ្លើយតបទៅនឹងអាទិភាពជាតិ។

ការធ្វើមូលដ្ឋានីយកម្ម សំដៅលើការលើកកម្ពស់ការដឹកនាំ ភាពម្ចាស់ការ និងការប្តេជ្ញាចិត្តថ្នាក់ជាតិចំពោះការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងចំណោមតួអង្គថ្នាក់ជាតិសំខាន់ៗ។ ការធ្វើមូលដ្ឋានីយកម្មបង្កើនសមត្ថភាពរបស់សង្គមស៊ីវិលក្នុងការរក្សាការទទួលខុសត្រូវរបស់អ្នកដឹកនាំថ្នាក់ជាតិ និងអាជ្ញាធររដ្ឋាភិបាល អង្គការកម្រិតតំបន់ អង្គការសហប្រជាជាតិ ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ចំពោះកាតព្វកិច្ចរបស់ខ្លួន ក្រោមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ និងក្របខណ្ឌតំបន់ (ក្នុងករណីនេះ គឺផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ)។ លិខិតុបករណ៍គតិយុត្ត និងគោលនយោបាយដែលពង្រឹងការអនុវត្តនៅថ្នាក់ជាតិជាធាតុផ្សំដ៏សំខាន់ ព្រមទាំងការសម្របសម្រួលជាប្រព័ន្ធ និងកិច្ចសហប្រតិបត្តិការឆ្លងវិស័យក្នុងចំណោមភាគីពាក់ព័ន្ធ[11]។

## គោលបំណង និងរចនាសម្ព័ន្ធនៃកញ្ចប់ឧបករណ៍នេះ

កញ្ចប់ឧបករណ៍នេះបង្ហាញពីវិធីផ្សារភ្ជាប់អាទិភាពជាតិ ទៅនឹងសកម្មភាពអាទិភាពរបស់ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ គោលបំណងចម្បងគឺការពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ភាគីសំ ខាន់ៗនៅថ្នាក់ជាតិនៅក្នុងរដ្ឋសមាជិកអាស៊ាន ក្នុងការជ្រើសរើស ផ្សារភ្ជាប់ និងអនុវត្តវិធានការដែលស្របនឹងអា ទិភាពជាតិ[12]និងឆ្លើយតបនឹងការគំរាមកំហែងជាបន្តបន្ទាប់ដល់សន្តិសុខមនុស្សជាតិ។

គោលបំណងទីពីរនៃកញ្ចប់ឧបករណ៍នេះ គឺការផ្តល់ផែនទីបង្ហាញផ្លូវជាក់ស្តែងមួយសម្រាប់កំណត់ដំណើរការសំខាន់ៗ និងផ្តល់ការណែនាំជាជំហានៗសម្រាប់ការប្រែក្លាយសកម្មភាពអាទិភាពដែលបានជ្រើសរើសទៅជាគំនិតផ្តួចផ្តើមថ្នាក់ជាតិដែលផ្អែកតាមតម្រូវការ។ ដំណើរការដែលបានកំណត់ គួរបំពេញបន្ថែមដោយការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព ផែនការកៀរគរធនធាន និងក្របខណ្ឌ ពិនិត្យតាមដាន និងវាយតម្លៃដ៏រឹងមាំ ដើម្បីធានាតម្លាភាព និងគណនេយ្យភាព[13]។

កញ្ចប់ឧបករណ៍នេះ រួមមាន ៖

- ការណែនាំពីការកំណត់និយមន័យនៃការធ្វើមូលដ្ឋានីយកម្ម និងគោលបំណងដែលសមស្របសម្រាប់កញ្ចប់ឧបករណ៍នេះដោយរបស់គណៈកម្មាធិការស្ត្រីអាស៊ាន និងបរិបទអាស៊ាន។
- ទិដ្ឋភាពរួមនៃក្របខណ្ឌគតិយុទ្ធ និងគោលនយោបាយ កម្រិតសកល និងកម្រិតតំបន់ លើរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។
- ការបរិយាយពីជំហានសំខាន់ៗសម្រាប់ការរៀបចំកសាងផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលគ្របដណ្តប់លើគម្រូ សមិទ្ធផល និងមេរៀនផ្សេងៗ និងមូលដ្ឋានគ្រឹះនៃការធ្វើផែនការ សេចក្តីពង្រាង និងការអនុវត្តផែនការក៏ដូចជាការពិនិត្យតាមដាន និងវាយតម្លៃ។

# ទិដ្ឋភាពរួមនៃរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ

## ក្របខណ្ឌសកល

បន្ទាប់ពីការរៀបចំសន្និសីទពិភពលោកលើកទី ៤ ស្ដីពីស្ត្រី នៅទីក្រុងប៉េកាំង ក្នុងឆ្នាំ ១៩៩៥ ៥ ឆ្នាំក្រោយមក ក្រុមប្រឹក្សាសហប្រជាជាតិបានអនុម័តសេចក្ដីសម្រេចលេខ ១៣២៥។ នេះជាលើកទីមួយហើយដែលក្រុមប្រឹក្សាសន្តិសុខអំពាវនាវឱ្យរដ្ឋសមាជិកអង្គការសហប្រជាជាតិ បញ្ជ្រាបយេនឌ័រទៅក្នុងស្ថាប័ន និងសកម្មភាពទាំងអស់ដែលពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ ដើម្បីធានាថា រដ្ឋសមាជិកឆ្លើយតបនឹងតម្រូវការផ្សេងៗរបស់ស្ត្រី និងបុរស និងពិចារណាពីផលប៉ះពាល់ផ្អែកតាមយេនឌ័រពីការអន្តរាគមន៍នានា។ សេចក្ដីសម្រេចលេខ ១៣២៥ ក៏អំពាវនាវឱ្យគ្រប់ភាគីនៃជម្លោះប្រដាប់អាវុធ ចាត់វិធានការពិសេសដើម្បីការពារស្ត្រី និងក្មេងស្រីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងការរំលោភបំពានផ្លូវភេ[14]ទផងដែរ។

សេចក្ដីសម្រេចលេខ ១៣២៥ និងសេចក្ដីសម្រេចពាក់ព័ន្ធចំនួន ៩ ដែលត្រូវបានអនុម័ត ក្នុងរយៈពេល ២ ទសវត្សរ៍កន្លងក្រោយមក បង្កើតបានជារបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ (សូមមើលតារាងទី ១ សម្រាប់ប្រការចែងសំខាន់ៗ)។ កាតព្វកិច្ចក្នុងរបៀបវារៈនេះគ្របដណ្ដប់ចាប់ពីកម្រិតជាតិ រហូតដល់កម្រិតអន្តរជាតិ។ កាតព្វកិច្ចទាំងនេះមានវិធានការជាក់លាក់ក្នុងការទទួលស្គាល់ និងការពារសិទ្ធិរបស់ស្ត្រី និងក្មេងស្រីគ្រប់រូប និងធានាបរិយាបន្ននៅក្នុងស្ថាប័ន និងប្រតិបត្តិការដែលពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ ដូចជា កំឡុងពេលសង្គ្រោះ និងស្ដារឡើងវិញ។ សេចក្ដីសម្រេចនេះអំពាវនាវឱ្យគ្រប់ភាគីទាំងអស់បំពេញតម្រូវការរបស់ស្ត្រី ក្នុងការទទួលបានសេវាសុខភាព និងសេវាផ្សេងទៀត ដូចជា ឱកាសសេដ្ឋកិច្ច ការចូលរួមក្នុងមុខតំណែងដឹកនាំ និងបញ្ហាជាច្រើនដែលពាក់ព័ន្ធនឹងការអនុវត្តរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ។

បន្ថែមលើសេចក្ដីសម្រេចសំខាន់ៗទាំង ១០ ស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ ក៏មានសេចក្ដីសម្រេចផ្សេងទៀតរបស់ក្រុមប្រឹក្សាសន្តិសុខដែលលើកឡើងពីបញ្ហាពាក់ព័ន្ធ មានដូចជា សេចក្ដីសម្រេចលេខ ២៥៣៨ ស្ដីពីយេនឌ័រ និងការរក្សាសន្តិភាព ដែលត្រូវបានដាក់ស្នើដោយប្រទេសឥណ្ឌូនេស៊ី និងត្រូវបានអនុម័តក្នុងឆ្នាំ ២០០០[15]។ល។

### តារាងទី ១ ៖ ប្រការចែងសំខាន់ៗក្នុងសេចក្ដីសម្រេចទាំង ១០ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ

| ឆ្នាំចេញសេចក្ដីសម្រេច | ចំណុចគោល និងប្រការចែងសំខាន់ៗ |
|---|---|
| S/RES/1325 ( 2000 ) | ភាពជាតំណាង និងការចូលរួមរបស់ស្ត្រីក្នុងអភិបាលកិច្ចសន្តិភាព និងសន្តិសុខ<br>ការការពារសិទ្ធិ និងស្ថាប័នរបស់ស្ត្រី នៅក្នុងស្ថានភាពមានជម្លោះ និងស្ថានភាពក្រោយជម្លោះ |
| S/RES/1820 ( 2008 ) | ការការពារស្ត្រីពីអំពើហិង្សាផ្លូវភេទក្នុងពេលមានជម្លោះ ការមិនអត់អោនចំពោះការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទដែលបង្កឡើងដោយបុគ្គលិកនាយកដ្ឋានប្រតិបត្តិការថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ |
| S/RES/1888 ( 2009 ) | ការបង្កើតការិយាល័យអ្នកតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកអំពើហិង្សាផ្លូវភេទក្នុងពេលមានជម្លោះ ការបង្កើតគំនិតផ្ដួចផ្ដើមអន្តរទីភ្នាក់ងារ "វិធានការសហប្រជាជាតិប្រឆាំងអំពើហិង្សាផ្លូវភេទក្នុងពេលមានជម្លោះ" ការកំណត់ "ក្រុមអ្នកជំនាញ" ការចាត់តាំងទីប្រឹក្សាខាងកិច្ចការពារស្ត្រី ឱ្យចុះបេសកកម្មតាមមូលដ្ឋាន |
| S/RES/1889 ( 2009 ) | ភាពចាំបាច់ក្នុងបង្កើនការចូលរួមរបស់ស្ត្រីក្នុងអភិបាលកិច្ចសន្តិភាព និងសន្តិសុខនៅគ្រប់កម្រិត<br>ការបង្កើតសូចនាករកម្រិតសកល ដើម្បីបង្ហាញទិសដៅដល់ការអនុវត្តសេចក្ដីសម្រេចលេខ ១៣២៥ |

| ឆ្នាំចេញសេចក្ដីសម្រេច | ចំណុចគោល និងប្រការចែងសំខាន់ៗ |
| --- | --- |
| S/RES/1960 (2010) | ការរៀបចំឱ្យមានការពិនិត្យតាមដាន ការវិភាគ និងការធ្វើរបាយការណ៍ពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទក្នុងពេលមានជម្លោះ ការដាក់បញ្ចូលទីប្រឹក្សាសន្តិភាពរបស់ស្ត្រីទៅក្នុងបេសកកម្មចុះមូលដ្ឋាន អមជាមួយនឹងទីប្រឹក្សាផ្នែកយេនឌ័រ |
| S/RES/2106 (2013) | ដេញដោលនិទណ្ឌភាព និងកង្វះគណនេយ្យភាពលើអំពើហិង្សាផ្លូវភេទក្នុងពេលមានជម្លោះ |
| S/RES/2122 (2013) | ចាត់តាំងភ្នាក់ងារសហប្រជាជាតិ UN Women ឱ្យធ្វើជាស្ថាប័នស្នូលរបស់អង្គការសហប្រជាជាតិដើម្បីផ្តល់ព័ត៌មាន និងការណែនាំស្តីពីការចូលរួមរបស់ស្ត្រីក្នុងអភិបាលកិច្ចសន្តិភាព និងសន្តិសុខ |
| S/RES2242 (2015) | ដាក់បញ្ចូលស្ត្រី សន្តិភាព និងសន្តិសុខ ទៅក្នុងរាល់ដំណើរការកម្រិតប្រទេសរបស់ក្រុមប្រឹក្សាសន្តិសុខ បង្កើតក្រុមអ្នកជំនាញក្រៅផ្លូវការទទួលបន្ទុកស្ត្រី សន្តិភាព និងសន្តិសុខ ដាក់បញ្ចូលការពិចារណាពីស្ត្រី សន្តិភាព និងសន្តិសុខទៅក្នុងសេចក្តីសម្រេចរបស់គណៈកម្មាធិការដាក់ទណ្ឌកម្ម ធ្វើការផ្សារភ្ជាប់ស្ត្រី សន្តិភាព និងសន្តិសុខ ទៅនឹងការប្រឆាំងអំពើភេរវកម្ម និងភាពជ្រុលនិយម |
| S/RES/2467 (2019) | ពង្រឹងការផ្តន្ទាទោស/ការដាក់ទណ្ឌកម្មលើអំពើហិង្សាផ្លូវភេទក្នុងពេលមានជម្លោះ បើកចំហរឱ្យមានការដាក់ទណ្ឌកម្មលើជនបង្ក បញ្ជាក់អះអាងអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ អំពាវនាវឱ្យមានការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ |
| S/RES/2493 (2019) | អំពាវនាវឱ្យរដ្ឋសមាជិកអង្គការសហប្រជាជាតិលើកកម្ពស់សិទ្ធិស្ត្រី លើកទឹកចិត្តឱ្យបង្កើតបរិយាកាសប្រតិបត្តិការដែលមានសុវត្ថិភាពសម្រាប់បុគ្គល/ស្ថាប័ន ដែលធ្វើការលើការលើកកម្ពស់សិទ្ធិស្ត្រី អំពាវនាវឱ្យមានការអនុវត្តពេញលេញរាល់សេចក្តីសម្រេចទាំងអស់ដែលពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ។ |

ប្រភព ៖ ត្រូវបានផលិតឡើងវិញមួយផ្នែកពី Kirby and Shepherd, 2016 and Myrttinen et al., 2020

ក្របខណ្ឌកម្រិតសកលផ្សេងទៀតដែលមានឥទ្ធិពល និងពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ គឺសេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងប៉េកាំង។ ក្របខណ្ឌនេះអំពាវនាវឱ្យមានសកម្មភាពជាយុទ្ធសាស្ត្រដើម្បីស្វែងយល់ពី "ផលប៉ះពាល់នៃជម្លោះប្រដាប់អាវុធ ឬជម្លោះផ្សេងទៀត មកលើស្ត្រី រួមទាំងស្ត្រីដែលកំពុងរស់នៅក្រោមការគ្រប់គ្រងដោយបរទេស" និងទទួលស្គាល់ការដឹកនាំរបស់ស្ត្រីជា "កំលាំងដ៏សំខាន់សម្រាប់...ការដោះស្រាយជម្លោះ និងការលើកកម្ពស់សន្តិភាពយូរអង្វែងនៅគ្រប់កម្រិត"។

ក្នុងឆ្នាំ ២០១៣ មានការអនុម័តអនុសាសន៍លេខ ៣០ ក្រោមអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ (CEDAW)។ អនុសាសន៍នេះលម្អិតពីសិទ្ធិរបស់ស្ត្រីក្នុងទប់ស្កាត់ជម្លោះ ការស្តារឡើងវិញពីជម្លោះ និងការស្តារឡើងវិញក្រោយពេលមានជម្លោះ និងលើកឡើងពីស្ថានភាពរបស់ស្ត្រីនៅគ្រប់ដំណាក់កាលនៃវដ្តជម្លោះ។ អនុសាសន៍នេះតម្រូវឱ្យប្រទេសហត្ថលេខីប្រមូលទិន្នន័យពីរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងធ្វើរបាយការណ៍អនុលោមតាមចំណុចដៅរបស់អង្គការសហប្រជាជាតិ។

អនុសាសន៍ទូទៅលេខ ៣៧ របស់អនុសញ្ញា CEDAW ដែលបានព្រមព្រៀងក្នុងឆ្នាំ ២០១៨ ផ្តោតសំខាន់លើទិដ្ឋភាពដែលពាក់ព័ន្ធនឹងយេនឌ័រក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។ របៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ទទួលស្គាល់ថាសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ជាចំណុចស្នូលនៃសន្តិភាព សន្តិសុខ និងការអភិវឌ្ឍប្រកបដោយចីរភាព និងលើកកម្ពស់ស្ត្រី សន្តិភាព និងសន្តិសុខ តាមរយៈគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពស្តីពីសមភាពយេនឌ័រ ការកាត់បន្ថយវិសមភាព និងសន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ[16]។

ក្របខណ្ឌអន្តរជាតិផ្សេងទៀតដែលមានភាពពាក់ព័ន្ធ គឺសេចក្តីសម្រេចលេខ ២២៥០ របស់ក្រុមប្រឹក្សាសន្តិសុខស្តីពីយុវជន សន្តិភាព និងសន្តិសុខ ដែលត្រូវបានអនុម័តក្នុងឆ្នាំ ២០១៥។ សេចក្តីសម្រេចនេះអំពាវនាវឱ្យការចូលរួមរបស់យុវជននិងយុវនារី ក្នុងដំណើរការសន្តិភាព និងសន្តិសុខ ។ គោលបំណងនៃការបង្កើនកិច្ចខិតខំប្រឹងប្រែងនេះ គឺដើម្បីធានាថា ការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ មានភាពប្រសព្វគ្នា និងបរិយាបន្ន ពីស្ត្រីមានពិការភាព ចាស់ជរា និងយុវជន ក៏ដូចជាស្ត្រីមកពីក្រុមមានតំណាងតិចតួច និងក្រុមងាយរងគ្រោះ[17]។

ការវិវត្តទាំងអស់នេះបានរួមចំណែកកាន់តែច្រើនដល់គំរូសន្តិសុខដែលឆ្លើយតបនឹងយេនឌ័រ និងឆ្លុះបញ្ចាំងពីទំនាក់ទំនងសង្គមដែលមានលក្ខណៈបរិវត្ត[18]។

## ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ

សន្និសីទអ្នកជំនាញ (symposium) ថ្នាក់តំបន់លើកទី ១ ស្តីពីការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលបានរៀបចំឡើងក្នុងឆ្នាំ ២០១៩ នាទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ស្នើឱ្យមានការសិក្សាថ្នាក់តំបន់ដើម្បីបង្កើនការយល់ដឹងអំពីការបកស្រាយរបៀបវារៈនេះនៅទូទាំងតំបន់អាស៊ាន។ ការសិក្សានេះត្រូវបានបោះពុម្ពផ្សាយក្នុងឆ្នាំ ២០២១។ អនុសាសន៍ដ៏សំខាន់មួយពីការសិក្សានេះ គឺការបង្កើតផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ[19] ដែលត្រូវបានអនុម័តដោយប្រមុខដឹកនាំអាស៊ាននៅឆ្នាំ ២០២២ ក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី ៤០ និង ៤១។

គោលបំណងចម្បងនៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ គឺដើម្បីផ្តល់ការណែនាំច្បាស់លាស់ស្តីពីការអនុវត្ត នេះបានផ្តល់ឱកាសគ្រប់គ្រាន់សម្រាប់ការឆ្លើយតបនឹងអាទិភាព និងតថភាពជាតិស្តីពីសន្តិភាព និងសន្តិសុខ[20]និងគាំទ្រនវានុវត្តន៍ថ្នាក់ជាតិ។ ភាពម្ចាស់ការរបស់ប្រទេសនីមួយៗ និងការចូលរួមក្នុងអន្តរាគមន៍នានា ជាកត្តាចាំបាច់បំផុត។ កញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំនេះ នឹងជួយដល់ភាគីពាក់ព័ន្ធសំខាន់ៗក្នុងរដ្ឋសមាជិកអាស៊ាន លើការរៀបចំ អនុវត្ត ពិនិត្យតាមដាន និងវាយតម្លៃផែនការសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈដំណើរការប្រកបដោយក្នុងបរិបទ ទូលំទូលាយ[21]។

# ជម្រើសផ្សេងៗក្នុងការបង្កើតផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ

ក្រោយការអនុម័តសេចក្តីសម្រេចលេខ ១៣២៥ អគ្គលេខាធិការអង្គការសហប្រជាជាតិ និងក្រុមប្រឹក្សាសន្តិសុខ បានគូសបញ្ជាក់ពីភាពចាំបាច់ដែលប្រទេសទាំងអស់ត្រូវអនុវត្តគោលការណ៍របស់ខ្លួនឱ្យខាងតែបាន តាមរយៈការបង្កើតផែនការសកម្មភាពជាតិ។ ផែនការទាំងនេះត្រូវកំណត់ចំណុចដៅជាក់ស្តែង និងការប្តេជ្ញាចិត្ត ដើម្បីជាត្រីវិស័យសម្រាប់គោលនយោបាយក្នុងនិងក្រៅប្រទេស ស្ថាប័ន និងគំនិតផ្តួចផ្តើមនានា។ គិតត្រឹមពាក់កណ្តាលឆ្នាំ ២០២៣ រដ្ឋសមាជិកចំនួន ១០៧ ប្រទេស មានផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

ផែនការសកម្មភាពជាតិលម្អិតពីសកម្មភាពដែលរដ្ឋាភិបាលកំពុងអនុវត្ត ហើយនឹងធ្វើក្នុងចិរវេលាកំណត់មួយ ដើម្បីបំពេញកាតព្វកិច្ចក្រោមសេចក្តីសម្រេចទាំង ១០ របស់ក្រុមប្រឹក្សាសន្តិសុខ។ ក្នុងឆ្នាំ ២០០២ ក្រុមប្រឹក្សាសន្តិសុខ "លើកទឹកចិត្តឱ្យរដ្ឋសមាជិក...និងតួអង្គពាក់ព័ន្ធផ្សេងទៀត បង្កើតយុទ្ធសាស្ត្រ និងផែនការសកម្មភាពច្បាស់លាស់ ដោយមានគោលដៅ និងចិរវេលាជាក់លាក់" និង "រៀបចំសកម្មភាពចំគោលដៅដែលផ្តោតលើបញ្ហាប្រឈមរបស់ស្ត្រី និងក្មេងស្រី ក្នុងស្ថានភាពក្រោយពេលមានជម្លោះ"។

ក្រុមប្រឹក្សាសន្តិសុខបានពង្រឹងការគាំទ្រខាងលើក្នុងឆ្នាំ ២០០៤ "ស្វាគមន៍កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋសមាជិកក្នុងការអនុវត្តសេចក្តីសម្រេចលេខ ១៣២៥ (២០០០) នៅថ្នាក់ជាតិ ដូចជា ការបង្កើតផែនការសកម្មភាពជាតិ និងបានលើកទឹកចិត្តឱ្យរដ្ឋសមាជិកបន្តអនុវត្តសេចក្តីសម្រេចនេះ"។ ក្នុងឆ្នាំ ២០០៥ ក្រុមប្រឹក្សាសន្តិសុខ "បានអំពាវនាវឡើងវិញឱ្យរដ្ឋសមាជិកបន្តអនុវត្តសេចក្តីសម្រេចលេខ ១៣២៥ (២០០០) ដូចជា តាមរយៈការបង្កើតផែនការសកម្មភាពជាតិ ឬយុទ្ធសាស្ត្រថ្នាក់ជាតិផ្សេងទៀត[22,23]"។

ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលបានអនុម័តក្នុងឆ្នាំ ២០២២ លើកទឹកចិត្តឱ្យរដ្ឋសមាជិកប្រកាសជាផ្លូវការ ឬបន្តរៀបចំកសាងផែនការសកម្មភាពជាតិ ឬក្របខណ្ឌគោលនយោបាយ និងកំណត់តួនាទី និងការទទួលខុសត្រូវសម្រាប់ថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ[24]។

ប្រទេសនីមួយៗនឹងកំណត់វិធីល្អបំផុតសម្រាប់ការអនុវត្តរបៀបវារៈនេះ ទៅតាមបរិបទជាក់លាក់របស់ខ្លួន ដែលជាផ្នែកមួយនៃការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រី។ ប្រទេសមួយចំនួនបានដាក់បញ្ចូលចំណុចពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ ទៅក្នុងច្បាប់ គោលនយោបាយ និងផែនការដែលស្រាប់ ដូចជា ផែនការអភិវឌ្ឍន៍ជាតិ (ឧ. យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ) និងយុទ្ធសាស្ត្រសន្តិសុខជាតិ ឬយុទ្ធសាស្ត្រការពារជាតិ ជាដើម។ ប្រទេសផ្សេងទៀតបានអនុម័តផែនការសកម្មភាពជាតិដាច់ដោយឡែកតាមរយៈដំណើរការពិគ្រោះយោបល់ ដើម្បីកសាងការយល់ដឹង និងភាពម្ចាស់ការក្នុងចំណោមភាគីពាក់ព័ន្ធផ្សេងៗនៅក្នុងជួរ រដ្ឋាភិបាល ដែលដើរតួនាទីដោយផ្ទាល់ ឬដោយប្រយោលក្នុងការអនុវត្ត[25]។ តារាងទី ២ សង្ខេបពីគុណសម្បត្តិ និងគុណវិបត្តិមួយចំនួននៃការដាក់បញ្ចូលចំណុចពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ ទៅក្នុងគោលនយោបាយ ឬផែនការដែលមានស្រាប់ ឬការអនុម័តអភិក្រមដាច់ដោយឡែក[26]។

## តារាងទី ២ ៖ គុណសម្បត្តិ និងគុណវិបត្តិនៃផែនការសកម្មភាពជាតិចម្រុះ និងផែនការសកម្មភាពជាតិដាច់ដោយឡែក

| | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|
| ដាក់បញ្ចូលទៅក្នុងផែនការដែលមានស្រាប់ | ការបង្កើតផែនការសកម្មភាពជាតិអាចទាមទារធនធានកាន់តែតិច។ បញ្ហាពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ អាច បញ្ជ្រាបទៅក្នុងទិសដៅ និងគំនិតផ្តួចផ្តើមសំខាន់ៗនៅថ្នាក់ជាតិ ស្តីពីសន្តិសុខ យុត្តិធម៌ និងការអភិវឌ្ឍ។ | ចំណុចពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ អាចក្លាយជា "ចំណុចបន្ទាប់បន្សំ" ឬគ្មានធន្ទៈពិតប្រាកដ។ ធនធានអាចត្រូវបានបង្វែរពីចំណុចទាំងនេះទៅកម្មវិធីផ្សេងទៀត ដែលទទួលបានចំណាប់អារម្មណ៍ជាង នៅក្នុងគោលនយោបាយ ច្បាប់ ឬផែនការ។ |
| ផែនការសកម្មភាពជាតិដាច់ដោយឡែក | បង្កើនការយល់ដឹងថ្នាក់ជាតិអំពីរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ផ្តោតលើការអនុវត្តគោលដៅនៃរបៀបវារៈនេះ ក្នុងអាទិភាពជាតិ។ បង្កភាពងាយស្រួលជាងមុន ក្នុងការពិនិត្យតាមដានវឌ្ឍនភាព និងបរាជ័យក្នុងការអនុវត្ត។ ប្រសិនបើផ្អែកលើការរៀបចំផែនការ និងការអនុវត្តតាមបែបចូលរួម វាមានការចូលរួមពាក់ព័ន្ធនឹងភាគីមកពីតំបន់ផ្សេងៗក្នុងសហគមន៍អនុវត្តន៍ ដើម្បីបង្កើតជាការប្តេជ្ញាចិត្ត។ | ទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែម និងធនធានកាន់តែច្រើនក្នុងការផ្តួចផ្តើមដំណើរការនេះ ត្រូវផ្តល់ហេតុផលពីភាពចាំបាច់ និងអនុវត្ត។ អាចត្រួតគ្នានឹងកិច្ចខិតខំប្រឹងប្រែងក្នុងផែនការសកម្មភាពជាតិដែលមានស្រាប់។ ផែនការសកម្មភាពនេះអាច "ត្រូវបានញែកដាច់ពីគេ/មិនទទួលបានការយកចិត្តទុកដាក់" ដោយសារគ្មានធន្ទៈពិតប្រាកដ ត្រូវ និងមិនយកទៅអនុវត្ត។ |

រូបទី ១ បង្ហាញពីចំនួនប្រទេសដែលបានបង្កើតផែនការសកម្មភាពជាតិ (គិតត្រឹមពាក់កណ្តាលឆ្នាំ ២០២៣)។ ប្រទេស ១៣ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកទាំងមូល បានដាក់ចេញផែនការ។ រដ្ឋសមាជិកអាស៊ានជាច្រើនសម្រេចបានវឌ្ឍនភាពគួរកត់សម្គាល់ក្នុងការបង្កើតផែនការ និងក្របខណ្ឌគោលនយោបាយជាតិផ្សេងទៀត ដើម្បីអនុវត្តសេចក្តីសម្រេចលេខ ១៣២៥។ ប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីន បានបង្កើត និងអនុវត្តផែនការសកម្មភាពជាតិ ដែលត្រូវបានព្រាងឡើង ក្រោមភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិល។ ប្រទេសកម្ពុជា ម៉ាឡេស៊ី និងវៀតណាម បានធ្វើបច្ចុប្បន្នភាពក្របខណ្ឌគោលនយោបាយជាតិរបស់ខ្លួនដែលពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ[27]។

### រូបទី ១ ៖ ប្រទេសដែលបានអនុម័តផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (គិតត្រឹមខែ កក្កដា ឆ្នាំ ២០២៣)




ប្រភព ៖ WILPF, n.d.

ទោះបីជាមានវឌ្ឍនភាពក្តី ប៉ុន្តែផែនការសកម្មភាពជាតិមួយចំនួនគឺមិនមានភាពជាក់ស្តែង ខ្វះការប្តេជ្ញាចិត្តផ្នែកនយោបាយ និងធនធានសម្រាប់ការអនុវត្ត ឬកង្វះការពិនិត្យតាមដាន និងគណនេយ្យភាព និងខ្វះការសម្របសម្រួលក្នុងស្ថាប័នរដ្ឋាភិបាល និងនៅកម្រិតផ្សេងៗ[28]។ កញ្ចប់ឧបករណ៍នេះ ផ្តល់អនុសាសន៍ជាក់លាក់សម្រាប់ការដោះស្រាយបញ្ហាប្រឈមមួយចំនួនខាងលើ។

# គម្រូផែនការសកម្មភាពជាតិ

ការប្រែក្លាយរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខទៅជាគោលនយោបាយជាតិ គឺ ផ្អែកខ្លាំងលើបរិបទជាតិ។ ផែនការសកម្មភាពជាតិដែលបង្កើតឡើងដោយប្រទេសម្ចាស់ជំនួយ មានលក្ខណៈផ្តោតទៅក្រៅប្រទេស (outward-looking) និងច្រើនតែផ្តោតលើគោលនយោបាយបរទេស ជាពិសេសទំនាក់ទំនងជាមួយប្រទេសដែលរងផលប៉ះពាល់ដោយសារជម្លោះ ដើម្បីទទួលបានជំនួយអភិវឌ្ឍន៍ផ្លូវការ។ ប្រទេសដែលទើបងើបចេញពីជម្លោះ និងប្រទេសដែលរងផលប៉ះពាល់ដោយសារជម្លោះ ច្រើនតែផ្តោតលើបរិបទនយោបាយក្នុងស្រុក។ ចំណុចសំខាន់របស់ផែនការមួយ បង្កផលវិបាកជាច្រើន។

ប្រទេសមួយចំនួនច្របាច់បញ្ចូលគ្នានូវគម្រូផែនការសកម្មភាពបែបផ្តោតមកក្នុងប្រទេស និងបែបផ្តោតទៅក្រៅប្រទេស។ ឧ. ផែនការទី ១ (ឆ្នាំ ២០១៤) និងផែនទី ២ (ឆ្នាំ ២០២១) របស់ឥណ្ឌូនេស៊ី ប្រើប្រាស់គម្រូចម្រុះនេះ។ តារាងទី ៣ បង្ហាញពីគម្រូផ្សេងៗមួយចំនួន[29]។

តារាងទី ៣ ៖ គម្រូផ្សេងៗនៃផែនការសកម្មភាពជាតិ

| ផែនការបែបផ្តោតមកក្នុងប្រទេស | ផែនការបែបផ្តោតទៅក្រៅប្រទេស | អភិក្រមចម្រុះ |
|---|---|---|
| អ៊ុយហ្គង់ដា | កាណាដា | ឥណ្ឌូនេស៊ី ហ្វីលីពីន ទីម័រខាងកើត |
| ស៊ូដង់ | ន័រវែស | ថៃ (វិធានការជាតិ និងគោលការណ៍ណែនាំស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ) |

ជំហានទី ១

# ការរៀបចំផែនការសកម្មភាពជាតិ

ផែនការសកម្មភាពជាតិត្រូវបានបង្កើតឡើងដោយ និងតាងនាមឱ្យរដ្ឋាភិបាល ដើម្បីប្រែក្លាយសេចក្ដីសម្រេចអន្តរជាតិ និងក្របខណ្ឌតំបន់ទៅជាសកម្មភាពថ្នាក់ជាតិ។ ស្ថាប័នរដ្ឋាភិបាលជាអ្នកដឹកនាំការរៀបចំកសាងផែនការ និងផ្ដល់ឱកាសឱ្យមានការចូលរួមពីអង្គការសង្គមស៊ីវិល គ្រឹះស្ថានសិក្សា វិស័យឯកជន ស្ថាប័នថ្នាក់តំបន់ និងភាគីពាក់ព័ន្ធផ្សេងទៀត ។ ផ្នែកនេះសង្ខេបពីធាតុផ្សំសំខាន់ៗនៃដំណើរការរៀបចំផែនការ ដោយកត់សម្គាល់ថា ដំណើរការនេះគួរឆ្លុះបញ្ចាំងពីស្ថានភាពរបស់ប្រទេស និងកត្តានានា ដូចជា ភាពចម្រុះ និងចំនួនភាគីពាក់ព័ន្ធ មជ្ឈដ្ឋាន ផ្សេងៗនៅក្នុងតំបន់ ប្រទេស ឬសហគមន៍ ការយកចិត្តទុកដាក់ផ្នែកនយោបាយ (political sensitivities) និងធនធានដែលមាន។

## ១.បង្កើតរចនាសម្ព័ន្ធសម្រាប់ត្រួតពិនិត្យការសម្របសម្រួល សេចក្ដីព្រាង និងការអនុវត្ត

រចនាសម្ព័ន្ធ ឬលេខាធិការដ្ឋានមួយ អាចសម្របសម្រួល និងត្រួតពិនិត្យរាល់សកម្មភាពដែលពាក់ព័ន្ធនឹងការកសាង និងការអនុវត្តផែនការសកម្មភាពជាតិ។ កិច្ចការនេះគួរដឹកនាំដោយស្ថាប័នរដ្ឋាភិបាល ដែលទទួលបានការគាំទ្រពេញលេញសម្រាប់ការជំរុញដំណើរការ និងអាចបញ្ចប់ជំហានផ្សេងៗបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។ សមាជិកលេខាធិការដ្ឋានគួរជ្រើសរើសចេញពីស្ថាប័នចម្រុះ ដែលពាក់ព័ន្ធក្នុងការអនុវត្ត និងបានកំណត់ច្បាស់ពីតួនាទី និងការទទួលខុសត្រូវច្បាស់លាស់។ រចនាសម្ព័ន្ធគួរបង្កើតមុនការអនុវត្តសកម្មភាព។

## ២.កសាងនិងបញ្ជ្រាបការយល់ដឹងដល់ភាគីពាក់ព័ន្ធសំខាន់ៗស្ដីពីការទទួលខុសត្រូវរបស់ពួកគេ និងធ្វើឱ្យមានភាពម្ចាស់ការ

បន្ទាប់ពីផែនការសកម្មភាពជាតិបានបង្កើតឡើង ដើម្បីឆ្លើយតបទៅនឹង សេចក្ដីសម្រេចអន្តរជាតិ និងក្របខណ្ឌតំបន់ ការកសាងការយល់ដឹងគឺជាជំហានដំបូងដ៏សំខាន់។ សកម្មភាពនេះនឹងបង្កើនការយល់ដឹងរបស់ភាគីពាក់ព័ន្ធ ពង្រឹងឆន្ទៈនយោបាយ លើកកម្ពស់ភាពម្ចាស់ការពេញលេញ និងកសាងកិច្ចសហការឆ្លងវិស័យ[30]។ យុទ្ធសាស្ត្របែបសហការដែលមានការចូលរួមពីតួអង្គផ្សេងៗមកពីសាវតារចម្រុះ ជួយធានាថា គំនិតផ្ដួចផ្ដើមស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលដឹកនាំ និងគ្រប់គ្រងដោយតួអង្គទាំងនោះតាំងពីដំបូងមានការអន្តរាគមន៍ទូលំទូលាយ។ ការណ៍នេះនឹងសម្រួលដល់ការកសាងឯកភាពគ្នា ដោយផ្អែកលើការយល់ដឹង ពីក្របខណ្ឌផ្សេងៗ និងភាពពាក់ព័ន្ធនៃក្របខណ្ឌទៅនឹងបរិបទជាតិ។

មេរៀនសង្គមនីយកម្ម និងកសាងសមត្ថភាពជាមួយមន្ត្រីរដ្ឋាភិបាលសំខាន់ៗ អង្គការសង្គមស៊ីវិល គ្រឹះស្ថានសិក្សា និងក្រុមហ៊ុនក្នុងវិស័យឯកជន ត្រូវផ្ដល់ឱ្យ មុនការបង្កើតផែនការណាមួយ ហើយវាជាជម្រើស ក្នុងការកំណត់ការចូលរួមរបស់ភាគីពាក់ព័ន្ធចម្រុះ។ សកម្មភាពទាំងនេះអាចជួយកសាងការយល់ដឹង ជំរុញភាពម្ចាស់ការពេញលេញ និងធ្វើឱ្យមានការមូលមតិគ្នាតាំងពីដំបូងលើមាតិកា និងការបង្កើតផែនការ និងការកំណត់សកម្មភាពអាទិភាពសំខាន់ៗ ព្រមទាំងអាចជំរុញភាពជាដៃគូរឹងមាំ រវាងរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិល។ មធ្យោបាយមានប្រសិទ្ធភាពផ្សេងទៀតសម្រាប់ការកសាងការយល់ដឹង និងការតស៊ូមតិ គឺយុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយ[31]។

ដើម្បីធានាឆន្ទៈនយោបាយ គួរបង្ហាញពីគុណសម្បត្តិរបស់ផែនការទៅដល់មន្ត្រីរដ្ឋាភិបាលសំខាន់ៗនៅក្នុងក្រសួងសាម៉ី ក៏ដូចជាតួអង្គដែលមានចំណាប់អារម្មណ៍នៅក្នុងអង្គការសង្គមស៊ីវិល គ្រឹះស្ថានសិក្សា និងប្រព័ន្ធផ្សព្វផ្សាយ[32]។ល។ ដំណើរការនេះគួរខិតខំពង្រឹង

ការយល់ដឹងកាន់តែច្បាស់អំពីភាពបន្សីគ្នារវាងអាទិភាពជាតិ និងអាទិភាពតំបន់។
ខាងក្រោមនេះជាបញ្ហាសំខាន់ៗមួយចំនួនដែលត្រូវគូសបញ្ជាក់ ៖

- ការយល់ច្បាស់ពីរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងក្របខណ្ឌគោលនយោបាយតំបន់ និងក្របខណ្ឌគោលនយោបាយសកលដែលមានស្រាប់ និងជាពិសេសហេតុផលដែល របៀបវារៈនេះដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការអភិវឌ្ឍប្រកបដោយចីរភាព។
- បញ្ហាឆ្លងវិស័យ និងសារៈសំខាន់នៃការសម្របសម្រួល
- មេរៀន និងការអនុវត្តល្អបំផុតពីប្រទេសផ្សេងៗ
- ក្របខណ្ឌគោលនយោបាយ និងក្របខណ្ឌគតិយុត្តិ និងសកម្មភាពអាទិភាពសំខាន់ៗ ដើម្បីដោះស្រាយបញ្ហាសន្តិសុខជាតិ (ទាំងបញ្ហាសន្តិសុខទូទៅ និងបញ្ហាសន្តិសុខថ្មីៗ) ចេញពីទស្សនៈយេនឌ័រ ដូចជា ទស្សនៈរបស់ក្មេងស្រី។
- បញ្ហាសមភាពយេនឌ័រដែលបន្តលេចឡើងក្នុងសន្តិភាព និងសន្តិសុខ និងរបៀបដោះស្រាយបញ្ហាទាំងនេះ។
- ការវិវត្តនៃនិម្មាបនកម្មស្ត្រី សន្តិភាព និងសន្តិសុខនៅក្នុងតំបន់អាស៊ាន ដែលអំពាវនាវឱ្យបន្តធ្វើបច្ចុប្បន្នភាពលើបញ្ហាសន្តិសុខ និងការបង្កើនសមត្ថភាពរបស់ភាគីពាក់ព័ន្ធ។
- ការដាក់បញ្ចូលកម្មវិធីស្តីពីស្ត្រី សន្តិភាព និងសន្តិសុខទៅក្នុងថវិការដ្ឋាភិបាល និងការកំណត់រកប្រភពហិរញ្ញប្បទានថ្មីៗ។

### ចំណុចសំខាន់ៗ ៖

ការកសាងការយល់ដឹង និងការស្វែងរកមតិគាំទ្រអាចបន្តធ្វើឡើង សូម្បីតែក្រោយការបង្កើតផែនការសកម្មភាពជាតិ។ ឧ. ក្រោយការវាយតម្លៃ ព័ត៌មានដែលប្រមូលបាន អាចផ្តល់មូលដ្ឋានដល់ការស្វែងរកមតិគាំទ្រ និងកសាងការយល់ដឹង។ ការវាយតម្លៃជាសកលរកឃើញថា ការគាំទ្ររបស់ភ្នាក់ងារសហប្រជាជាតិ UN Women ដល់ផែនការសកម្មភាពជាតិ អាចជួយបង្កើនការបន្សីទៅនឹងក្របខណ្ឌសកល និងក្របខណ្ឌតំបន់ជាច្រើន តាមរយៈការកសាងចំណេះដឹងនៅកម្រិតប្រទេស និងការប្តេជ្ញាចិត្តចំពោះក្របខណ្ឌបែបនិយាម (normative framework) និងភាពពាក់ព័ន្ធរបស់ក្របខណ្ឌទាំងនោះទៅនឹងគោលបំណងស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

## ៣.កំណត់តួនាទី និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធសំខាន់ៗ

ការរៀបចំផែនការប្រកបដោយប្រសិទ្ធភាព ទាមទារឱ្យមានការកំណត់តួនាទី និងការទទួលខុសត្រូវច្បាស់លាស់ ដោយផ្អែកតាមលក្ខខណ្ឌយោងរបស់សេចក្តីព្រាង ការសម្របសម្រួល និងការអនុវត្តផែនការសកម្មភាពជាតិ[33]។ គណៈកម្មាធិការសម្របសម្រួល និងធ្វើសេចក្តីព្រាងផែនការ គួររៀបចំលក្ខខណ្ឌយោងដែលផ្សារភ្ជាប់នឹងក្របខណ្ឌសកល និងក្របខណ្ឌតំបន់ ទៅនឹងអាទិភាពជាតិ។ គណៈកម្មាធិការនេះមានការអាចចូលរួមដោយដៃគូអភិវឌ្ឍន៍ដែលដើរតួនាទីសំខាន់ក្នុងការកសាងសមត្ថភាពរបស់ស្ថាប័នរដ្ឋ និងស្ថាប័នមិនមែនរដ្ឋ។ ដៃគូអភិវឌ្ឍន៍អាចជួយដល់ការកៀរគរភាគីពាក់ព័ន្ធ និងធនធាន និងការបង្កើតយន្តការសម្របសម្រួល[34]។

ខាងក្រោមនេះជាកិច្ចការមួយចំនួនសម្រាប់តួអង្គផ្សេងៗ[35]៖

- មន្ត្រីរដ្ឋាភិបាលធានាថា លទ្ធផលចុងក្រោយស៊ីសង្វាក់គ្នានឹងអាទិភាពសន្តិសុខជាតិ ផ្តល់ធនធាន (ហិរញ្ញវត្ថុ មនុស្ស និងបច្ចេកទេស) ដើម្បីគាំទ្រដល់ការអនុវត្ត និងសម្របសម្រួលការពិនិត្យតាមដាន និងវាយតម្លៃវឌ្ឍនភាព និងផលជះ។

- អង្គការសង្គមស៊ីវិលផ្តល់ធាតុចូលប្រកបដោយអត្ថន័យ និងផ្អែកតាមបរិបទ និងគាំទ្រដល់តួអង្គផ្ទើមក្នុងរដ្ឋាភិបាល (government champion) តាមរយៈការស្វែងរកមតិគាំទ្រ ពង្រីកវិសាលភាពរបស់រដ្ឋាភិបាលក្នុងការផ្សព្វផ្សាយពីគោលបំណងនៃផែនការសកម្មភាពជាតិទៅដល់សហគមន៍មូលដ្ឋាន ជាដៃគូ អនុវត្តសកម្មភាពសំខាន់ៗ និងពិនិត្យតាមដាន និងវាយតម្លៃវឌ្ឍនភាព និងផលជះ។

- សហគមន៍អន្តរជាតិផ្តល់ធាតុចូលប្រកបដោយអត្ថន័យ សម្រាប់ការរៀបចំ ផ្តល់ធនធាន (ហិរញ្ញវត្ថុ មនុស្ស និងបច្ចេកទេស) ដើម្បីគាំទ្រដល់ការអនុវត្ត សហការលើសកម្មភាពសំខាន់ៗ និងរួមចំណែកដល់ការពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីឱ្យអ្នកដឹកនាំនៅក្នុង និងនៅក្រៅជួររដ្ឋាភិបាល អាចរក្សាការទទួលខុសត្រូវគ្នាទៅវិញទៅមកបាន។

- តួនាទីរបស់វិស័យឯកជនគួរស្វែងយល់បន្ថែមទៀត ទៅតាមបរិបទប្រទេសនីមួយៗ ដែលអាចជំរុញ ការចូលរួម និងការសហការ ក្នុងការពន្លឿនរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

តារាងទី ៤ បង្ហាញពីគំនិតសំខាន់ៗមួយចំនួនសម្រាប់ពង្រឹងភាពម្ចាស់ការថ្នាក់ជាតិលើផែនការសកម្មភាពជាតិ។

## តារាងទី ៤ ៖ ចំណុចសំខាន់ៗសម្រាប់ពង្រឹងភាពម្ចាស់ការថ្នាក់ជាតិ

| ភាគីពាក់ព័ន្ធក្នុងរដ្ឋាភិបាល | ជំហានផ្សេងៗក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាពជាតិ | គំនិតផ្សេងៗសម្រាប់ពង្រឹងភាពម្ចាស់ការថ្នាក់ជាតិ |
|---|---|---|
| ក្រសួង ៖ យេនឌ័រ/កិច្ចការនារី មហាផ្ទៃ យុត្តិធម៌ អភិវឌ្ឍន៍សង្គម សុខាភិបាល អប់រំ កសិកម្ម។ល។<br><br>ទីភ្នាក់ងារសាធារណៈ ៖ ការពង្រឹងការអនុវត្តច្បាប់ វិស័យសន្តិសុខ សិទ្ធិមនុស្ស ការិយាល័យស្ថិតិ។ល។ | ការរៀបចំផែនការ ៖<br><br>កិច្ចសន្ទនាជាមួយមន្ត្រី រដ្ឋាភិបាល និងទីភ្នាក់ងារសាធារណៈ<br><br>ការវិភាគភាគីពាក់ព័ន្ធ<br><br>ការវិភាគបរិបទ/ស្ថានភាព<br><br>ការជ្រើសរើសសមាជិកគណៈកម្មាធិការសម្រាប់ធ្វើសេចក្តីពង្រាងផែនការ<br><br>ការជ្រើសរើសចំណុចអាទិភាព<br><br>ការកៀរគរមូលនិធិ/ធនធាន<br>ការសម្របសម្រួល ៖ ទីភ្នាក់ងារដឹកនាំ និងត្រួតពិនិត្យការអនុវត្ត<br><br>ការពិនិត្យតាមដាន និងវាយតម្លៃ ៖<br><br>ការចងក្រងការអនុវត្តល្អ និងមេរៀន និងចែករំលែក | ភាគីពាក់ព័ន្ធសំខាន់ៗក្នុងរដ្ឋាភិបាល គួរទទួលខុសត្រូវលើការបន្ស៊ីអាទិភាពជាតិទៅនឹងក្របខណ្ឌអន្តរជាតិ និងក្របខណ្ឌតំបន់ ដើម្បីបំពេញបន្ថែមលើការអភិវឌ្ឍជាតិ។<br><br>ការជ្រើសរើសភាគីពាក់ព័ន្ធក្នុងជួររដ្ឋាភិបាល គួរធ្វើឡើងដោយអ្នកធ្វើសេចក្តីសម្រេចមកពីក្រសួង ឬទីភ្នាក់ងារសាធារណៈដែលពាក់ព័ន្ធ។<br><br>មន្ត្រីរដ្ឋាភិបាលដែលត្រូវបានចាត់តាំងពីក្រសួង ឬទីភ្នាក់ងារពាក់ព័ន្ធ គួរដឹកនាំការធ្វើសវនកម្មស្ថាប័ន និងការវិភាគបរិបទ/ស្ថានភាព។<br><br>ប្រធានគណៈកម្មាធិការធ្វើសេចក្តីពង្រាងផែនការ គួរតែជាមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ដែលអាចធ្វើសេចក្តីសម្រេច និងមានសមត្ថភាព ឬអាចកៀរគរការគាំទ្រផ្នែកនយោ បាយ។<br><br>ក្រោមកិច្ចសហការជាមួយភាគីពាក់ព័ន្ធផ្សេងទៀត ប្រធានគណៈកម្មាធិការធ្វើសេចក្តីពង្រាងផែនការ គួរដឹកនាំការជ្រើសរើសចំណុចអាទិភាព ដោយមានពិគ្រោះយោបល់ជាមួយអ្នកតាក់តែងគោលនយោបាយផ្សេងទៀត (រដ្ឋបាល និងនយោបាយ)។<br><br>សកម្មភាពអាទិភាពគួរដាក់បញ្ចូលទៅក្នុងថវិកាតាមវិស័យសម្រាប់ការអនុវត្ត។<br><br>រដ្ឋាភិបាលគួរកំណត់រកប្រភពថ្មីៗនៃអភិវឌ្ឍន៍ហិរញ្ញ ប្បទាន ដូចជា តាមរយៈការរៀបចំថវិកាដែលឆ្លើយតបនឹងយេនឌ័រ។<br><br>យន្តការសម្របសម្រួលគួរដឹកនាំដោយរដ្ឋាភិបាល (ក្រ សួងជាក់លាក់) ដែលទទួលខុសត្រូវលើការអនុវត្តប្រកបដោយតម្លាភាព និងប្រសិទ្ធភាព។<br><br>ស្ថាប័នស្ថិតិរបស់រដ្ឋាភិបាល គួរសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ផ្សេងទៀតក្នុងការប្រមូលទិន្នន័យ/ព័ត៌មានដោយផ្អែកលើគោលនយោបាយ/ផែនការអភិវឌ្ឍន៍ជាតិ។<br><br>ការជ្រើសរើសការអនុវត្តល្អ និងមេរៀន យកទៅបំពេញបន្ថែមទៅលើ គោលដៅអភិវឌ្ឍន៍ជាតិ។ |

# ៤.វិភាគស្ថានភាព

ការវិភាគស្ថាប័នជាតិដែលមានស្រាប់ និងតួអង្គអភិវឌ្ឍន៍ នឹងជួយកំណត់លក្ខណៈបន្សុីជាមួយ គោលនយោបាយជាតិ ក្រសួង និងនាយកដ្ឋានពាក់ព័ន្ធ និងផែនការសកម្មភាពតំបន់អាស៊ាន។ សកម្មភាពនេះនឹងគាំទ្រដល់អភិក្រមចម្រុះសម្រាប់ការអនុវត្តផែនការសកម្មភាពជាតិ និងផ្តល់ឱកាសឱ្យរដ្ឋាភិបាលឆ្លុះបញ្ចាំងពីសកម្មភាពដែលបានអនុវត្តកន្លងមក កំណត់អាទិភាព ឬឱកាសនាពេលអនាគត និងធានាចីរភាពគោលនយោបាយ។

ខាងក្រោមនេះជាការវិភាគស្ថានភាព ២ ផ្សេងគ្នា[36]៖

សវនកម្មស្ថាប័ន ៖ ការវាយតម្លៃគោលនយោបាយស្នូលរបស់នាយកដ្ឋានពាក់ព័ន្ធ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុដែលមាន និងបញ្ហាពាក់ព័ន្ធ។

ការវិភាគបរិបទ ៖ ការវាយតម្លៃស្ថានភាពនៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ពាក់ព័ន្ធនឹងការចូលរួមរបស់ស្ត្រីក្នុងនយោបាយ អំពើហិង្សាជ្រុលនិយម ការបណ្តេញចេញដោយបង្ខំ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ អំពើជួញដូរមនុស្ស និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្នុងចំណោមការគំរាមកំហែងថ្មីៗផ្សេងទៀតដល់សន្តិសុខ។

តារាងទី ៥ បង្ហាញពីចំណុចសំខាន់ៗនៃសវនកម្មស្ថាប័ន និងការវាតម្លៃបរិបទ។

### តារាងទី ៥ ៖ ចំណុចសំខាន់ៗនៃសវនកម្មស្ថាប័ន និងការវាយតម្លៃបរិបទ

| ប្រភេទនៃការវិភាគស្ថានភាព | ការប្តេជ្ញា | ច្បាប់ | គោលនយោបាយ | ស្ថាប័ន |
|---|---|---|---|---|
| សវនកម្មស្ថាប័ន | តើមានការប្តេជ្ញាចិត្តជាផ្លូវការចំពោះរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដូចជា សេចក្តីប្រកាស ឬសេចក្តីថ្លែងការណ៍ដោយថ្នាក់ដឹកនាំនយោបាយជាន់ខ្ពស់ ឬទេ? | តើមានច្បាប់ជាតិដែលកំពុងពន្លឿនរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ឬទេ? | តើមានគោលនយោបាយជាតិសំខាន់ៗអ្វីខ្លះដែលគាំទ្រដល់របៀបវារៈនេះ? តើមានឱកាសដាក់បញ្ចូលអាទិភាព និងគោលបំណងស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ទៅក្នុងរបៀបវារៈនោះ ឬទេ (ប្រសិនបើមិនទាន់បានបញ្ចូល)? | តើស្ថាប័នរដ្ឋាភិបាលណាខ្លះដែលមានភាពពាក់ព័ន្ធខ្លាំងក្នុងការដោះស្រាយបញ្ហាស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ? តើស្ថាប័នទាំងនោះមានធនធានហិរញ្ញវត្ថុដើម្បីអនុវត្តផែនការសកម្មភាពជាតិ ឬទេ? |
| | បញ្ហាប្រឈម | ឫសគល់នៃបញ្ហា | ឧបសគ្គធំៗដែលរារាំងមិនឱ្យស្ត្រីចូលរួមក្នុងបញ្ហាស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ នៅក្នុងបរិបទជាតិ? | ការរួមចំណែកសំខាន់ៗរបស់ស្ត្រីដល់ការដោះស្រាយជម្លោះ និងការលើកកម្ពស់សន្តិភាពប្រកបដោយចីរភាព |
| ការវាយតម្លៃបរិបទ | តើបញ្ហាប្រឈមធំៗអ្វីខ្លះដែលអាចរាំងស្ទះដល់វឌ្ឍនភាពក្នុងការរៀបចំផែនការ និងការផ្តោតលើទស្សនៈយេនឌ័រ និងបញ្ហាស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ? | តើអ្វីខ្លះជាឫសគល់នៃបញ្ហាសន្តិសុខដែលកំពុងលេចឡើងនៅក្នុងប្រទេស? តើបញ្ហាទាំងនោះបង្កផលប៉ះពាល់អ្វីខ្លះមកលើស្ត្រី និងក្មេងស្រី? | តើអ្វីខ្លះជាឧបសគ្គធំៗដែលរារាំងមិនឱ្យស្ត្រីចូលរួមក្នុងការធ្វើសេចក្តីសម្រេចលើបញ្ហាស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ? | តើស្ត្រីបានផ្តល់ការរួមចំណែកសំខាន់ៗអ្វីខ្លះដល់ការដោះស្រាយជម្លោះ និងការរក្សាសន្តិភាពប្រកបដោយចីរភាព? |

## ៥.គូសផែនទីភាគីពាក់ព័ន្ធ

ផែនការសកម្មភាពជាតិពឹងផ្អែកលើកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ដៃគូចម្រុះ ដូចនេះការវាយតម្លៃច្បាស់លាស់លើតួនាទី និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធនឹងជួយកំណត់ពីរបៀបដែលពួកគេអាចគាំទ្រដល់ផែនការនោះ។ ខាងក្រោមនេះជាសំណួរមគ្គុទេសក៍មួយចំនួនសម្រាប់ការគូសផែនទីបង្ហាញពីតួនាទីរបស់ភាគីពាក់ព័ន្ធ[37]៖

- តើភាគីពាក់ព័ន្ធសំខាន់ៗមានការយល់ដឹងកម្រិតណាអំពីរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងផែនការសកម្មភាពជាតិ?
- តើភាគីពាក់ព័ន្ធណាខ្លះដែលរងផលប៉ះពាល់ផ្ទាល់ ឬចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងស្តីពីសន្តិភាព និងសន្តិសុខ? តើអ្វីខ្លះជាចំណុចអាទិភាពរបស់ពួកគេសម្រាប់ការចូលរួមនោះ?
- តើភាគីពាក់ព័ន្ធណាខ្លះដែលតំណាងឱ្យស្ត្រីមកពីសាវតាចម្រុះ និង/ឬអនុវត្តទស្សនៈយេនឌ័រក្នុងការងារស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ? តើអ្វីខ្លះជាចំណាប់អារម្មណ៍របស់ភាគីពាក់ព័ន្ធផ្សេងៗដែលបន្ថែមគុណតម្លៃដល់សកម្មភាពនេះ (បញ្ហាដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម ទស្សនៈយល់ឃើញរបស់ក្មេងស្រី ក្នុងពេលនិងក្រោយពេលមានជម្លោះ បញ្ហាប្រឈមរបស់ស្ត្រីនៅក្នុងទីផ្សារការងារ។ល។) និងការកៀរគរដៃគូឱ្យបានកាន់តែគ្រប់ជ្រុងជ្រោយ?
- តើភាគីពាក់ព័ន្ធធ្វើការសម្របសម្រួលសកម្មភាពនានាដោយរបៀបណា ដើម្បីសម្រេចបានរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ?
- តើភាគីពាក់ព័ន្ធណាខ្លះដែលលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចស្តីពីសន្តិភាព និងសន្តិសុខ?

តារាងទី ៦ ផ្តល់តារាងវិភាគផលប៉ះពាល់ដើម្បីជួយដល់ការគូសផែនទីភាគីពាក់ព័ន្ធ[38]។ រូបទី ២ បង្ហាញពីប្រភេទផ្សេងៗនៃភាគីពាក់ព័ន្ធ។

### តារាងទី ៦ ៖ តារាងវិភាគផលប៉ះពាល់របស់ភាគីពាក់ព័ន្ធ

| ការវិភាគភាគីពាក់ព័ន្ធ | ចំណាប់អារម្មណ៍ (ទាប មធ្យម ខ្ពស់) | ឥទ្ធិពល (ទាប មធ្យម ខ្ពស់) | តើអ្វីដែលសំខាន់ចំពោះភាគីពាក់ព័ន្ធទាំងនោះ? | តើភាគីពាក់ព័ន្ធអាចរួមចំណែកដោយរបៀបណាដល់ផែនការសកម្មភាពជាតិ? | យុទ្ធសាស្ត្រដំរញការចូលរួមរបស់ភាគីពាក់ព័ន្ធ |
|---|---|---|---|---|---|
| ភាគីពាក់ព័ន្ធទី ១ | | | | | |
| ភាគីពាក់ព័ន្ធទី ២ | | | | | |
| ភាគីពាក់ព័ន្ធទី ៣ | | | | | |

រូបទី ២ ៖ ប្រភេទភាគីពាក់ព័ន្ធ បែងចែកតាមកម្រិតឥទ្ធិពលរបស់ពួកគេ







## ៦.បង្កើតវេទិកាពិគ្រោះយោបល់ប្រកបដោយបរិយាបន្ន សម្រាប់ភាគីពាក់ព័ន្ធដែលមានសារៈសំខាន់ ដើម្បីចែករំលែកព័ត៌មានជាប្រចាំ និងធានាតម្លាភាព

ការសម្របសម្រួល

ការបង្កើតយន្តការសម្របសម្រួលផ្ទៃក្នុងដែលមានប្រសិទ្ធភាព និងការជ្រើសរើសទីភ្នាក់ងាររដ្ឋាភិបាលឱ្យដឹកនាំជំរុញការធ្វើផែនការ ជាកត្តាសំខាន់ក្នុងការធានាការគាំទ្រផ្នែកស្ថាប័ន និងការទទួលយកយ៉ាងទូលំទូលាយ[39]។ សកម្មភាពនេះគួរធ្វើឡើងនៅដំណាក់កាលដំបូង។ ផ្អែកតាមលក្ខណៈធំទូលាយនៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ កិច្ចសហការឆ្លងវិស័យជាគន្លឹះនៃការសម្របសម្រួល និងការអនុវត្តប្រកបដោយជោគជ័យ។ ទីភ្នាក់ងារដឹកនាំដែលមានប្រសិទ្ធភាពនៅក្នុងអាស៊ាន មានដូចជា ក្រសួងពង្រឹងភាពអង់អាចដល់ស្ត្រី និងការពារកុមារនៃប្រទេសឥណ្ឌូនេស៊ី ការិយាល័យទីប្រឹក្សាប្រធានាធិបតីទទួលបន្ទុកដំណើរការសន្តិភាព (ចំណុះឱ្យការិយាល័យប្រធានាធិបតីហ្វីលីពីន) និងក្រសួងសន្តិសុខជាតិនៃប្រទេសទីម័រខាងកើត។

ជំហានដំបូងក្នុងការបង្កើតយន្តការសម្របសម្រួលដែលមានប្រសិទ្ធភាព គឺការវិភាគវប្បធម៌ស្ថាប័នជារួមរបស់រដ្ឋាភិបាល ដោយសួរសំណួរខាងក្រោម[40]៖

- តើការសម្រេចចិត្តអនុវត្តនឹងធ្វើឡើងដោយរបៀបណា?
- តើមានយន្តការសម្របសម្រួលពហុទីភ្នាក់ងារ ដែលទុកជាគម្រូឬទេ?
- ពីមុនមក តើវិធានការអ្វីខ្លះដែលមានប្រសិទ្ធភាព (ឬគ្មានប្រសិទ្ធភាព)?

វប្បធម៌ អាណត្តិ និងបញ្ហាផ្សេងទៀតរបស់ទីភ្នាក់ងារនីមួយៗ ជាចំណុចគួរពិចារណា[41]៖

- តើទីភ្នាក់ងារនីមួយៗធ្វើប្រតិបត្តិការក្នុងពេលវេលាដូចគ្នា សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រ ឬទេ?
- តើទីភ្នាក់ងារផ្សេងៗមានគោលការណ៍ណែនាំដូចគ្នាសម្រាប់ការបែងចែកធនធាន កំឡុងពេលរៀបចំកសាងថវិកាស្ថាប័នរបស់ខ្លួន ឬទេ?
- តើមានចំណុចខុសគ្នាធំៗអ្វីខ្លះក្នុងការរៀបចំថវិកា ឬការចាត់ចែងបុគ្គលិករបស់ទីភ្នាក់ងារដែលពាក់ព័ន្ធនឹងផែនការនោះ?
- តើបច្ចុប្បន្ន ទីភ្នាក់ងារនីមួយៗមានការប្ដេជ្ញាចិត្តដូចម្ដេចខ្លះចំពោះការចាត់ចែងបុគ្គលិក និងការផ្ដល់ធនធាន?

ក្នុងការកំណត់ស្ថាប័នដឹកនាំការរៀបចំកសាងផែនការ គួរគប្បីដាក់បញ្ចូលដំណើរការរៀបចំផែនការទៅក្នុង ឬទទួលបានការគាំទ្រពីក្រសួងចម្បងៗ ដូចជា ក្រសួងផែនការ ក្រសួងការពារជាតិ ក្រសួងការបរទេស ក្រសួងយុត្តិធម៌ ឬក្រសួងមហាផ្ទៃ។ ការធ្វើដូច្នេះអាចជួយធានាការគាំទ្រជាបន្តបន្ទាប់ក្នុងផ្នែកនយោបាយ និងប្រភពហិរញ្ញវត្ថុដែលចាំបាច់។

មានគម្រូផ្សេងៗសម្រាប់ការសម្របសម្រួល ដែលពាក់ព័ន្ធនឹង ១ ស្ថាប័ន ឬច្រើនស្ថាប័ន ។ ប្រមាណ ២/៣ នៃផែនការសកម្មភាពជាតិដែលមានស្រាប់ ត្រូវបានបង្កើតឡើងដោយក្រសួងចម្រុះ[42]។ ក្នុងប្រទេសមួយចំនួន ផែនការផ្ដោតលើបញ្ហាសន្តិសុខនៅក្រៅព្រំដែនរដ្ឋច្រើនតែដឹកនាំដោយក្រសួងដែលត្រួតពិនិត្យកិច្ចការក្រៅប្រទេស និងបញ្ហាដែលពាក់ព័ន្ធនឹងទំនាក់ទំនងការបរទេស។ ក្នុងប្រទេសផ្សេងទៀត ផែនការអាចផ្ដោតសំខាន់លើជម្លោះផ្ទៃក្នុង និង/ឬស្ថានភាពក្រោយពេលមានជម្លោះ។ ជាឧទាហរណ៍របស់ ប្រទេសហ្វីលីពីន ការិយាល័យទីប្រឹក្សាប្រធានាធិបតីទទួលបន្ទុកសន្តិភាព ការផ្សះផ្សារ និងសាមគ្គីភាព ដឹកនាំការរៀបចំផែនការសកម្មភាពជាតិ។ ផែនការមួយចំនួនដឹកនាំដោយក្រសួងទទួលបន្ទុកសមភាពយេនឌ័រ និងកិច្ចការនារី ដូចជាក្នុងប្រទេស ១០ នៅអាហ្វ្រិក (ប៊ូរុនឌី កូដឌីវ័រ សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ហ្គីណេ ហ្គីណេប៊ីសូ លីបេរីយ៉ា រ្វ៉ាន់ដា សេនេហ្គាល់ សៀរ៉ាឡេអូន និងអ៊ុយហ្គង់ដា)[43]។

ដោយមិនគិតពីក្រសួងដែលដឹកនាំផែនការនេះ ស្ថាប័នត្រួតពិនិត្យគួរទទួលបានការគាំទ្រគ្រប់គ្រាន់ពីរដ្ឋាភិបាល ក៏ដូចជាធនធានមនុស្ស និងហិរញ្ញវត្ថុគ្រប់គ្រាន់ និងសមត្ថកិច្ចក្នុងការសម្របសម្រួលឯកសារយុទ្ធសាស្ត្រដែលគាំទ្រ និងអនុវត្តដោយភាគីពាក់ព័ន្ធទាំងអស់។

ខាងក្រោមនេះជាគំនិតផ្ដួចផ្ដើមផ្សេងទៀតដើម្បីជួយដល់ការសម្របសម្រួល ៖

- គណៈកម្មាធិការតាមវិស័យសម្រាប់សសរស្ដម្ភនីមួយៗនៃរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលចូលរួមដោយអ្នកតំណាងដែលមានសារតាចម្រុះ
- ក្រុមការងារ និងក្រុមសម្របសម្រួលកម្រិតខ្ពស់
- លក្ខខណ្ឌយោងសម្រាប់ការសម្របសម្រួល និងរចនាសម្ព័ននៃការអនុវត្ត
- ការចាត់តាំងជាផ្លូវការមន្ត្រីបង្គោលផ្នែកស្ត្រី សន្តិភាព និងសន្តិសុខ ដែលមានអំណាចធ្វើសេចក្ដីសម្រេចផ្នែកនយោបាយ និងមកពីក្រសួងផ្សេងៗដែលចូលរួមក្នុងផែនការនេះ។

ការកំណត់រចនាសម្ព័ន្ធសម្របសម្រួល

ការសម្របសម្រួលអាចរៀបចំជា ២ កម្រិត ដូចខាងក្រោម[44]៖

កម្រិតយុទ្ធសាស្ត្រ ជាមួយនឹងស្ថាប័នកម្រិតខ្ពស់ដែលចូលរួមដោយអនុរដ្ឋមន្ត្រី/ជំនួយការរដ្ឋមន្ត្រី ឬប្រធាននាយកដ្ឋានដែលរៀបចំគោលដៅយុទ្ធសាស្ត្រ ផ្ដល់ការគាំទ្រចាំបាច់ក្នុងផ្នែកនយោបាយ ជំរុញការចូលរួមក្នុងរដ្ឋាភិបាលទាំងមូល និងដើរតួនាទីជាយន្តការគណនេយ្យភាពចម្បង។

កម្រិតប្រតិបត្តិការ ដែលចូលរួមដោយបុគ្គលិកបច្ចេកទេសដែលត្រូវបានចាត់តាំងជាមន្ត្រីបង្គោលខាងផែនការសកម្មភាពជាតិ ឬស្ត្រី សន្តិភាព និងសន្តិសុខ/យេនឌ័រ នៅក្នុងក្រសួង/នាយកដ្ឋាន/ទីភ្នាក់ងាររបស់ពួកគេ និងមានតួនាទីគ្រប់គ្រងកម្មវិធីដោយសហការជាមួយតួអង្គផ្សេងទៀត។

មធ្យោបាយមួយចំនួនសម្រាប់ការសម្របសម្រួល[45]៖

ការសម្របសម្រួលតាមខ្សែបញ្ឈរ ៖ ប្រទេសមួយចំនួន ដូចជា នីហ្សេរីយ៉ា ចាត់តាំងទីភ្នាក់ងារតែមួយប៉ុណ្ណោះឱ្យគ្រប់គ្រងការសម្របសម្រួល និងមានតួនាទីអនុវត្តសកម្មភាពផងដែរ។

ការសម្របសម្រួលតាមខ្សែផ្ដេក ៖ ការសម្របសម្រួល ធ្វើឡើងនៅក្នុងស្ថាប័នអ្នកតំណាងមកពីក្រសួងសំខាន់ៗមួយចំនួនតូច ដែលចូលរួមក្នុងការអនុវត្ត ដូចជា ក្នុងប្រទេសប៊ូស្នៀ និងហ៊ឺហ្សេហ្គោវីណា។

ការសម្របសម្រួលបែបត្រួតពិនិត្យ ៖ អង្គការសហប្រជាជាតិប្រើប្រាស់គម្រូនេះ ដែលក្រុមប្រឹក្សាសន្តិសុខជាតិជាស្ថាប័នប្រតិបត្តិមួយ ដើម្បីត្រួតពិនិត្យការអនុវត្ត។

គោលការណ៍រួមមួយគឺការបង្កើតរចនាសម្ព័ន្ធសម្របសម្រួល តាមរយៈការជំរុញការចូលរួមរបស់ក្រសួងសាមី (ប្រអប់ទី ១)។ គួរផ្ដោតការពិចារណាលើការគ្រប់គ្រងថាមវន្តរបស់អង្គការ/ស្ថាប័នដែលមានអំណាច ធនធាន និងអាណត្តិខុសៗគ្នា។ ជាទូទៅ ផែនការត្រូវបានអនុវត្តក្នុងរយៈពេល ៣-៥ ឆ្នាំ ដូច្នេះការអនុវត្តដោយជោគជ័យនឹងកំណត់ចីរភាព និងផលប៉ះដ: ជាពិសេសប្រសិនបើមានការផ្លាស់ប្ដូរថ្នាក់ដឹកនាំនយោបាយជាញឹកញាប់ ដែលអាចបង្អាក់ការប្ដេជ្ញាចិត្តផ្នែកនយោបាយ។ មន្ត្រីបង្គោល ឬតួអង្គផ្ទើមនៅក្នុងក្រសួងសាម៉ី និងទីភ្នាក់ងារពាក់ព័ន្ធ ក៏អាចជួយធានានិរន្តរភាពបានផងដែរ[46]។

## ប្រអប់ទី ១ ៖ ការបង្កើតយន្តការសម្របសម្រួលប្រកបដោយបរិយាបន្ន

ដើម្បីពង្រឹងភាពបន្សុីគ្នានៃសកម្មភាពនានានៅក្នុងផែនការសកម្មភាពជាតិទី ២ របស់ខ្លួន ថ្នាក់ដឹកនាំនៃប្រទេសប៊ូស្នៀ និងហ៊ឺហ្សេហ្គោវីណា បានបង្កើតគណៈកម្មាធិការសម្របសម្រួលជាមួយនឹងលក្ខខណ្ឌយោងច្បាស់លាស់។ គណៈកម្មាធិការនេះចូលរួមដោយអ្នកតំណាងមកពីក្រសួងទាំងអស់ដែលពាក់ព័ន្ធក្នុងការអនុវត្តផែនការនេះ។ គណៈកម្មាធិការនេះក៏ត្រូវបានបែងចែកជាកម្រិតផងដែរ គឺកម្រិតប្រតិបត្តិ (ឧ. គណៈកម្មាធិការដឹកនាំកម្រិតខ្ពស់) និងកម្រិតបច្ចេកទេស (អ្នកអនុវត្តន៍ និងអ្នកជំនាញផ្នែកបច្ចេកទេស)។

ប្រភព ៖ Lippai and Young, 2017

រូបទី ៣ រៀបរាប់សង្ខេបពីសមាសភាគសំខាន់ៗសម្រាប់ការសម្របសម្រួលផែនការដែលមានផលប៉ះដ៏ៈកម្រិតខ្ពស់[47,48]។

រូបទី ៣ ៖ ការសម្របសម្រួលផែនការដែលមានផលប៉ះពាល់កម្រិតខ្ពស់

១ បង្កើតចក្ខុវិស័យដែលជម្រុញទឹកចិត្ត

២ ជម្រុញទឹកចិត្តឱ្យអ្នកផ្សេងទទួលយកចក្ខុវិស័យនោះ

៣ គ្រប់គ្រងការអនុវត្តចក្ខុវិស័យនោះ

៤ កសាងទំនាក់ទំនងរឹងមាំប្រកបដោយការទុកចិត្ត ដើម្បីធានានិរន្តរភាពចក្ខុវិស័យនោះ

## ការសម្របសម្រួល

ការបង្កើតផែនការសកម្មភាពជាតិទាមទារភាពជាដៃគូក្នុងចំណោមតួអង្គថ្នាក់ជាតិ និងជាមួយទីភ្នាក់ងារទ្វេភាគី ទីភ្នាក់ងារថ្នាក់តំបន់ និងទីភ្នាក់ងារពហុភាគី ដែលអាចបង្កើតជាការគាំទ្រផ្នែកនយោបាយ និងហិរញ្ញវត្ថុ (ប្រអប់ទី ២)[49]។ ធនធានសំខាន់មួយគឺការបង្កើតបណ្តាញមន្ត្រីបង្គោលផ្នែកស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងឆ្នាំ ២០១៧ ដើម្បីជួយដល់រដ្ឋសមាជិកអង្គការសហប្រជាជាតិ និងអង្គការថ្នាក់តំបន់[50]។ ប្រទេសម៉ាឡេស៊ី ហ្វីលីពីន និងថៃ ជាសមាជិករបស់បណ្តាញនេះ។ បណ្តាញនេះជួយដល់ប្រទេសនានា អង្គការថ្នាក់តំបន់ និងអង្គការសហប្រជាជាតិក្នុងការដាក់បញ្ចូលការប្តេជ្ញាចិត្តជាសកលចំពោះស្ត្រី សន្តិភាព និងសន្តិសុខ ទៅក្នុងគោលនយោបាយ និងច្បាប់ជាតិ និងទទួលបានការគាំទ្រពីភ្នាក់ងារសហប្រជាជាតិ UN Women ក្នុងនាមជាលេខាធិការដ្ឋាន (សូមមើលផងដែរ ប្រអប់ទី ៣ និង ៤)។ បណ្តាញនេះដើរតួនាទីជាវេទិកាឆ្លងតំបន់សម្រាប់ចែករំលែកបទពិសោធន៍ និងការអនុវត្តល្អបំផុត បង្កើនការសម្របសម្រួលកម្មវិធីផ្តល់មូលនិធិ និងកម្មវិធីផ្តល់ជំនួយ និងជំរុញឱ្យមានលំហូរព័ត៌មានជាមួយវេទិកាពាក់ព័ន្ធ ដូចជា ក្រុមអ្នកជំនាញក្រៅផ្លូវការរបស់ក្រុមប្រឹក្សាសន្តិសុខ ទទួលបន្ទុកស្ត្រី សន្តិភាព និងសន្តិសុខ និងក្រុមមិត្តសំឡាញ់នៃស្ត្រី សន្តិភាព និងសន្តិសុខ (the Group of Friends of WPS)[51]។

### ប្រអប់ទី ២ ៖ ឧទាហរណ៍នៃកិច្ចសហការអន្តរជាតិក្នុងការបង្កើតផែនការសកម្មភាពជាតិ

មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNPF) និងភ្នាក់ងារសហប្រជាជាតិ UN Women បានគាំទ្រដល់ការរៀបចំផែនការសកម្មភាពជាតិអ៊ុយហ្គង់ដា។ ប្រទេសកូដឌីវ័រ ទទួលបានជំនួយពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ។ ក្រសួង យេនឌ័រ និងអភិវឌ្ឍន៍នៃប្រទេសលីបេរីយ៉ា បានសហការជាមួយបេសកកម្មសហប្រជាជាតិក្នុងប្រទេសលីបេរីយ៉ា ភ្នាក់ងារសហប្រជាជាតិ UN Women និងអង្គការអន្តរជាតិផ្សេងទៀត ក្នុងការរៀបចំផែនការសកម្មភាពជាតិរបស់ខ្លួន។ នៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ និងប្រទេសនេប៉ាល់ អង្គការសហប្រជាជាតិបានគាំទ្រដល់សកម្មភាពនានាដើម្បីអនុវត្តសេចក្តីសម្រេចលេខ ១៣២៥។

ប្រភព ៖ Lippai and Young, 2017

## អប់ទី ៣ ៖ តម្លៃបន្ថែមលើការចាប់ដៃគូសហការជាមួយភ្នាក់ងារសហប្រជាជាតិ UN Women

នៅកម្រិតប្រទេស អភិក្រមតាមបែបបរិយាបន្ន និងអំណាចក្នុងការកោះប្រជុំ និងអព្យាក្រឹតភាពរបស់ភ្នាក់ងារសហប្រជាជាតិ UN Women ធ្វើឱ្យអង្គការនេះអាចបំពេញអាណត្តិសម្របសម្រួល ដើម្បីគាំទ្រដល់ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ នៅកម្រិតសកល ភ្នាក់ងារសហប្រជាជាតិ UN Women បានប្រើប្រាស់តួនាទីបែបនិយាមរបស់ខ្លួន ដើម្បីដឹកនាំសកម្មភាពពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ នៅក្នុងគោលនយោបាយកម្រិតសកល និងជួយបង្កើតស្តង់ដារសម្រាប់ដំណើរការថ្នាក់ជាតិ។

ប្រភព ៖ UN Women, 2021

## ប្រអប់ទី ៤ ៖ ការចូលរួមរបស់សង្គមស៊ីវិល នៅក្នុងប្រទេសហ្សកដង់

មុនការដាក់ចេញផែនការសកម្មភាពជាតិហ្សកដង់ គណៈកម្មការជាតិដើម្បីស្ត្រីបានសហការជាមួយភ្នាក់ងារសហប្រជាជាតិ UN Women ក្នុងការរៀបចំកិច្ចការពិគ្រោះយោបល់ថ្នាក់ជាតិដើម្បីប្រមូលទស្សនៈយល់ឃើញចម្រុះស្តីពីអាទិភាពនានា។ កិច្ចពិគ្រោះយោបល់ទាំងនេះក៏មានគោលបំណងអប់រំសហគមន៍ទូទៅស្តីពីសេចក្តីសម្រេចលេខ ១៣២៥ និងគោលបំណងនៃផែនការសកម្មភាពជាតិនេះផងដែរ។ បុរស និងស្ត្រីជាង ២៥០ នាក់ដែលតំណាងឱ្យរដ្ឋាភិបាល និងសង្គមស៊ីវិល បានចូលរួមក្នុងព្រឹត្តិការណ៍ទាំងនេះ និងបានកំណត់អាទិភាព ១៤ ចំណុច។

ប្មរភព ៖ Lippai and Young, 2017

# ៧.សម្របសម្រួលការចូលរួមប្រកបដោយអត្ថន័យរបស់សង្គមស៊ីវិល ក្នុងការបង្កើត និងអនុវត្តផែនការសកម្មភាពជាតិ

ការស្ទង់មតិសមាជិកគណៈកម្មាធិការអាស៊ានដើម្បីស្ត្រីបានបញ្ជាក់ថា សង្គមស៊ីវិលដើរតួនាទីសំខាន់ក្នុងការរៀបចំផែនការ និងអនុវត្តផែនការសកម្មភាពជាតិ ជាពិសេសតាមរយៈសមត្ថភាពរបស់សង្គមស៊ីវិលក្នុងការ "ចូលដល់តំបន់ដាច់ស្រយាល និងឆ្ងាយៗ ដែលទីភ្នាក់ងាររដ្ឋាភិបាលមិនអាចចូលទៅដល់[52]" (សូមមើលប្រអប់ទី ៥)។ សេចក្តីថ្លែងការណ៍រួមគ្នារបស់រដ្ឋមន្ត្រីការបរទេសអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ កាលពីឆ្នាំ ២០១៧ ប្តេជ្ញាបង្កើនការចូលរួមប្រកបដោយអត្ថន័យរបស់អង្គការសង្គមស៊ីវិល និងបណ្តាញដែលធ្វើការងារពាក់ព័ន្ធនឹងស្ត្រី "ក្នុងការទប់ស្កាត់ គ្រប់គ្រង និងដោះស្រាយជម្លោះប្រដាប់អាវុធ និងការកសាងសន្តិភាព និងការស្តារឡើងវិញពីជម្លោះ[53]"។

ការជំរុញការចូលរួមរបស់ក្រុមទាំងនេះ ផ្អែកតាមរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលបន្តការ ខិតខំប្រឹងប្រែងទប់ស្កាត់អំពើហិង្សា ដោះស្រាយជម្លោះផ្សេងៗតាមបែបស្ថាបនា និងជួយកសាងភាពខ្លាំង និងភាពធន់របស់សហគមន៍ ដើម្បីទប់ទល់នឹងការគំរាមកំហែងដោយមនុស្ស និងធម្មជាតិចំពោះសន្តិភាព និងសន្តិសុ[54]ខ។ ក្នុងបណ្តាប្រទេសដែលមានផែនការសកម្មភាពជាតិ សង្គមស៊ីវិលដើរតួនាទីជាច្រើន ដូចជា គាំទ្រដល់ការពិគ្រោះយោបល់នៅកម្រិតមូលដ្ឋាន ដែលបានធ្វើនៅប្រទេសហ្វីលីពីន ក្នុងការរៀបចំផែនការសកម្មភាពជាតិ និងផែនការសកម្មភាពតំបន់សម្រាប់ Bangsamoro។ សង្គមស៊ីវិលជាដៃគូមួយក្នុងការអនុវត្ត ពិនិត្យតាមដាន និងធ្វើរបាយការណ៍ស្តីពីសមិទ្ធផល ក្នុងការពិនិត្យមើលតាមប្រព័ន្ធឌីជីថល (digital review) លើផែនការសកម្មភាពជាតិទី ១ ក្នុងប្រទេសឥណ្ឌូនេស៊ី។

ក្រៅពីតួអង្គបែបប្រពៃណី ដូចជា អង្គការតាមសហគមន៍ និងក្រុមស្ត្រី មានការចូលរួមកាន់តែច្រើនពីសំណាក់សង្គមស៊ីវិលផ្សេងទៀត ក្នុងផែនការសកម្មភាពជាតិ ដូចជា អង្គការធ្វើការលើជំនឿសាសនា អ្នកដឹកនាំជាយុវជន អង្គការដែលតំណាងឱ្យទស្សនៈយល់ឃើញរបស់ក្មេងស្រីក្នុងពេល និងក្រោយពេលមានជម្លោះ និងអ្នកពាក់ព័ន្ធផ្សេងទៀតដែលមានសាវតារចម្រុះ ជាពិសេសគ្រឹះស្ថានសិក្សា/ក្រុមអ្នកស្រាវជ្រាវនិងជំនាញ (think tanks) និងប្រព័ន្ធផ្សព្វផ្សាយ[55]។

សង្គមស៊ីវិលទាំងមូល អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងការយល់ដឹង និងការស្វែងរកមតិគាំទ្រសម្រាប់ផែនការសកម្មភាពជាតិ។ សង្គមស៊ីវិលអាចផ្តល់ចក្ខុវិស័យសំខាន់ៗស្តីពីឫសគល់នៃការរើសអើងផ្អែកលើ យេនឌ័រ និងផលប៉ះពាល់របស់វាមកលើស្ត្រី បុរស ក្មេងប្រុស និងក្មេងស្រី នៅក្នុងសន្តិភាព ក៏ដូចជាស្ថានភាពក្នុងពេល និងក្រោយពេលមានជម្លោះ។ ក្នុងបរិបទក្រោយពេលមានជម្លោះ ឬបរិបទអន្តរកាល ដែលជាញឹកញាប់មានការបាត់ទិន្នន័យ សង្គមស៊ីវិលអាចជាប្រភពសំខាន់ដែលផ្តល់ព័ត៌មាន និងជាដៃគូដ៏មានតម្លៃក្នុងការអនុវត្ត។ ជាមួយនឹងការលេចឡើងនៃការគំរាមកំហែងថ្មីៗផ្សេងទៀត សង្គមស៊ីវិលដើរតួនាទីកាន់តែសំខាន់ក្នុងការជួយចងក្រងក្រុមស្ត្រី ដើម្បីសម្រេចបានយុត្តិធម៌អន្តរកាល[56]។

## ប្រអប់ទី ៥ ៖ កិច្ចសហការរវាងសង្គមស៊ីវិល និងរដ្ឋាភិបាល ក្នុងប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីន

ក្នុងប្រទេសឥណ្ឌូនេស៊ី បណ្តាញសកម្មភាពមូស្លីមអាស៊ាន (ដែលជាអង្គការធ្វើការលើជំនឿសាសនា) បានសហការជាមួយរដ្ឋាភិបាល ក្រោយការបង្កើតផែនការសកម្មភាពជាតិទី ១ ដើម្បីបញ្ចប់ការពិនិត្យឡើងវិញតាមប្រព័ន្ធឌីជីថល (digital review) លើសមិទ្ធកម្មនៃផែនការនេះ។ លទ្ធផលរកឃើញបានរួមចំណែកដល់ការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុ អំពើហិង្សាជ្រុលនិយម និងជំងឺកូវីដ-១៩ ទៅក្នុងការរៀបចំផែនការទី ២។

ក្នុងប្រទេសហ្វីលីពីន ផែនការតំបន់ Bangsamoro លើកទី ២ (២០២០-២០២២) ត្រូវបានវាយតម្លៃរួមគ្នាដោយរដ្ឋាភិបាលកម្រិតតំបន់ និងសង្គមស៊ីវិល។ ផែនការនេះបានកំណត់ពីសមិទ្ធផលសំខាន់មួយចំនួន ដូចជា ការកំណត់ភាពពាក់ព័ន្ធគ្នារវាងបញ្ហាជម្លោះប្រដាប់អាវុធ និងបញ្ហាអភិបាលកិច្ច ក៏ដូចជាអំពើជួញដូរមនុស្ស និងអំពើហិង្សាលើស្ត្រី ការប្រមូលទិន្នន័យ និងការបន្តអភិវឌ្ឍសមត្ថភាពរបស់ដៃគូអនុវត្តន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត។ សេចក្តីសន្និដ្ឋានបានរួមចំណែកដល់ការបង្កើតផែនការតំបន់លើកទី ៣ (២០២៣-២០២៨) ដែលបន្សុីគ្នានឹងផែនការអភិវឌ្ឍន៍តំបន់។

ប្រភព ៖ ក្រសួងបង្កើនភាពអង់អាចរបស់ស្ត្រី និងការពារកុមារ ២០២២ ការិយាល័យរដ្ឋមន្ត្រីប្រចាំតំបន់ ២០២៣

ចំណុចសំខាន់ៗ ៖

> សង្គមស៊ីវិលអាចផ្តល់សេវាជាច្រើនដល់ការអនុវត្តផែនការសកម្មភាពជាតិ ដូចជាការច្បាមយកតថភាពផ្សេងៗទៅតាមបរិបទជាក់លាក់ ដែលជួយដល់ការកៀរគរការគាំទ្រ និងនាំឱ្យមានការទទួលយកក្នុងចំណោមស្ថាប័នពាក់ព័ន្ធយ៉ាងច្រើន (នៅកម្រិតអន្តរជាតិ កម្រិតជាតិ កម្រិតក្រោមជាតិ និងកម្រិតមូលដ្ឋាន) ការកសាងសមត្ថភាពក្នុងការអនុវត្ត ការរួមចំណែកដល់យុទ្ធនាការរៃអង្គាសមូលនិធិ និងការគាំទ្រការពិនិត្យតាមដាន និងវាយតម្លៃដើម្បីជួយដល់រដ្ឋាភិបាលក្នុងការពិចារណាឡើងវិញលើអាទិភាពជាតិ ចេញពីទស្សនៈយេនឌ័រ។

## ៨.កំណត់ចំណុចសំខាន់ៗសម្រាប់ការបន្សុីគោលនយោបាយ ក្របខណ្ឌកម្រិតសកល និងក្របខ័ណ្ឌកម្រិតតំបន់ ដែលមានស្រាប់ ទៅនឹងផែនការសកម្មភាពជាតិ

ផែនការសកម្មភាពជាតិដ៏ជោគជ័យ ត្រូវផ្អែកលើការយល់ដឹងស៊ីជម្រៅអំពីគោលនយោបាយជាតិ និងលិខិតុបករណ៍ពាក់ព័ន្ធ ដើម្បីសម្រួលដល់ការដាក់បញ្ចូលកម្មវិធីស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ក៏ដូចជាការបន្សុីគ្នាទៅនឹងអាទិភាពអភិវឌ្ឍន៍ជាតិ និងក្របខណ្ឌតំបន់ និងក្របខណ្ឌសកល[57]។ ផែនការទាំងឡាយគួរពង្រឹងការផ្សារភ្ជាប់នឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដើម្បីជំរុញការគាំទ្រផ្នែកនយោបាយ និងនិរន្តរភាពយូរអង្វែង ដែលអាចជួយទ្រទ្រង់ផ្នែកហិរញ្ញវត្ថុ។ ប្រអប់ទី ៦ បង្ហាញពីចំណុចសំខាន់ៗសម្រាប់ការបន្សុីគ្នា។ រូបទី ៤ សង្ខេបពីផ្នែកគោលនយោបាយដែលតែងលេចឡើងជាច្រើនលើកច្រើនសារ នៅក្នុងផែនការសកម្មភាពជាតិ[58]។

ប្រអប់ទី ៦ ៖ ចំណុចសំខាន់ៗសម្រាប់ការបន្សុីជាមួយគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រដែលមានស្រាប់

| ការការពារសិទ្ធិរបស់ស្ត្រី និងក្មេងស្រី | ការចូលរួម និងភាពជាតំណាង |
|---|---|
| ប្រព័ន្ធច្បាប់ ប្រព័ន្ធតុលាការ និងប្រព័ន្ធរដ្ឋធម្មនុញ្ញ | កម្មវិធីមនុស្សធម៌ |
| ប្រព័ន្ធសម្រាប់ធានាសន្តិសុខ និងការការពាររូបរាងកាយ | ការចរចាដំណោះស្រាយជម្លោះ (ផ្លូវការ និងក្រៅផ្លូវការ) និងកិច្ចព្រមព្រៀងសន្តិភាព |
| សិទ្ធសង្គម-សេដ្ឋកិច្ច (ដីធ្លី ទ្រព្យសម្បត្តិ ការអប់រំ អក្ខរកម្មសន្តិសុខសេដ្ឋកិច្ច សុខភាពបឋម) | ការរួមចំណែករបស់ជាតិដល់បុគ្គលិករក្សាសន្តិភាព (កងកម្លាំងឯកសណ្ឋាន និងបុគ្គលិកស៊ីវិល) |
| ការប្រឆាំងអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹង យេនឌ័រ | ដំណើរការបោះឆ្នោត ដូចជា ភាពជាតំណាងរបស់ស្ត្រីនៅក្នុងគណបក្សនយោបាយ នៅមុនពេល និងក្រោយពេលបោះឆ្នោត |
| សុខភាពមាតា និងសុខភាពបន្តពូជ | រចនាសម្ព័ន្ធអំណាចដែលមានសម្រាប់ ក្នុងអំឡុងពេលអន្តរកាលក្រោយពេលមានជម្លោះ |
| ការប្រឆាំងជំងឺអេដស៍/មេរោគអេដស៍ | នីតិរដ្ឋ និងស្ថាប័នអភិបាលកិច្ចបែបប្រជាធិបតេយ្យ |

| ការទប់ស្កាត់ | ការសង្គ្រោះ និងស្តារឡើងវិញ |
|---|---|
| យុត្តិធម៌ និងមាតុភូមិនិវត្តន៍ រួមទាំងយុត្តិធម៌អន្តរកាល | ការវាយតម្លៃដែលគិតគូពីយេនឌ័រ នៅក្រោយពេលមានជម្លោះ |
| កំណែទម្រង់វិស័យសន្តិសុខ លក្ខខណ្ឌតម្រូវផ្អែកតាមយេនឌ័រ | ការវិភាគថវិកាយេនឌ័រ ក្នុងការចំណាយក្រោយពេលមានជម្លោះ ដើម្បីអាចឱ្យមានការតាមដានធនធានដែលត្រូវបានបែងចែកសម្រាប់លើកកម្ពស់សមភាពយេនឌ័រ ឬការបង្កើនភាពអង់អាចដល់ស្ត្រី |
| កំណែទម្រង់យុត្តិធម៌ លក្ខខណ្ឌតម្រូវផ្អែកតាមយេនឌ័រ | សមភាពយេនឌ័រ ក្នុងការបែងចែកភាគលាភសន្តិភាព ដូចជា ការវិនិយោគធំៗលើកម្មវិធីការងារ ឬសេវាសាធារណៈ សំខាន់ៗ ក្នុងការស្តារឡើងវិញក្រោយជម្លោះ |
| វប្បធម៌សន្តិភាពថ្មី ដោយផ្អែកលើការរួមចំណែករបស់ស្ត្រី និងជម្រុញបន្ថែមសមភាពយេនឌ័រ | ការធ្វើបរិយាបន្នប្រកបដោយប្រសិទ្ធភាពរបស់ កងជីវពលជាស្ត្រី ឬស្ត្រីដែលពាក់ព័ន្ធក្នុងកងកម្លាំងប្រយុទ្ធ ទៅក្នុងកម្មវិធីរំសាយអាវុធ កម្មវិធីរំសាយកងទ័ព និងកម្មវិធីសមា ហរណកម្ម |
| ប្រព័ន្ធប្រកាសព័ត៌មានឱ្យដឹងមុនពីជម្លោះដែលគិតគូរពី យេនឌ័រ | កម្មវិធីធ្វើមាតុភូមិនិវត្តន៍ |
| កម្មវិធីអប់រំតាមសាលា និងស្ថាប័នផ្សេងទៀតស្តីពីបញ្ហា យេនឌ័រ ការកសាងសន្តិភាព និងការដោះស្រាយជម្លោះ | |
| ការកសាងការយល់ដឹងរបស់សាធារណជនស្តីពីបញ្ហាសន្តិសុខដែលផ្អែកតាមយេនឌ័រ | |

## ៩.ជ្រើសរើសសកម្មភាពអាទិភាព ដោយផ្អែកតាមសមាសភាគសំខាន់ៗនៃផែនការសកម្មភាពជាតិដែលផ្តល់ផលជះកម្រិតខ្ពស់

ការជ្រើសរើសសកម្មភាពអាទិភាពសម្រាប់ផែនការជាតិ គួរផ្អែកតាមការវិភាគល្អិតល្អន់លើកម្មវិធីនានា ដោយផ្សារភ្ជាប់នឹងអាទិភាពជាតិ និងលិខិតុបករណ៍អន្តរជាតិ និងលិខិតុបករណ៍ថ្នាក់តំបន់ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ដំណើរការជ្រើសរើសសកម្មភាពអាទិភាព ចេញពីការប្រមូលព័ត៌មាន ពីការរៀបចំសិក្ខាសាលាកសាងការយល់ដឹង និងកិច្ចសន្ទនាបញ្ជ្រាបការយល់ដឹងជាមួយភាគីពាក់ព័ន្ធសំខាន់ៗ និងការវិភាគស្ថានភាព ដែលមានការផ្តួចផ្តើម

ការវិភាគបរិបទអាចជាកត្តាសំខាន់ក្នុងការចាប់ផ្តើមដំណើរការកំណត់អាទិភាពយុទ្ធសាស្ត្រសម្រាប់ផែនការសកម្មភាពជាតិ[59]។ ក្រៅពីនេះ ការវិភាគអាចផ្តល់ជាទិន្នន័យដើមគ្រាដែលអាចវាស់វែងបាន ដូចជា តាមរយៈការកំណត់រក និងការបង្កើតសូចនាករដាក់លាក់ស្តីពីបទពិសោធន៍របស់ស្ត្រីនៅក្នុងជម្លោះ និងការរួមចំណែកដល់ការដោះស្រាយជម្លោះ។ រូបទី ៤ រៀបរាប់ពីចំណុចអាទិភាពជាតិមួយចំនួនដែលត្រូវបានលើកឡើងជាច្រើនលើកច្រើនសារនៅក្នុងផែនការសកម្មភាពជាតិដែលមានស្រាប់[60]។

## រូបទី ៤ ៖ ចំណុចអាទិភាពមួយចំនួនដែលត្រូវបានលើកឡើងជាច្រើនលើកច្រើនសារនៅក្នុងផែនការសកម្មភាពជាតិដែលមានស្រាប់




ផែនការសកម្មភាពតំបន់អាស៊ានមានសកម្មភាពអាទិភាព ៤ ដែលគ្របដណ្តប់លើសសរស្តម្ភសំខាន់ៗនៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ៖ ការការពារ ការចូលរួម ការទប់ស្កាត់ និងការសង្គ្រោះនិងស្តារឡើងវិញ។ សសរស្តម្ភនីមួយៗមានលទ្ធផលចុងក្រោយមួយ លើកលែងតែសសរស្តម្ភ "ការទប់ស្កាត់" ដែលមានលទ្ធផលចុងក្រោយ ២ ស្តីពីការដាក់បញ្ចូលស្ត្រីឱ្យបានពេញលេញទៅក្នុងគំនិតផ្តួចផ្តើមទប់ស្កាត់ការគំរាមកំហែងចំពោះសន្តិភាព និងសន្តិសុខ និងការទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ លទ្ធផលចុងក្រោយទី ៦ ផ្តោតលើការអនុវត្ត ការសម្របសម្រួល ការធ្វើរបាយការណ៍ ការពិនិត្យតាមដាន និងការវាយតម្លៃ។

សសរស្តម្ភទាំង ៤ មានលទ្ធផលក្នុងឆ្នាំចំនួន ១៤[61]និងសកម្មភាពអាទិភាពចំនួន ៧៨។ ការវាយតម្លៃហ័សលើលទ្ធផលចុងក្រោយ លទ្ធផលក្នុងឆ្នាំ និងសកម្មភាពដែលជាក់លាក់ទៅតាម ប្រទេសនីមួយៗ និងព័ត៌មានដែលប្រមូលបានពីការស្ទង់មតិ បូករួមនឹងការជ្រើសរើសជាគុផ្សំមួយចំនួនចេញពីសមាសភាគសំខាន់ៗទាំង ៦ នៃផែនការសកម្មភាពជាតិដែលបង្កផលជះកម្រិតខ្ពស់ អាចជួយដល់ការកំណត់សកម្មភាពអាទិភាព ដោយផ្អែកតាម បរិបទប្រទេស[62]។

តារាងទី ៧ បង្ហាញពីសមាសភាគទាំង ៦ នៃផែនការសកម្មភាពជាតិដែលបង្កផលជះកម្រិតខ្ពស់ អមជាមួយនឹងលក្ខខណ្ឌតម្រូវ។ តារាងទី ៨ អាចជួយដល់រដ្ឋសមាជិកអាស៊ានក្នុងការជ្រើសរើសសកម្មភាពអាទិភាពសម្រាប់ផែនការជាតិ ជាមួយនឹងការកែសម្រួលឱ្យស្របទៅតាមបរិបទជាតិ។

## តារាងទី ៧ ៖ សមាសភាគទាំង ៦ នៃផែនការសកម្មភាពជាតិដែលបង្កផលជះកម្រិតខ្ពស់

| ឆន្ទៈនយោបាយ | ការរៀបចំ | ការសម្របសម្រួល | សង្គមស៊ីវិល | ការពិនិត្យតាមដាន និងវាយតម្លៃ | ថវិកា និងហិរញ្ញប្បទាន |
|---|---|---|---|---|---|
| ថ្នាក់ដឹកនាំយល់ដឹងអំពីសេចក្តីសម្រេចលេខ ១៣២៥ យល់ថា សេចក្តីសម្រេចនេះជួយពង្រីកគោលដៅជាតិ មើលឃើញថាស្ត្រីជាភ្នាក់ងារនៃការផ្លាស់ប្តូរ និងចាត់វិធានការ (នៅកម្រិតខ្ពស់) ដើម្បីពន្លឿនរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ តាមរយៈការអនុវត្ត (នៅកម្រិតបច្ចេកទេស) ផែនការសកម្មភាពជាតិ។ | ផែនការសកម្មភាពជាតិគាំទ្រដោយក្របខណ្ឌគំរូតក្កភាព (ឡុកហ្វ្រេម) ដែលរៀបរាប់ពីលទ្ធផលចុងក្រោយជាក់លាក់ដែលបន្សីគ្នានឹងសេចក្តីសម្រេចលេខ ១៣២៥ និងយុទ្ធសាស្ត្រ និងគោលនយោបាយដែលមានស្រាប់ (ដូចជា យុទ្ធសាស្ត្រសន្តិសុខជាតិ) និងត្រូវបានបង្កើតឡើងតាមរយៈដំណើរការប្រកបដោយបរិយាបន្ន និងជំរុញដោយភាគីពាក់ព័ន្ធ (ឧ.ការពិគ្រោះយោបល់ជាមួយអ្នកដឹកនាំក្នុងមូលដ្ឋាន និង អ្នកទទួលផល នៅថ្នាក់ក្រោមជាតិ)។ | តួនាទី និងការទទួលខុសត្រូវ ត្រូវបានកំណត់ច្បាស់ក្នុងស្ថាប័នសម្របសម្រួលផែនការសកម្មភាពជាតិ។ សមាជិករបស់ស្ថាប័ននោះចែករំលែកការប្តេជ្ញាចិត្តដោយផ្អែកតាមបេសកកម្មចំពោះគោលបំណងរយៈពេលវែង ហើយស្ថាប័ននោះមានយន្តការមួយសម្រាប់រក្សាការទទួលខុសត្រូវរបស់អ្នកអនុវត្តន៍ (ឧ. មុខងារត្រួតពិនិត្យ)។ | សង្គមស៊ីវិលមានភាពជាតំណាងសមស្រប នៅក្នុងដំណើរការរៀបចំ អនុវត្ត ពិនិត្យតាមដាន និងវាយតម្លៃ។ | មានផែនការ ឧបករណ៍ និងប្រព័ន្ធជាស្រេចសម្រាប់ប្រមូល វិភាគ និងរាយការណ៍ទិន្នន័យ។ ព័ត៌មានទាំងនេះត្រូវបានប្រើប្រាស់សម្រាប់ការកែលម្អសមិទ្ធផល និងអប់រំភាគីពាក់ព័ន្ធស្តីពីវឌ្ឍនភាពនៃផែនការសកម្មភាពជាតិ និងផលជះ។ | ផែនការសកម្មភាពជាតិ ត្រូវមាន កញ្ចប់ថវិកាសម្រាប់ធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានបច្ចេកទេសដែលចាំបាច់សម្រាប់ការអនុវត្តសកម្មភាពទាំងអស់ដែលមានរៀបរាប់ក្នុងយុទ្ធសាស្ត្រនេះ។ |

ប្រភព ៖ Lippai and Young, 2017.

## តារាងទី ៨ ៖ ការជ្រើសរើសសកម្មភាពអាទិភាពសម្រាប់ផែនការសកម្មភាពជាតិ

| អាទិភាពអភិវឌ្ឍន៍ជាតិ (ច្បាប់ និងគោលនយោបាយ) | ចំណុចសំខាន់ៗក្នុងសសរស្តម្ភទាំង ៤ នៃរបៀបវារៈស្ត្រី<br>សន្តិភាព និងសន្តិសុខ | សកម្មភាពអាទិភាពក្នុងផែនការសកម្មភាពជាតិដែលពាក់ព័ន្ធនឹងបរិបទជាតិ | ធាតុផ្សំពាក់ព័ន្ធក្នុងផែនការសកម្មភាពជាតិដែលបង្កផលជះកម្រិតខ្ពស់ | ចំណុចអាទិភាពដែលត្រូវបានជ្រើសរើសសម្រាប់ផែនការសកម្មភាពជាតិ |
|---|---|---|---|---|
| ការការពារ | | | | សកម្មភាពអាទិភាពទី១ ៖ ការការពារ |
| | | | | សកម្មភាព |
| ការចូលរួម | | | | សកម្មភាពអាទិភាពទី២ ៖ ការចូលរួម |
| | | | | សកម្មភាព |
| ការទប់ស្កាត់ | | | | សកម្មភាពអាទិភាពទី៣ ៖ ការទប់ស្កាត់ |
| | | | | សកម្មភាព |
| ការសង្គ្រោះ និងស្តារឡើងវិញ | | | | សកម្មភាពអាទិភាពទី៤ ៖ ការសង្គ្រោះ និងស្តារឡើងវិញ |
| | | | | សកម្មភាព |
| ការគំរាមកំហែងដែលកំពុងលេចឡើងក្នុងប្រទេសនីមួយៗ ៖ អំពើហិង្សាជ្រុលនិយម គ្រោះមហន្តរាយដែលបង្កឡើងដោយអាកាសធាតុ និងការបណ្តេញចេញដោយបង្ខំ អំពើជួញដូរមនុស្ស។ល។ | | | | សកម្មភាពអាទិភាពទី ៖ សកម្មភាព ៖ |

# ១០.ធានាតម្លាភាព និងគណនេយ្យភាព

គណនេយ្យភាព និងតម្លាភាពក្នុងការបង្កើត និងអនុវត្តផែនការសកម្មភាពជាតិ គឺសំខាន់ណាស់ ព្រោះវាទាមទារឱ្យមានការតាមដានជាប្រចាំដើម្បីកំណត់កេចន្លោះប្រហោង និងធ្វើការផ្លាស់ប្តូរនានា។ ខាងក្រោមនេះជាសំណួរសំខាន់ៗមួយចំនួន[63]៖

- តើគោលការណ៍គណនេយ្យភាព និងតម្លាភាពត្រូវបានបញ្ជ្រាបកម្រិតណាទៅក្នុងការរៀបចំផែនការ និងការអនុវត្តផែនការសកម្មភាពជាតិ?
- តើអន្តរាគមន៍ដើម្បីសម្រេចបានអាទិភាពរួមនៃគោលនយោបាយជាតិ ក៏ដូចជាផែនការសកម្មភាពតំបន់អាស៊ាន ត្រូវបានអនុវត្តប្រកបដោយតម្លាភាព និងគណនេយ្យភាពក្នុងកម្រិតណា?
- តើអ្វីខ្លះជាគម្លាតធំៗដែលត្រូវដោះស្រាយ? តើផ្នែកណាខ្លះទាមទារការពន្លឿនបន្ថែម?

ការរក្សាគណនេយ្យភាពកម្រិតខ្ពស់ ទាមទារការអនុវត្តជាមួយភាគីពាក់ព័ន្ធផ្សេងៗនៅកម្រិតខុសៗគ្នា[64]៖

- ខ្សែផ្តេក ៖ ការជំរុញការចូលរួមរបស់ប្រជាជនដែលរងផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលដោយសារសកម្មភាពក្នុងផែនការ
- ផ្តោតមកខាងក្នុង ៖ គណនេយ្យភាពចំពោះសមាជិកក្រុមទទួលបន្ទុកផែនការសកម្មភាពជាតិ
- ផ្តោតទៅខាងក្រៅ ៖ គណនេយ្យភាពចំពោះប្រជាជនក្នុងសហគមន៍ ដែលពាក់ព័ន្ធនឹងកិច្ចខិតខំប្រឹងប្រែងស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ
- ផ្តោតទៅខាងលើ ៖ ធ្វើរបាយការណ៍ទៅក្រសួង/ទីភ្នាក់ងាររដ្ឋាភិបាលដែលទទួលខុសត្រូវលើការអនុវត្តផែនការសកម្មភាពតំបន់អាស៊ាន ឬម្ចាស់ជំនួយដែលបានផ្តល់ធនធាន។

ការបញ្ជ្រាបតម្លាភាពទៅក្នុងផែនការសកម្មភាពជាតិ ទាមទារភាពច្បាស់លាស់ និងភាពបើកចំហរស្តីពីសកម្មភាព គោលបំណង និងហិរញ្ញវត្ថុ និងការគ្រប់គ្រងក្តីរំពឹងទុកចំពោះសមិទ្ធផល។ ការបែងចែក និងប្រើប្រាស់ធនធានប្រកបដោយសមធម៌ ប្រសិទ្ធភាព និងប្រសិទ្ធផល ជួយបង្កើនភាពស្របច្បាប់ និងតម្លៃនៃការចំណាយ (value for money)[65]។ ខាងក្រោមនេះជាសកម្មភាពមួយចំនួនសម្រាប់បង្កើនគណនេយ្យភាព និងតម្លាភាព[66]៖

- ផ្តល់ព័ត៌មានពិស្តារស្តីពីរបៀប ទីកន្លែង និងគោលបំណងដែលផែនការនោះប្រើប្រាស់ធនធានរបស់ខ្លួនដើម្បីធានាតម្លៃនៃការចំណាយ (value for money)
- បង្កើតក្របខណ្ឌសមិទ្ធផលដោយផ្អែកលើភស្តុតាង
- បង្កើតមធ្យោបាយច្បាស់លាស់សម្រាប់ធ្វើរបាយការណ៍ទៀតទាត់ ដោយផ្អែកលើទិដ្ឋភាពរួមរបស់កម្មវិធី
- គាំទ្រការអភិវឌ្ឍសមត្ថភាពសម្រាប់មន្ត្រីអនុវត្តន៍ ក្នុងការអនុលោមតាមលក្ខខណ្ឌតម្លាភាព និងគណនេយ្យភាព
- ធានាថា ផែនការពិនិត្យតាមដាន និងវាយតម្លៃ និងបុគ្គលិកអាចធ្វើការវាយតម្លៃដោយមិនលម្អៀងលើការអនុវត្តផែនការ និងផ្តល់ការធានាអះអាងដល់អាជ្ញាធរមានសមត្ថកិច្ច។

## ចំណុចសំខាន់ៗ ៖

ការដាក់បញ្ចូលគណនេយ្យភាព និងតម្លាភាពទៅក្នុងការអនុវត្តផែនការសកម្មភាពជាតិ ទាមទារការកំណត់ច្បាស់ពីការទទួលខុសត្រូវ និងសមត្ថកិច្ចក្នុងចំណោមដៃគូអនុវត្តន៍។ ចំណុចទាំងនេះត្រូវកំណត់ឡើងតាំងពីដំណាក់កាលដំបូង ដើម្បីធានាការត្រួតពិនិត្យជាប់ជាប្រចាំ។ ធាតុផ្សំសំខាន់ៗផ្សេងទៀត គឺការបញ្ជ្រាបវប្បធម៌សុចរិតភាព និងការធ្វើសេចក្តីសម្រេចប្រកបដោយការទទួលខុសត្រូវ តាំងពីដំណាក់កាលរៀបចំផែនការ រួមជាមួយនឹងប្រព័ន្ធច្បាស់លាស់សម្រាប់វាស់វែង និងវាយតម្លៃការអនុវត្តការងារ។

អភិក្រមដែលលក្ខណៈជាក់ស្តែង និងអាចអនុវត្តបាន ក៏មានសារៈសំខាន់ដូចគ្នា សម្រាប់ការបង្កើត និងអនុវត្តការវាស់វែងការអនុវត្តការងារឱ្យបានគ្រប់ជ្រុងជ្រោយ។ សកម្មភាពនេះអាចត្រូវការពេលវេលា និងដំណើរការមួយដើម្បីជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ និងដៃគូចម្រុះ ដូចជា ការគាំទ្រដល់ការកសាងសមត្ថភាពរយៈពេលមធ្យម និងរយៈពេលវែង ដើម្បីធានាភាពម្ចាស់ការ និងកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការបង្កើនការប្រមូលទិន្នន័យ ការធ្វើរបាយការណ៍ និងការវិភាគលើវឌ្ឍនភាពក្នុងការអនុវត្ត។

ជំហានទី ២

# ការធ្វើសេចក្តីពង្រាងផែនការសកម្មភាពជាតិ

ក្រោយការប្រមូលទិន្នន័យនិងព័ត៌មានក្នុងជំហានទី ១ ជំហានទី ២ ផ្តោតសំខាន់លើការចងក្រងព័ត៌មាន ពិស្តារសម្រាប់ការព្រាងផែនការសកម្មភាពជាតិ។ ជំហាននេះជាមូលដ្ឋានកំណត់គុណភាពនៃផែនការ ព្រោះវាដោះស្រាយបញ្ហាសំខាន់ៗ ដូចជា ការជ្រើសរើសសមាជិគណៈកម្មាធិការសម្រាប់ធ្វើសេចក្តីពង្រាងផែនការ ដោយធានាថាពួកគេតំណាងឱ្យស្ថាប័ន/អង្គការចម្រុះ។ វាក៏ជាដំណើរការព្រាងផែនការប្រកបដោយបរិយាបន្ន ដោយធ្វើការបន្សុីផែនការសកម្មភាពជាតិទៅនឹងផែនការសកម្មភាពតំបន់អាស៊ាន និងសកម្មភាពសំខាន់ៗសម្រាប់ការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនេះ ក៏ដូចជាសមាសភាគសំខាន់ៗ ២ នៃការពិនិត្យតាមដាន និងវាយតម្លៃ និងការគណនាចំណាយលើសកម្មភាពក្រោមផែនការសកម្មភាពជាតិ សម្រាប់ជាមូលដ្ឋាននៃការអនុវត្តប្រកបដោយប្រសិទ្ធភាព។

## ១.បង្កើតគណៈកម្មាធិការ ឬក្រុមការងារ ដើម្បីចាប់ផ្តើមពង្រាងផែនការសកម្មភាពជាតិ

ការបង្កើតផែនការសកម្មភាពជាតិដែលប្រកបដោយប្រសិទ្ធភាព អាស្រ័យលើការជំរុញការចូលរួមរបស់តំណាងមកពីក្រសួងពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល។ ក្នុងជំហានទី ២ គណៈកម្មាធិការ ឬក្រុមការងារធ្វើសេចក្តីពង្រាងផែនការ គួរកៀរគរតួអង្គដែលអាចប្រមូលផ្តុំចំណាប់អារម្មណ៍ លើកកម្ពស់ការយល់ដឹង និងដឹកនាំដំណើរការជារួម។ គណៈកម្មាធិការ ឬក្រុមការងារនេះ អាចរួមបញ្ចូលបុគ្គលដែលទទួលខុសត្រូវលើការកសាងធនូះនយោបាយពីមុនសម្រាប់ផែនការសកម្មភាពជាតិ និងអ្នកដែលមានបទពិសោធន៍ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ។

រដ្ឋាភិបាលមួយចំនួនអាចជួលអ្នកជំនាញផ្នែកស្ត្រី សន្តិភាព និងសន្តិសុខ ឱ្យគាំទ្រដល់ដំណើរការនេះ។ ឧទាហរណ៍ពីប្រទេសលីបេរីយ៉ា រដ្ឋាភិបាលពឹងផ្អែកលើជំនួយបច្ចេកទេសរបស់ភ្នាក់ងារសហប្រជាជាតិ UN Women ដើម្បីព្រាងផែនការសកម្មភាពជាតិលើកទី ២ របស់ខ្លួន។ ជាទូទៅ ក្រុមការងារដែលសម្របសម្រួលការពង្រាងផែនការនេះ ក្លាយជាក្រុមដែលគាំទ្រការអនុវត្ត ការពិនិត្យតាមដាន និងការវាយតម្លៃ។

សមាជិកគណៈកម្មាធិការធ្វើសេចក្តីពង្រាងផែនការ គួរ[67]៖

- យល់ច្បាស់ពីបញ្ហាសំខាន់ៗដែលពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ និងអាទិភាពជាតិដែលពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ ដើម្បីពន្លឿនចំណុចទាំងនេះក្នុងពេលតែមួយ
- តំណាងឱ្យស្ថាប័ន/អង្គការផ្សេងៗមកពីរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ សង្គមស៊ីវិល និងស្ថាប័នផ្សេងទៀតដែលមានបទពិសោធន៍ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ និងមានជំនាញក្នុងការវាយតម្លៃសកម្មភាពថ្នាក់ជាតិ។

គណៈកម្មាធិការធ្វើសេចក្តីពង្រាងផែនការ អាចចូលរួមដោយសមាសភាគតិច ឬច្រើន ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១ | តំណាងរដ្ឋាភិបាល | • មកពីក្រសួង ឬនាយកដ្ឋានពាក់ព័ន្ធ ដូចជា ការបរទេស ការពារជាតិ យុត្តិធម៌ មហាផ្ទៃ និងហិរញ្ញវត្ថុ<br>• មន្ត្រីបង្គោល ឬអ្នកជំនាញយេនឌ័រ នៅក្នុងជួររដ្ឋាភិបាល |
| ២ | អង្គការសង្គមស៊ីវិល | • តំណាងមកពីអង្គការសិទ្ធិស្ត្រី<br>• អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារពាក់ព័ន្ធនឹងយេនឌ័រ និងសន្តិភាព<br>• តំណាងមកពីអង្គការដែលផ្តោតលើទិដ្ឋភាពជាក់លាក់នៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដូចជា ការទប់ស្កាត់ជម្លោះ ឬការកសាងឡើងវិញក្រោយពេលមានជម្លោះ |
| ៣ | គ្រឹះស្ថានសិក្សា | • អ្នកជំនាញខាងការសិក្សាយេនឌ័រ ឬអ្នកស្រាវជ្រាវដែលមានចំណេះដឹងផ្នែកការសិក្សាស្តីពីជម្លោះ និងសន្តិភាព |
| ៤ | ស្ថាប័នអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិ | • តំណាងមកពីភ្នាក់ងារសហប្រជាជាតិ UN Women និង/ឬស្ថាប័នពាក់ព័ន្ធផ្សេងទៀតរបស់អង្គការសហប្រជាជាតិ<br>• អ្នកជំនាញមកពីអង្គការអន្តរជាតិដែលមានបទពិសោធន៍លើបញ្ហាជម្លោះ និង យេនឌ័រ។ |
| ៥. | អ្នកដឹកនាំសហគមន៍ | • តំណាងមកពីអង្គការសហគមន៍តាមមូលដ្ឋាន ឬអ្នកដឹកនាំដែលមានបទពិសោធន៍ក្នុងមូលដ្ឋាននៅតាមតំបន់ដែលរងផលប៉ះពាល់ដោយសារជម្លោះ |

| | | |
|---|---|---|
| ៦ | តំណាងយុវជន | • អង្គការយុវជន ឬអ្នកស្វែងរកមតិគាំទ្រដែលផ្តោតសំខាន់លើសន្តិភាព និងសន្តិសុខ |
| ៧ | ក្រុមជនជាតិដើម និងក្រុមភាគតិច | • តំណាងមកពីសហគមន៍ជនជាតិដើម ឬជនជាតិភាគតិច ដើម្បីធានាការពិចារណាពីទស្សនៈវិស័យ និងតម្រូវការរបស់ពួកគេ |
| ៨ | អ្នកជំនាញផ្នែកច្បាប់ និងសិទ្ធិមនុស្ស | • មានចំណេះដឹងផ្នែកច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងយន្តការដែលពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ |
| ៩ | តំណាងប្រព័ន្ធផ្សព្វផ្សាយ | • អ្នកសារព័ត៌មាន ឬអ្នកជំនាញប្រព័ន្ធផ្សព្វផ្សាយ ដើម្បីសម្របសម្រួលការផ្សព្វផ្សាយ និងការកសាងការយល់ដឹង |
| ១០ | អ្នកជំនាញយេនឌ័រ | • ផ្តល់ជំនាញផ្នែកបច្ចេកទេសស្តីពីការបញ្ជ្រាបយេនឌ័រ និងការរៀបចំកម្មវិធីដែលឆ្លើយតបនឹងយេនឌ័រ ដូចជា តំណាងរបស់អង្គការដែលធ្វើការងារពាក់ព័ន្ធនឹងការដាក់បញ្ចូលទស្សនៈវិស័យរបស់ក្មេងស្រីទៅក្នុងស្ថានភាពក្រោយជម្លោះ។ |
| ១១ | អ្នកជំនាញខាងដោះស្រាយជម្លោះ និងកសាងសន្តិភាព | • អ្នកជំនាញខាងដោះស្រាយជម្លោះ កសាងសន្តិភាព និងទប់ស្កាត់ជម្លោះ |
| ១២ | ជនមានពិការភាព | • តំណាងមកពីអង្គការនានា ឬអ្នកស្វែងរកមតិគាំទ្រដែលផ្តោតសំខាន់លើការដាក់បញ្ចូលជនមានពិការភាពទៅក្នុងកិច្ចខិតខំប្រឹងប្រែងស្តីពីសន្តិភាព និងសន្តិសុខ |
| ១៣ | អ្នកដឹកនាំក្រុមជាតិពន្ធ និងអ្នកដឹកនាំសាសនា | • មកពីក្រុមជាតិពន្ធ និងក្រុមសាសនាចម្រុះ ដើម្បីបង្កើនបរិយាបន្ន និងការអត់ ឱនក្នុងសាសនាទៅក្នុងដំណើរការសន្តិភាព |
| ១៤ | តំណាងយុវជន និងតំណាងយេនឌ័រ | • យុវជនទាំងពីរភេទ ដែលមានជំនាញ ឬបទពិសោធន៍ក្នុងការស្វែងរកមតិគាំទ្រ ពាក់ព័ន្ធនឹងបញ្ហាយេនឌ័រ និងយុវជន។ |
| ១៥ | អ្នកជំនាញឯករាជ្យ | • បុគ្គលដែលមានជំនាញខាងយេនឌ័រ ជម្លោះ និងការកសាងសន្តិភាព ដែលអាច ផ្តល់ការណែនាំដោយមិនលម្អៀង។ |

## រូបទី ៥ ៖ សមាសភាគរបស់គណៈកម្មាធិការធ្វើសេចក្តីព្រាងផែនការ




គណៈកម្មាធិការធ្វើសេចក្តីព្រាងផែនការ គួរចាត់តាំងអ្នកសម្របសម្រួលម្នាក់ និងស្ថាប័នពាក់ព័ន្ធឱ្យដឹកនាំកិច្ចការដាក់លាក់ដែលពាក់ព័ន្ធនឹងការរៀបចំផែនការសកម្មភាពជាតិ[68]។ គណៈកម្មាធិការនេះនឹងកំណត់ពីរបៀបទទួលយោបល់ត្រឡប់ផ្ទៃក្នុង និងយោបល់ត្រឡប់ខាងក្រៅ ពីអ្នកជំនាញ និងភាគីពាក់ព័ន្ធដែលនឹងត្រូវបានដាក់បញ្ចូលទៅក្នុងឯកសារនេះ។ រូបទី ៦ បង្ហាញពីធាតុផ្សំចំនួន ៧ នៃផែនការសកម្មភាពជាតិដែលប្រកបដោយនវានុវត្តន៍[69,70]។

## រូបទី ៦ ៖ ធាតុផ្សំនៃផែនការសកម្មភាពជាតិដែលប្រកបដោយនវានុវត្តន៍




ខាងក្រោមនេះជាឧទាហរណ៍នៃក្របខណ្ឌ/ប្លង់សម្រាប់ការពង្រាងផែនការ[71] ៖

ជំហានទី ១ ៖ រៀបចំប្លង់ផែនការសកម្មភាពជាតិ ដែលអាចមានដូចជា ៖

១.មាតិកា និងបញ្ជីពាក្យកាត់
២.លិខិតបង្ហាញពីការគាំទ្រផ្នែកនយោបាយ (រដ្ឋមន្ត្រី។ល។)
៣.សេចក្តីផ្តើមដែលផ្តល់ព័ត៌មានស្តីពី ៖

- សារៈតារ/សនិទានភាព
- បរិបទសកល សេចក្តីសម្រេចលេខ ១៣២៥ និងសេចក្តីសម្រេចដែលពាក់ព័ន្ធផ្សេងៗ
- បរិបទជាតិ
- ភាគីពាក់ព័ន្ធ និងតួនាទីរបស់ពួកគេ
- ដំណើរការកសាងផែនការ ដូចជា ក្របខណ្ឌពេលវេលាសម្រាប់ការរៀបចំសិក្ខាសាលា សន្និសីទ កិច្ចប្រជុំសំខាន់ៗ ការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល និងព្រឹត្តការណ៍សំខាន់ៗផ្សេងទៀត។

ជំហានទី ២ ៖ បរិយាយចំណុចសំខាន់ៗ ដូចជា ៖

- គោលបំណង
- តារាងបង្ហាញសមិទ្ធផលរបស់ទ្រឹស្តីនៃការផ្លាស់ប្តូរ ដូចជា សូចនាករសម្រាប់វាស់វែងវឌ្ឍនភាព វិធានការ/សកម្មភាពអាទិភាពសំខាន់ៗ ការកំណត់ភាគីអនុវត្តន៍ និងភាគីទទួលខុសត្រូវ និងភាគីផ្សេងទៀត និងថវិកា (សម្រាប់ការទប់ស្កាត់ ការការពារ ការចូលរួម ការសង្គ្រោះ និងស្តារឡើងវិញ និងការសម្របសម្រួល ការពិនិត្យតាមដាន និងធ្វើរបាយការណ៍)
- ផែនការពិនិត្យតាមដាន និងវាយតម្លៃ
- ការសម្របសម្រួល និងការអនុវត្ត។

គណៈកម្មាធិការធ្វើសេចក្តីពង្រាងផែនការ គួរកំណត់កាលបរិច្ឆេទជាក់លាក់សម្រាប់សកម្មភាពនីមួយៗ និង រយៈពេលសម្រាប់ការបញ្ចប់ផែនការទាំងមូល។ ការកំណត់ខាងលើគួរមានភាពជាក់ស្តែង និងផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការរៀបចំផ្នែករដ្ឋបាល ធនធាន ការអប់រំ និងហេដ្ឋារចនាសម្ព័ន្ធ។

## ២.ព្រាងផែនការជាតិដែលបន្សុីគ្នានឹងផែនការសកម្មភាពតំបន់អាស៊ាន

ផែនការសកម្មភាពជាតិគួរបន្សុីគ្នានឹងផែនការសកម្មភាពតំបន់អាស៊ាន។ ផែនការសកម្មភាពតំបន់អាស៊ានផ្តោតសំខាន់លើសកម្មភាពអនុវត្តន៍នៅថ្នាក់ជាតិ ហើយកិច្ចការជាង ៨០% ស្ថិតក្រោមដែនយុត្តាធិការរបស់រដ្ឋសមាជិកអាស៊ាននីមួយៗ (រូបទី ៧)។ តួនាទីដ៏សំខាន់របស់ប្រទេសនានាក្នុងការទទួលយកផែនការនេះដាក់ទៅក្នុងការអនុវត្តនៅថ្នាក់ជាតិ អាចធ្វើឱ្យផែនការនោះក្លាយជាកំលាំងជំរុញទៅរកការផ្លាស់ប្តូរជាវិជ្ជមាន និងប្រកបដោយផលជះ សម្រាប់ស្ត្រី និងក្មេងស្រី (រូបទី ៨)។

រូបទី ៧ ៖ សកម្មភាពអាទិភាពនៃផែនការសកម្មភាពតំបន់អាស៊ាន




រូបទី ៨ ៖ អត្ថប្រយោជន៍នៃការបន្សុីផែនការជាតិទៅនឹងផែនការតំបន់




ការបន្សុីគ្នារវាង យុទ្ធសាស្ត្រជាតិ និងយុទ្ធសាស្ត្រតំបន់ តាមរយៈការពិនិត្យតាមដាន និងវាយតម្លៃគ្រប់ជ្រុងជ្រោយ ជួយបង្កើនប្រសិទ្ធភាពនៃការអន្តរាគមន៍ក្នុងស្រុក និងអន្តរាគមន៍កម្រិតតំបន់ និងរក្សាការតាមដានបន្តលើវឌ្ឍនភាពរបស់តំបន់អាស៊ានទាំងមូល។ ការសំយោគចូលគ្នានឹងលុបបំបាត់ភាពត្រួតគ្នា និងភាពច្រំដែល ជួយដល់ការបែងចែកធនធានឱ្យចំគោលដៅ ទៅកន្លែងដែលត្រូវការការយកចិត្តទុកដាក់ជាចាំបាច់ សម្រួលនីតិវិធីធ្វើរបាយការណ៍ និងបង្កើនគណនេយ្យភាព តាមរយៈការដាក់ចេញសូចនាកររួម និងចំណុចដៅដើម្បីវាស់វែងវឌ្ឍនភាព។

ការបន្សុីគ្នាជួយសម្រួលកិច្ចសហការក្នុងចំណោមរដ្ឋជាសមាជិក តាមរយៈការផ្តល់បរិយាកាសអំណោយផលសម្រាប់ការផ្លាស់ប្តូរការអនុវត្តល្អបំផុត ចែករំលែកចំណេះដឹង និងបន្តកិច្ចសហការដើម្បីបង្កើនផលជះ។ ការបន្សុីគ្នា អាចជួយពង្រឹងអភិក្រមរួមរបស់អាស៊ានសម្រាប់ការដោះស្រាយបញ្ហាប្រឈមដែលគិតគូពីយេនឌ័រនៅក្នុងបរិបទសន្តិភាព និងសន្តិសុខ និងផ្តល់សារច្បាស់លាស់ស្តីពីការប្តេជ្ញាចិត្តជារួមចំពោះស្ត្រី សន្តិភាព និងសន្តិសុខ។ តាមរយៈសាមគ្គីភាពនេះ អាស៊ានអាចបង្កើនភាពជឿទុកចិត្ត និងឥទ្ធិពលរបស់ខ្លួននៅកម្រិតសកល ដែលអាចទាក់ទាញការគាំទ្រ និងកិច្ចសហការកាន់តែច្រើនពីភាគីពាក់ព័ន្ធអន្តរជាតិ។

ផែនការសកម្មភាពតំបន់អាស៊ាន ផ្តល់ទិសដៅជាក់លាក់សម្រាប់ការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ក៏ដូចជាទទួលស្គាល់សារៈសំខាន់នៃនវានុវត្តន៍ផ្អែកលើភស្តុតាង និងអភិក្រមដែលមានលក្ខណៈមូលដ្ឋាន។ ផែនការនេះគូសបញ្ជាក់ពីការអនុវត្តជាគំរូ និងជំរុញភាពជាដៃគូរវាងយុទ្ធសាស្ត្រថ្នាក់មូលដ្ឋាន និងយុទ្ធសាស្ត្រថ្នាក់ជាតិ ឬយុទ្ធសាស្ត្រថ្នាក់តំបន់។

តាមរយៈការបន្សុីគ្នារវាងសកម្មភាពអាទិភាព ទៅនឹងសសរស្តម្ភសំខាន់ៗ (ការការពារ ការចូលរួម ការទប់ស្កាត់ ការសង្គ្រោះ និងស្តារឡើងវិញ) ផែនការសកម្មភាពតំបន់អាស៊ាននឹងក្លាយជាមគ្គុទេសក៍ដ៏មានប្រសិទ្ធភាពសម្រាប់ត្រួសត្រាយកិច្ចខិតខំប្រឹងប្រែងដាក់បញ្ចូលរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ទៅក្នុងគំនិតផ្តួចផ្តើមស្តីពីសន្តិភាព និងសន្តិសុខព្រំដែន។ រូបទី ៩ បង្ហាញពីតារាងសម្រាប់តាមដានវឌ្ឍនភាព និងការសម្របសម្រួល។

## រូបទី ៩ ៖ តារាងសកម្មភាពក្នុងផែនការសកម្មភាពតំបន់អាស៊ាន

**លទ្ធផលចុងក្រោយទី ១ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ**

នៅក្នុងគោលនយោបាយ ការអនុវត្ត និងស្ថាប័នដែលពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ ការការពារសិទ្ធិរបស់ស្ត្រី ស្ត្រីវ័យក្មេង និងក្មេងស្រី រួមទាំងអ្នកមកពីក្រុមងាយរងគ្រោះ ដូចជា ការការពារស្ត្រី និងក្មេងស្រីពីគ្រប់ទម្រង់នៃអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្នុងស្ថានភាពមានជម្លោះ ស្ថានភាពក្រោយពេលមានជម្លោះ ស្ថានភាពកសាងសន្តិភាព និងស្ថានភាពមនុស្សធម៌

**លទ្ធផលចុងក្រោយទី ១ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ**

ការចូលរួមពេញលេញ ប្រកបដោយអត្ថន័យ និងស្មើភាពរបស់ស្ត្រី នៅក្នុងស្ថាប័ន អង្គការ និងដំណើរការធ្វើសេចក្តីសម្រេច ដែលពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ ដូចជា ក្នុងមុខតំណែងដឹកនាំ

**លទ្ធផលចុងក្រោយទី ៣ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ**

ស្ថាប័នតាមវិស័យរបស់អាស៊ាន ស្ថាប័ន និងរដ្ឋសមាជិកដើរតួនាទីយ៉ាងសកម្មក្នុងការរួមចំណែកដល់ការទប់ស្កាត់ជម្លោះនៅកម្រិតសកល តំបន់ និងជាតិ និងការទប់ស្កាត់អំពើហិង្សា គ្រោះមហន្តរាយ និងការគំរាមកំហែងផ្សេងទៀតលើសន្តិភាព និងសន្តិសុខ ដោយកំណត់យករបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ជាចំណុចស្នូលនៃសកម្មភាពទាំងនោះ

**លទ្ធផលចុងក្រោយទី ៤ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ**

ស្ថាប័ន យន្តការ និងដំណើរការស្តីពីសន្តិភាព និងសន្តិសុខ ទប់ស្កាត់ដោយជោគជ័យ លើអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ

**លទ្ធផលចុងក្រោយទី ៥ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ**

ការបំពេញតម្រូវការរបស់ស្ត្រី និងក្មេងស្រី នៅក្នុងដំណើរការសង្គ្រោះ និងស្តារឡើងវិញ នៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ហើយស្ត្រីអាចចូលរួមដោយស្មើភាព និងប្រកបដោយអត្ថន័យ នៅក្នុងដំណើរការទាំងនេះ ដូចជា ក្នុងមុខតំណែងធ្វើសេចក្តីសម្រេច និងមុខតំណែងដឹកនាំ

**លទ្ធផលចុងក្រោយទី ៦ នៃផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ**

ហេដ្ឋារចនាសម្ព័ន្ធ និងយន្តការក្នុងការអនុវត្ត សម្របសម្រួល និងពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីគាំទ្រដល់ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវបានបង្កើតឡើង និងអនុវត្ត ជាមួយនឹងវិធានការជាក់លាក់ដើម្បីកែសម្រួល និងធ្វើការផ្លាស់ប្តូរ ទៅតាមការពិគ្រោះយោបល់ជាបន្តបន្ទាប់ និងលទ្ធផលរកឃើញពីរបាយការណ៍វឌ្ឍនភាព ការវាយតម្លៃ និងទិន្នន័យស្តីពីស្ត្រី សន្តិភាព និង សន្តិសុខ

### ការគូសផែនទី

ការគូសផែនទី អាចវាយតម្លៃរបៀបដែលផែនការជាតិអាចបន្សុីជាមួយគោលបំណងជាយុទ្ធសាស្ត្រនៃផែនការសកម្មភាពតំបន់អាស៊ាន ដោយរំលេចចំណុចរួមគ្នា និងចំណុចខុសគ្នា។ ការគូសផែនទីនឹងផ្តល់ឧបករណ៍ដល់រដ្ឋាភិបាលសម្រាប់រក្សាតុល្យភាពរវាងសកម្មភាពអាទិភាពផ្សេងៗនៅកម្រិតតំបន់។ ការគូសផែនទីសម្រួលដល់ការកំណត់អាទិភាពជាតិសំខាន់ៗ ដែលឆ្លុះបញ្ចាំងពីគោលដៅក្នុងតំបន់ ដោយពិចារណាពីផលជះ និងភាពប្រទាក់ក្រឡាគ្នា។ ការបង្កើនការយល់ដឹងស៊ីជម្រៅរបៀបនេះ អាចកំណត់ចំណុចផ្តោតនៅកម្រិតប្រទេស និងកំណត់អាទិភាពកាន់តែច្បាស់លាស់ និងជាមគ្គុទេសក៍សម្រាប់ការបែងចែកធនធាន និងសកម្មភាពចំគោលដៅ។

## ស្ទ័យវាយតម្លៃលើការបន្សុីគ្នានឹងលទ្ធផលចុងក្រោយនៃផែនការសកម្មភាពតំបន់អាស៊ាន

១.លទ្ធផលចុងក្រោយទី ១ ៖ ការការពារសិទ្ធិ

- តើគោលនយោបាយ និងការអនុវត្តថ្នាក់ជាតិ កំពុងដោះស្រាយការការពារស្ត្រី ស្ត្រីវ័យក្មេង និងក្មេងស្រី ពីអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្នុងស្ថានភាពមានជម្លោះ ស្ថានភាពក្រោយពេលមានជម្លោះ ស្ថានភាពកសាងសន្តិភាព និងស្ថានភាពមនុស្សធម៌ ដោយរបៀបណា?
- តើក្រុមងាយរងគ្រោះមានភាពជាតំណាងគ្រប់គ្រាន់ក្នុងគោលនយោបាយជាតិដែលពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខ ឬទេ?
- តើគេអាចវាស់វែង និងបង្កើនប្រសិទ្ធភាពនៃវិធានការទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយរបៀបណា?

២.លទ្ធផលចុងក្រោយទី ២ ៖ ការចូលរួមរបស់ស្ត្រី

- តើមានវិធានការអ្វីខ្លះសម្រាប់ធានាការចូលរួមពេញលេញ និងប្រកបដោយអត្ថន័យរបស់ស្ត្រី នៅក្នុងដំណើរការធ្វើសេចក្តីសម្រេច ដែលពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខនៅកម្រិតផ្សេងៗ?
- តើគេអាចតាមដាន និងបង្កើនចំនួនស្ត្រីដែលកាន់មុខតំណែងថ្នាក់ដឹកនាំ នៅក្នុងស្ថាប័ន និងអង្គការពាក់ព័ន្ធ ដោយរបៀបណា?
- តើមានយន្តការសម្រាប់ដោះស្រាយឧបសគ្គរាំងមិនឱ្យស្ត្រីចូលរួមក្នុងតួនាទីដឹកនាំ ឬទេ?

៣.លទ្ធផលចុងក្រោយទី ៣ ៖ តួនាទីរបស់អាស៊ានក្នុងការទប់ស្កាត់ជម្លោះ

- តើរដ្ឋាភិបាលរួមចំណែកដូចម្តេចដល់កិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ជម្លោះនៅកម្រិតសកល តំបន់ និងជាតិ ស្របតាមគោលការណ៍ក្នុងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ?
- តើមានការអនុវត្តសកម្មភាពជាក់លាក់អ្វីខ្លះដើម្បីដាក់បញ្ចូលគោលការណ៍ស្ត្រី សន្តិភាព និងសន្តិសុខ ទៅក្នុងយុទ្ធសាស្ត្រទប់ស្កាត់ជម្លោះដែលមានស្រាប់?

៤.លទ្ធផលចុងក្រោយទី ៤ ៖ ការទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ

- តើស្ថាប័នសន្តិភាព និងសន្តិសុខធ្វើដូចម្តេចដើម្បីទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រប្រកបដោយប្រសិទ្ធភាព?
- តើមានយន្តការអ្វីខ្លះដើម្បីដោះស្រាយ និងឆ្លើយតបនឹងករណីអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅក្នុងកងកម្លាំងសន្តិសុខ ឬបរិបទដែលពាក់ព័ន្ធនឹងជម្លោះ?
- តើគេអាចវាស់វែង និងបង្កើនភាពជោគជ័យនៃកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយរបៀបណា?

៥.លទ្ធផលចុងក្រោយទី ៥ ៖ តម្រូវការរបស់ស្ត្រី និងក្មេងស្រី ក្នុងការសង្គ្រោះ និងស្តារឡើងវិញ

- តើដំណើរការសង្គ្រោះ និងស្តារឡើងវិញនឹងបំពេញតម្រូវការជាក់លាក់របស់ស្ត្រី និងក្មេងស្រីនៅកម្រិតតំបន់ ជាតិ និងមូលដ្ឋាន ដោយរបៀបណា?
- តើមានការអនុវត្តជំហានអ្វីខ្លះដើម្បីធានាការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រី នៅក្នុងការធ្វើសេចក្តីសម្រេចក្នុងដំណើរការសង្គ្រោះ និងស្តារឡើងវិញ?
- តើគេអាចវាយតម្លៃ និងបង្កើនផលជះនៃកិច្ចខិតខំប្រឹងប្រែងសង្គ្រោះ និងស្តារឡើងវិញ ដែលឆ្លើយតបនឹងយេនឌ័រ ដោយរបៀបណា?

៦.លទ្ធផលចុងក្រោយទី ៦ ៖ ការអនុវត្ត ការសម្របសម្រួល និងការពិនិត្យតាមដាន និងវាយតម្លៃ

- តើមានយន្តការថ្នាក់ជាតិ និងរចនាសម្ព័ន្ធសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃវឌ្ឍនភាពនៃផែនការសកម្មភាពតំបន់អាស៊ាន ឬទេ?
- តើមានដំណើរការពិគ្រោះយោបល់អ្វីខ្លះសម្រាប់ប្រមូលធាតុចូលពីភាគីពាក់ព័ន្ធ និងធ្វើការកែសម្រួលចាំបាច់ដោយផ្អែកតាមយោបល់ត្រឡប់របស់ពួកគេ?

### ការបង្កើតក្របខណ្ឌគំរូតក្កភាព (ឡុកហ្វ្រេម) និងទ្រឹស្តីនៃការផ្លាស់ប្តូរ

ក្នុងការបង្កើតផែនការសកម្មភាពជាតិ ការកំណត់គោលដៅច្បាស់លាស់ និងជាក់លាក់ ដែលបន្សីគ្នានឹងគោលបំណងជាតិ និងគោលបំណងតំបន់ បង្វែរពីការផ្តោតទៅជាការស្វែងយល់ពីលទ្ធផលចុងក្រោយ ជាង ការវាស់វែងត្រឹមតែលទ្ធផលក្នុងឆ្នាំ ។ ខណៈដែលលទ្ធផលក្នុងឆ្នាំអាចកំណត់ជាបរិមាណបាន ការផ្តោតអាទិភាពលើប្រសិទ្ធភាព និងលទ្ធផលចុងក្រោយក្នុងផ្នែកសង្គម នឹងជួយបញ្ចៀសការបំភ្លៃ និងការរឹតត្បិតដែលអាចលេចឡើង។ ក្របខណ្ឌគំរូតក្កភាព (ឡុងហ្វ្រេម) គួរធ្វើយ៉ាងណាឱ្យមានភាពបន្សីគ្នារវាងផែនការគោលបំណង លទ្ធផលចុងក្រោយ និងលទ្ធផលក្នុងឆ្នាំ។ ផែនទីបង្ហាញផ្លូវច្បាស់លាស់ដែលបង្ហាញពីទំនាក់ទំនងរវាងធាតុចូល និងសមិទ្ធផល គឺសំខាន់ណាស់។ ចំណុចនេះទាមទារការយល់ដឹងពីទំនាក់ទំនងហេតុ និងផល ដោយផ្អែកលើទ្រឹស្តីនៃការផ្លាស់ប្តូរ (រូបទី ១០)។

ជារួម ផែនការសកម្មភាពច្រើនតែរៀបរាប់ពីយុទ្ធសាស្ត្រសម្រាប់ជំរុញការផ្លាស់ប្តូរនៅកម្រិតខ្ពស់ ដែលអាចនាំឱ្យមានចន្លោះប្រហោងក្នុងការពណ៌នាពីរបៀបបង្ហាញពីសកម្មភាពជាក់លាក់។ កម្រិតនៃភាពច្បាស់លាស់ និងភាពពេញលេញក្នុងការលម្អិតពីសកម្មភាព គឺសំខាន់ ព្រោះវាអាចបង្កផលជះខ្លាំងលើទៅដល់លទ្ធផលចុងក្រោយ។ ការបញ្ជាក់ពីការផ្លាស់ប្តូរជាក់លាក់ និងអាចវាស់វែងបាន ពាក់ព័ន្ធនឹងកំណត់សូចនាករច្បាស់លាស់ ដែលឆ្លើយតបនឹងលទ្ធផលចុងក្រោយ ដើម្បីតាមដានវឌ្ឍនភាពប្រកបដោយអត្ថន័យ (ប្រអប់ទី ៧ និងទី ៨)។ គេអាចបង្កើតមូលដ្ឋានរឹងមាំ តាមរយៈការជ្រើសរើសសូចនាករដោយផ្អែកលើទ្រឹស្តីនៃការផ្លាស់ប្តូរ។

រូបទី ១០ ៖ តើអ្វីជាទ្រឹស្តីនៃការផ្លាស់ប្តូរ?

## ទ្រឹស្តីនៃការផ្លាស់ប្តូរជាផែនទីទស្សនទាន ដែលបង្ហាញពីរបៀបដែលសកម្មភាពនាំទៅរកលទ្ធផលចុងក្រោយ។

- ទ្រឹស្តីនេះបញ្ជាក់ច្បាស់ពីគោលបំណងនៃសកម្មភាព និងមធ្យោបាយនានា ដើម្បីសម្រេចគោលបំណងទាំងនោះ
- ទ្រឹស្តីនេះបង្ហាញពីសារៈសំខាន់នៃការសម្រេចបានលទ្ធផលចុងក្រោយកម្រិតមធ្យម
- ទ្រឹស្តីនេះបង្កើតជារចនាសម្ព័ន្ធសម្រាប់ការកំណត់រកចំណុចដែលត្រូវវាស់វែង
- ទ្រឹស្តីនេះជួយកំណត់ចំណុចសកម្ម និងចំណុចអសកម្ម
- ទ្រឹស្តីនេះផ្តល់វិធីធម្មតា និងច្បាស់លាស់សម្រាប់ឱ្យទៅសម្រេចបានបេសកកម្ម និងផលជះ

| បញ្ហា | ធាតុចូល | សកម្មភាព | លទ្ធផលក្នុងឆ្នាំ | លទ្ធផលចុងក្រោយ | សូចនាករ | ផលជះ |
|---|---|---|---|---|---|---|
| បញ្ហាសំខាន់ដែលត្រូវដោះស្រាយ | ធនធានចាំបាច់ដើម្បីអនុវត្តសកម្មភាព | សកម្មភាពដែលបានធ្វើឡើងដើម្បីសម្រេចលទ្ធផលក្នុងឆ្នាំ | សមិទ្ធផលនៃកម្រងសកម្មភាពដែលបានបញ្ចប់ | ការផ្លាស់ប្តូរដែលអ្នករំពឹងថានឹងសម្រេចបាន ពីសកម្មភាពរបស់ផែនការសកម្មភាពជាតិ | ជាក់លាក់ អាចវាស់វែងបាន អាចសម្រេចបាន មានភាពពាក់ព័ន្ធ និងមានការកំណត់ពេលវេលា | ផលជះយូរអង្វែង និងទូលំទូលាយនៃផែនការសកម្មភាពជាតិ |

## ប្រអប់ទី ៧ ៖ ផែនការសកម្មភាពជាតិ ២០១៨-២០២២ របស់ប្រទេសស្វីស

សូចនាករផែនការសកម្មភាពជាតិរបស់ស្វីស មានតម្លៃខ្ពស់ណាស់ ព្រោះវារក្សាតុល្យភាពរវាងវិធានការបែបបរិមាណ ដូចជា ចំនួនអ្នកចូលរួម និងការវាយតម្លៃបែបគុណភាព ដូចជា ការត្រៀមខ្លួនកាន់តែប្រសើររបស់អ្នកសម្រុះសម្រួល ក្នុងការផ្តល់ទស្សនៈយល់ឃើញកាន់តែគ្រប់ជ្រុងជ្រោយស្តីពីប្រសិទ្ធភាព និងបរិយាបន្ន នៃដំណើរការ សម្រុះសម្រួល។

### គោលដៅរងទី ២៖

ដំណើរការសម្រុះសម្រួលប្រកបដោយបរិយាបន្ន និងគិតគូពីយេនឌ័រ ជំរុញការរួមបញ្ចូលទស្សនៈ យល់ឃើញរបស់ តួអង្គពាក់ព័ន្ធទាំងអស់។

#### វិធានការ

- កសាងការយល់ដឹងរបស់ជនបង្គោលស្តីពី គុណសម្បត្តិ និងប្រសិទ្ធភាពនៃក្រុមបែបបរិយាបន្ន នៅក្នុងដំណើរការ សម្រុះសម្រួល
- បង្កើត អនុវត្ត និងវាយតម្លៃមេរៀនក្នុង បណ្តុះបណ្តាលស្តីពីយេនឌ័រ ក្នុង ការសម្រុះសម្រួល
- ការប្រជុំពិភាក្សាមុនពេល និងក្រោយពេល អនុវត្តសកម្មភាព សម្រាប់អ្នកអនុវត្ត ការសម្រុះសម្រួលលើបញ្ហាពាក់ព័ន្ធនឹង យេនឌ័រ នៅក្នុងការសម្រុះសម្រួល

#### សូចនាករក្នុងការរាយការណ៍

- ចំនួនដងនៃការធ្វើទំនាក់ទំនងជាមួយជន បង្គោលដើម្បីកសាងការយល់ដឹងអំពី ដំណើរការសម្រុះសម្រួលប្រកបដោយបរិយាបន្ន
- ពាក់ព័ន្ធនឹងការបណ្តុះបណ្តាល និង ការប្រជុំពិភាក្សាមុនការអនុវត្តសកម្មភាព អ្នកផ្សះផ្សារជាជនជាតិស្វីស យល់ថា ពួកគេត្រៀមខ្លួនរួចរាល់ក្នុងការដោះស្រាយ បញ្ហាពាក់ព័ន្ធនឹង យេនឌ័រ នៅក្នុងការសម្រុះសម្រួល និង អាចអនុវត្តចំណេះដឹងដែលពួកគេទទួល បាន។

#### ការទទួលខុសត្រូវ

FDFA

## ប្រអប់ទី ៨ ៖ ផែនការសកម្មភាពជាតិ ២០២៣-២០២៧ របស់ប្រទេសស្រីលង្ការ

សូចនាករក្នុងផែនការសកម្មភាពជាតិស្រីលង្ការ មានភាពជាក់លាក់ ដោយគ្របដណ្តប់លើកម្រិតផ្សេងៗនៅក្នុង កងកម្លាំងនគរបាល និងរៀបរាប់ពីមធ្យោបាយសម្រាប់វាស់វែងវឌ្ឍនភាព។ បន្ថែមពីនេះ សូនាករទាំងនោះបាន កំណត់ច្បាស់ពីការទទួលខុសត្រូវរបស់ទីភ្នាក់ងារដឹកនាំការអនុវត្ត ក៏ដូចជាកំណត់ទីភ្នាក់ងារជាក់លាក់ឱ្យ ទទួលខុសត្រូវលើការពិនិត្យតាមដានវឌ្ឍនភាព។ ចំណុចនេះជួយលើកម្ពស់គណនេយ្យភាព និងតម្លាភាពក្នុងការ ជ្រើសរើស និងរក្សាទុកកងកម្លាំងនគរបាលជាស្ត្រី។

| សកម្មភាពសំខាន់ៗ | សូចនាករ | មធ្យោបាយសម្រាប់វាស់វែងវឌ្ឍនភាព | ទីភ្នាក់ងារដឹកនាំការអនុវត្ត | ទីភ្នាក់ងារគាំទ្រ | | ក្របខណ្ឌពេលវេលា | ទីភ្នាក់ងារពិនិត្យតាមដាន | ថវិកា |
|---|---|---|---|---|---|---|---|---|
| | | | | តួអង្គរដ្ឋ | តួអង្គមិនមែនរដ្ឋ | | | |
| ២.១២ ធានាការជ្រើសរើសចំនួនមន្ត្រីនគរ បាលជាស្ត្រីឱ្យបានគ្រប់ និងប្រចាំការណ៍នៅគ្រប់ប៉ុស្តិ៍នគរបាល និងធានាថា មន្ត្រីនគរ បាល ទាំងនោះបានដាក់បញ្ចូលក្នុងក្របខណ្ឌការងារ និងទទួលបានឱកាសស្មើភាពក្នុងឡើងតំណែង និងសមត្ថភាពធ្វើសេចក្តីសម្រេចក្នុងជួរនគរ បាល។ | ចំនួនមន្ត្រីនគរបាលជាស្ត្រីដែលត្រូវបានជ្រើសរើស។ ភាគរយនៃមន្ត្រីនគរបាលជាស្ត្រីដែលប្រចាំការណ៍នៅគ្រប់ប៉ុស្តិ៍នគរបាលទាំងអស់។<br>ចំនួនមន្ត្រីនគរបាលជាស្ត្រី ដែលកាន់តួនាទីកំពូលទាំង៣ ក្នុងជួរនគរបាល។<br>ចំនួនការស្ទង់មតិប្រចាំឆ្នាំដែលបានធ្វើឡើងដើម្បីបញ្ជាក់ពីចំនួនមន្ត្រីនគរបាលជាស្ត្រីដែលត្រូវបានជ្រើសរើសនៅអំឡុងឆ្នាំ ២០២៣-២០២៧។<br>ចំនួននៃការស្ទង់មតិដែលបានធ្វើឡើងដើម្បីបញ្ជាក់ពីចំនួនមន្ត្រីនគរបាលជាស្ត្រីដែលបន្តការងារក្នុងក្របខណ្ឌ សម្រាប់រយៈពេល ៥ឆ្នាំ ១០ឆ្នាំ ១៥ឆ្នាំ ២០ឆ្នាំ និង២៥ឆ្នាំ។ | ស្នងការនគរបាល<br>នគរបាលស្រីលង្ការ | គណៈកម្មការសេវានគរបាល<br>ស្នងការនគរបាល<br>នគរបាលស្រីលង្ការ<br>ក្រសួងសន្តិសុខសាធារណៈ | គណៈកម្មការសេវានគរបាល<br>មហាវិទ្យាល័យនគរបាលស្រីលង្ការ<br>ក្រសួងយុត្តិធម៌ កិច្ចការពន្ធនាគារ និងកំណែទម្រង់រដ្ឋធម្មនុញ្ញ<br>ក្រសួងកិច្ចការនារី | ស្ថាប័នស្រាវជ្រាវ | ខែ មករា-សីហា ឆ្នាំ ២០២៣ | ស្នងការនគរបាលជាតិ ស្រីលង្ការ<br>ក្រសួងកិច្ចការនារី និងកុមារ និងការពង្រឹងភាពអង់អាច សង្គម | នឹងមានការបញ្ជាក់ |

# ៣.រៀបចំផែនការពិនិត្យតាមដាន និងវាយតម្លៃ

ការរៀបចំផែនការពិនិត្យតាមដាន និងវាយតម្លៃ គួរធ្វើឡើងដំណាលគ្នានឹងការព្រាងផែនការសកម្មភាពជាតិ ដើម្បីជានាការពិនិត្យតាមដានជាបន្ត និងជាក់ស្តែង។ ការរៀបចំកសាងផែនការពីដំបូងនឹងផ្តល់ការយល់ដឹងស៊ីជម្រៅអំពីគោលបំណង និងអាទិភាពនៃផែនការសកម្មភាពជាតិ។ ថវិកា បុគ្គលិក និងការគាំទ្រផ្នែកបច្ចេកទេស អាចត្រូវបានកំណត់ទុកជាមុន ដើម្បីបង្ការការពន្យារពេលណាមួយ និងភាពរាំងស្ទះផ្សេងៗ។

ការរៀបចំផែនការពីដំបូង ជួយដល់ការកំណត់លក្ខខណ្ឌនៃការប្រមូលទិន្នន័យ និងបញ្ហាប្រឈមសំខាន់ៗ។ ការធ្វើដូច្នេះនឹងជួយធានាថា យន្តការប្រមូលទិន្នន័យមានជាស្រេច នៅពេលដាក់ចេញផែនការសកម្មភាពជាតិ ដើម្បីបញ្ចៀសការពន្យារពេលក្នុងការប្រមូលព័ត៌មានសំខាន់ៗ ក៏ដូចជាពង្រឹងការចូលរួមរបស់ភាគីពាក់ព័ន្ធសំខាន់ៗតាំងពីដំបូង កសាងភាពម្ចាស់ការ ការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវរួមលើការពិនិត្យតាមដានលទ្ធផលចុងក្រោយ និងអាចដាក់បញ្ចូលយោបល់ត្រឡប់ផ្សេងៗ។ មេរៀន និងចំណេះដឹងដែលលេចឡើង អាចជួយដល់ការកែសម្រួលជាក់ស្តែងលើផែនការសកម្មភាពជាតិ ដើម្បីបង្កើនភាពបត់បែន និងប្រសិទ្ធភាព។

ប្រទេស និងអង្គការថ្នាក់តំបន់ជាច្រើន មានសសរស្តម្ភមួយស្តីពីការសម្របសម្រួល ការពិនិត្យតាមដាន ការធ្វើរបាយការណ៍ និងការវាយតម្លៃ នៅក្នុងផែនការសកម្មភាពជាតិ។ វាជាសញ្ញាបង្ហាញថា នឹងមានការតាមដានល្អិតល្អន់ និងការធ្វើរបាយការណ៍ពីវឌ្ឍនភាព ដើម្បីលើកកម្ពស់តម្លាភាព និងទំនុកចិត្តក្នុងចំណោមភាគីពាក់ព័ន្ធ។

ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃដែលមានប្រសិទ្ធភាព គួរផ្អែកលើគោលការណ៍ខាងក្រោម (សម្រាប់ជាឧទាហរណ៍ សូមមើលប្រអប់ទី ៩ និងប្រអប់ទី ១០)៖

- ផ្តោតសំខាន់លើសូចនាកររបស់លទ្ធផលចុងក្រោយ ៖ ភាពមានកម្រិតនៃសមត្ថភាពពិនិត្យតាមដាន អាចធ្វើឱ្យមានការសង្កត់ធ្ងន់លើសូចនាករលទ្ធផលចុងក្រោយ ជាងសូចនាករលទ្ធផលក្នុងឆ្នាំ។ សូចនាករលទ្ធផលចុងក្រោយ បន្សុីគ្នានឹងគោលដៅជារួមនៃផែនការសកម្មភាពជាតិ ជាងសូចនាករលទ្ធផលរំពឹងទុក និងផ្តល់ទស្សនៈស្តីពីវឌ្ឍនភាព ខ្ពស់ជាងសូចនាករលទ្ធផលក្នុងឆ្នាំ។

- បន្សុីគ្នានឹងគោលដៅជាក់លាក់ ៖ សូចនាករនីមួយៗគួរពាក់ព័ន្ធដោយផ្ទាល់នឹងគោលដៅជាក់លាក់មួយនៅក្នុងផែនការសកម្មភាពជាតិ ដើម្បីពង្រឹងទំនាក់ទំនងរវាងសកម្មភាព និងលទ្ធផលចុងក្រោយដែលចង់បាន។

- ផ្តល់ព័ត៌មានក្បោះក្បាយ ៖ សូចនាករគួរផ្តល់ទិន្នន័យដែលមានតម្លៃ និងក្បោះក្បាយដែលអាចផ្តល់ការយល់ដឹងពេញលេញអំពីវឌ្ឍនភាពនៃការអនុវត្ត។ ចំណុចនេះនឹងផ្តល់ភាពអង់អាចដល់អ្នកតាក់តែងគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត ក្នុងការធ្វើសេចក្តីសម្រេច និងមានការកែប្រែដោយផ្អែកតាមព័ត៌មានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ នៅក្នុងករណីចាំបាច់។

- ការតាមដានក្នុងលក្ខណៈធម្មតា ៖ សូចនាករគួរផ្តល់វិធីដែលងាយស្រួលវាស់វែង ដើម្បីតាមដានវឌ្ឍន-ភាព។ ការជ្រើសរើសសូចនាករគួរពិចារណាពីប្រភពដែលផ្តល់ទិន្នន័យជាប្រចាំ។

- ការវាស់វែងដែលមានសង្កត់ ៖ ជ្រើសរើសសូចនាករដែលអាចវាស់វែងជាបន្តបន្ទាប់ពីពេលមួយទៅពេលមួយ ដើម្បីផ្តល់ភាពជឿទុកចិត្តបានក្នុងការតាមដានវឌ្ឍនភាព។

- ការបង្ហាញភាពស្មុគស្មាញ ៖ សូចនាករគួរបង្ហាញទិដ្ឋភាពស្មុគស្មាញ និងសាំញ៉ាំនៃការផ្លាស់ប្តូរ ដែលផែនការសកម្មភាពជាតិចង់សម្រេចបាន។

- ពិចារណាលើចំណាយ ៖ នៅពេលជ្រើសរើសសូចនាករ សូមគិតពីការចំណាយលើការវាស់វែងសូចនាករទាំងនោះ និងរក្សាតុល្យភាពរវាងការវាស់វែងលើភាពក្បោះក្បាយ និងភាពអាចអនុវត្តបាន។

- សូចនាករយោង ៖ សូចនាករយោងដែលអ្នកបានជ្រើសរើសជាមួយនឹងក្របខណ្ឌសកល និងក្របខណ្ឌតំបន់ដែលពាក់ព័ន្ធ ដូចជា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងផែនការសកម្មភាពតំបន់អាស៊ាន ដើម្បីកំណត់សូចនាករទូទៅ។ ចំណុចនេះនឹងធ្វើឱ្យមានភាពសាមញ្ញក្នុងការធ្វើរបាយការណ៍ និងបង្កើនសង្គត់ភាព។

- សុខដុមរមនានឹងប្រព័ន្ធរបស់រដ្ឋាភិបាល ៖ ធានាថា សូចនាករដែលបានជ្រើសរើស មានសុខដុមរមនានឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃរបស់រដ្ឋាភិបាល។ ប្រសិនបើរដ្ឋាភិបាលប្រើប្រាស់អភិក្រមផ្អែកលើសកម្មភាព គួរពិចារណាដាក់បញ្ចូលសូចនាករលទ្ធផលចុងក្រោយទៅក្នុងរចនាសម្ព័ន្ធមានស្រាប់របស់រដ្ឋាភិបាល ជាជាងបង្កើតក្របខណ្ឌដាច់ដោយឡែកមួយ។

- ការកសាងសមត្ថភាព ៖ វាអាចនឹងចាំបាច់ដើម្បីកសាងសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការពិនិត្យតាមដាន និងវាយតម្លៃ។ ការបណ្តុះបណ្តាល និងការគាំទ្រ អាចលើកកម្ពស់សមត្ថភាពក្នុងការពិនិត្យតាមដាន និងការធ្វើរបាយការណ៍ដោយប្រសិទ្ធភាពលើសូចនាករដែលបានកំណត់។

- ធ្វើការសម្រួលអភិក្រម "ការកំណត់ចំនួនសូចនាករតិច តែមានប្រសិទ្ធភាពជាង (less is more)"។ ផ្តោតសំខាន់លើចំនួនសូចនាករសមស្របដែលអាចបង្ហាញពី សារៈសំខាន់នៃវឌ្ឍនភាព។ ការមានចំនួនសូចនាករតិចដែលគ្រប់ជ្រុងជ្រោយ នឹងសម្រួលដល់ការពិនិត្យតាមដាន និងការរបាយការណ៍កាន់តែមានប្រសិទ្ធភាព និងកាត់បន្ថយការដាក់បន្ទុកលើក្រុមពិនិត្យតាមដាន និងវាយតម្លៃរបស់រដ្ឋាភិបាល។

**ការបន្សុីការពិនិត្យតាមដាន និងការធ្វើរបាយការណ៍ថ្នាក់ជាតិទៅនឹងផែនការតំបន់អាស៊ាន**

ផែនការជាតិពិនិត្យតាមដាន និងវាយតម្លៃនីមួយៗ គួរឆ្លើយតបនឹងគោលដៅរួមនៃផែនការតំបន់អាស៊ាន ដើម្បីផ្តល់ការណែនាំច្បាស់លាស់លើការអនុវត្ត និងជំរុញយុទ្ធសាស្ត្រផ្អែកលើភស្តុតាង។ ផែនការពិនិត្យតាមដាន និងវាយតម្លៃ គួរតែជាឧបករណ៍ដ៏រស់រវើកដែលជួយឱ្យភាគីពាក់ព័ន្ធទាំងអស់ឈានទៅសម្រេចបានគោលដៅថ្នាក់ជាតិ និងគោលដៅថ្នាក់តំបន់ផ្សេងទៀត។ ផែនការពិនិត្យតាមដាន និងវាយតម្លៃ គួររួមចំណែកដល់ការធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាង តាមរយៈការផ្តល់ព័ត៌មានសុក្រឹត និងធ្វើបច្ចុប្បន្នភាពសកម្មភាពរបស់លទ្ធផលចុងក្រោយ ដែលលើកកម្ពស់ភាពជឿជាក់នៃដំណើរការដាក់សន្សុីគ្នា។

**ការបន្សុីសូចនាករទៅនឹងអាណត្តិរបស់ស្ថាប័ន**

សូចនាករគួរបន្សុីគ្នានឹងអាណត្តិ និងសកម្មភាពរបស់ក្រសួង នាយកដ្ឋាន និងទីភ្នាក់ងារពាក់ព័ន្ធ ដើម្បីអាចបង្ហាញលទ្ធផលក្នុងឆ្នាំ និងការរួមចំណែករបស់ស្ថាប័ននីមួយៗបានយ៉ាងត្រឹមត្រូវ ក៏ដូចជាពិចារណាលើផលជះធំទូលាយលើផ្នែកផ្សេងៗគ្នា។ ការរៀបចំវគ្គស្តីពីកម្មវិធី/គោលនយោបាយ ជាមួយនឹងបុគ្គលិកពិនិត្យតាមដាន និងវាយតម្លៃ ដែលមកពីនាយកដ្ឋានផ្សេងទៀត អាចពង្រឹងកិច្ចសហការ និងជាវេទិកាដ៏មានតម្លៃសម្រាប់ការពិនិត្យឡើងវិញ ការវាយតម្លៃ និងការកែលម្អសូចនាករដែលបានកំណត់។

**កុំមើលរំលងចំណេះដឹងបែបគុណភាព**

ការបង្កើតសូចនាករ គ្រាន់តែជាផ្នែកមួយនៃដំណើរការពិនិត្យតាមដានដ៏ធំទូលាយប៉ុណ្ណោះ។ ទោះបីជាសូចនាករផ្តល់ចំណេះដឹងសំខាន់ៗមែន ប៉ុន្តែវាមិនផ្តល់ទិដ្ឋភាពពេញលេញនោះទេ។ ចំណេះដឹងបែបគុណភាពដែលទទួលបានពីគម្រោង កិច្ចពិភាក្សា និងកិច្ចខិតខំប្រឹងប្រែងដោយមានកិច្ចសហការ ជួយរំលេចការយល់ដឹងជារួមអំពីផលជះរបស់ផែនការសកម្មភាពជាតិ។ គួរប្រើប្រាស់ទាំងប្រភពទិន្នន័យបែបបរិមាណ និងប្រភពទិន្នន័យបែបគុណភាពសម្រាប់ការដាក់បញ្ចូលចំណេះដឹងដែលអាចវាស់វែងបាន និងការយល់ដឹងស៊ីជម្រៅអំពីបទពិសោធន៍បែបបានុម័តរបស់ភាគីពាក់ព័ន្ធ។

## ប្រអប់ទី ៩ ៖ ផែនការសកម្មភាពជាតិ ២០១៨-២០២១ របស់ប្រទេសហុងកុងដង់

- ការបង្កើតលេខាធិការដ្ឋាន ៖ លេខាធិការដ្ឋាននៅក្នុងគណៈកម្មាធិការជាតិស្តីពីស្ត្រីរបស់ហុងកុងដង់ ត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យលើការពិនិត្យតាមដាន និងវាយតម្លៃផែនការសកម្មភាពជាតិ ក្រោមជំនួយពីភ្នាក់ងារសហប្រជាជាតិ UN Women និងជំនួយមូលនិធិពីរដ្ឋាភិបាលហ្វាំងឡង់។

- ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ ៖ ក្របខណ្ឌជាប្រព័ន្ធមួយត្រូវបានបង្កើតឡើង ដោយផ្អែកលើអភិក្រមបែបចូលរួមនៅថ្នាក់ជាតិ ដែលជំរុញការចូលរួមរបស់ភាគីទាំងអស់ក្នុងការអនុវត្តសកម្មភាពរបស់ផែនការសកម្មភាពជាតិ។ ក្របខណ្ឌនេះមានសូចនាករបែប SMART ដើម្បីវាស់វែងវឌ្ឍនភាពឆ្ពោះទៅរកគោលដៅយុទ្ធសាស្ត្រ លទ្ធផលចុងក្រោយ និងលទ្ធផលក្នុងឆ្នាំ។

- ការទទួលខុសត្រូវ និងការប្រមូលទិន្នន័យ ៖ ក្របខណ្ឌនេះបញ្ជាក់ពីស្ថាប័នដែលទទួលខុសត្រូវលើការអនុវត្ត និងការប្រមូលទិន្នន័យពីសូចនាករសមិទ្ធកម្ម ក៏ដូចជាកំណត់ភាពញឹកញាប់នៃការប្រមូលទិន្នន័យ។

- ការធ្វើរបាយការណ៍ពីវឌ្ឍនភាព ៖ ភាគីអនុវត្តន៍ត្រូវសហការគ្នាលើការពិនិត្យតាមដាន និងវាយតម្លៃវឌ្ឍនភាពនៃគំនិតផ្តួចផ្តើមដែលពួកគេទទួលខុសត្រូវ។ ភាគីអនុវត្តន៍នីមួយៗត្រូវដាក់របាយការណ៍វឌ្ឍនភាពតាមដំណាក់កាលជូនមន្ត្រីបង្គោលដែលទទួលខុសត្រូវលើការពិនិត្យតាមដាន និងវាយតម្លៃផែនការនេះទាំងមូល។

## ប្រអប់ទី ១០ ៖ ផែនការសកម្មភាពជាតិលើកទី ៣ (២០១៩-២០២៤) របស់ប្រទេសអៀកឡង់

ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃនៃផែនការសកម្មភាពជាតិអៀកឡង់ មានសមាសភាគជាច្រើន ៖

- ក្រុមត្រួតពិនិត្យ ៖ ធានាការសម្របសម្រួល និងគណនេយ្យភាពក្នុងពេលអនុវត្ត។

- ក្របខណ្ឌពិនិត្យតាមដាន ៖ ក្របខណ្ឌពិនិត្យតាមដានគ្រប់ជ្រុងជ្រោយមានសូចនាករជាក់លាក់ និងអាចវាស់វែងបាន ដែលតាមដានវឌ្ឍនភាពទាំងផ្នែកគុណភាព និងផ្នែកបរិមាណក ដូចជា សកម្មភាព និងលទ្ធផលចុងក្រោយ ដោយផ្តោតសំខាន់លើការប្រមូលទិន្នន័យដើមគ្រាសម្រាប់ការតាមដានប្រកបដោយប្រសិទ្ធភាព។

- ការវាយតម្លៃពីខាងក្រៅ ៖ ទីប្រឹក្សាឯករាជ្យធ្វើការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ ក្នុងឆ្នាំ ២០២១ ដើម្បីជាមគ្គុទេសក៏ដល់ការកែសម្រួលផែនការនេះ សម្រាប់រយៈពេល ២ ឆ្នាំចុងក្រោយ។ ការវាយតម្លៃចុងគ្រានៅចុងបញ្ចប់នៃផែនការសកម្មភាពជាតិលើកទី ៣ វាយតម្លៃវឌ្ឍនភាពលើផែនការជាច្រើន។

- ការបន្សុីគ្នានឹងអនុសញ្ញា CEDAW ៖ ផែនការសកម្មភាពជាតិបន្សុីគ្នានឹងកាតព្វកិច្ចរបស់អៀកឡង់ ក្រោមអនុសញ្ញា CEDAW និងកាតព្វកិច្ចក្នុងការពិនិត្យជាសកលតាមដំណាក់កាល (UPR) ដោយសង្គមស៊ីវិលត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងការធ្វើរបាយការណ៍ស្តីពីការប្តេជ្ញាចិត្តទាំងនេះ ក្រោមអនុសាសន៍ទូទៅលេខ ៣០ របស់គណៈកម្មាធិការ CEDAW។

- ការបន្សុីគ្នានឹងគោលនយោបាយជាតិ ៖ សកម្មភាព និងសូចនាកររបស់ផែនការសកម្មភាពជាតិ ត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយជាតិផ្សេងៗ ដូចជា គោលនយោបាយដែលពាក់ព័ន្ធនឹងស្ត្រី និងក្មេងស្រី ពលករទេសន្តរប្រវេសក៏ សុខុមាលភាពអន្តរវប្បធម៌ (intercultural health) និងការរៀបចំថវិកាដែលឆ្លើយតបនឹងយេនឌ័រ។

- ហានិភ័យ និងការសន្មត ៖ ផែនការនេះកត់សម្គាល់កត្តាសំខាន់ៗដែលនាំឱ្យទទួលបានជោគជ័យ ដូចជា ការគាំទ្រផ្នែកនយោបាយ និងការវិភាជថវិកា។ ហានិភ័យផ្សេងៗ ដូចជា ភាពមានកម្រិតនៃធនធាន និងការចូលរួមរបស់ភាគីពាក់ព័ន្ធ ត្រូវបានដោះស្រាយ ដើម្បីឱ្យគោលបំណងនៃផែនការអាចសម្រេចបាន។

### ស្វ័យវាយតម្លៃ

១.ការពិនិត្យឡើងវិញលើគោលបំណងនៃផែនការសកម្មភាពជាតិ និងគោលដៅយុទ្ធសាស្ត្រកម្រិតតំបន់

- តើយើងយល់ពីរបៀបដែលកម្មវិធី និងសកម្មភាពផ្សេងៗដែលមានលម្អិតនៅក្នុងផែនការសកម្មភាពជាតិ រួមចំណែកដល់ការសម្រេចបានគោលដៅយុទ្ធសាស្ត្រនៃផែនការសកម្មភាពតំបន់អាស៊ាន ឬទេ?
- តើមានភាពខុសគ្នា ឬគម្លាតរវាងផែនការថ្នាក់ជាតិ និងផែនការថ្នាក់តំបន់ ដែលចាំបាច់ត្រូវលើកឡើង ឬទេ?

២.ការកំណត់គោលដៅដែលច្បាស់លាស់ និងជាក់លាក់

- តើយើងបានកំណត់គោលដៅជាក់លាក់នៅក្នុងផែនការសកម្មភាពជាតិ ដែលបន្សុីគ្នានឹងគោលបំណងយុទ្ធសាស្ត្រនៃផែនការសកម្មភាពតំបន់អាស៊ាន ឬទេ?
- តើគោលដៅទាំងនេះត្រូវបានលើកឡើងយ៉ាងច្បាស់លាស់ និងមិនស្រពិចស្រពិល ឬទេ?

៣.ប្តូរពីផ្តោតលើលទ្ធផលក្នុងឆ្នាំ ទៅផ្តោតលើលទ្ធផលចុងក្រោយ

- តើគោលដៅត្រូវបានបន្សុីគ្នានឹងប្រសិទ្ធភាពនៃផែនការសកម្មភាពជាតិ និងការរួមចំណែករបស់ផែនការនេះដល់ផលជះជារួមនៃផែនការសកម្មភាពតំបន់អាស៊ាន ឬទេ?
- តើសូចនាករមានបង្ហាញទាំងលទ្ធផលក្នុងឆ្នាំបែបបរិមាណ និងការផ្លាស់ប្តូរបែបគុណភាព និងភាពប្រសើរឡើងនៃលទ្ធផលចុងក្រោយផ្នែកសង្គម ឬទេ?

៤.ការបញ្ចៀសការបំភ្លៃ

- តើគោលដៅដែលបានជ្រើសរើស មានតុល្យភាព ដោយមិនមានការសង្កត់ធ្ងន់ខ្លាំងពេកលើទិដ្ឋភាពមួយជាងទិដ្ឋភាពផ្សេងទៀត ឬទេ?
- តើគោលដៅត្រូវបានកំណត់ឡើង ដើម្បីបញ្ចៀសការដោះដូរអវិជ្ជមាន (trade-off) ដូចជា ការសម្រេចបានក្រុមគោលដៅធំ ប៉ុន្តែមិនខ្វល់ពីគុណភាពនៃលទ្ធផលចុងក្រោយ ឬទេ?
- តើមានការពិចារណាពីយោបល់ត្រឡប់ និងទស្សនៈយល់ឃើញពីភាគីពាក់ព័ន្ធចម្រុះ ដើម្បីបញ្ចៀសការបំភ្លៃដោយអចេតនា ឬទេ?

៥.ការបន្សុី និងការកែសម្រួលជាបន្តបន្ទាប់

- តើមានការបង្កើតយន្តការសម្រាប់ការពិនិត្យឡើងវិញជាប្រចាំ និងការបន្សុីគោលដៅទៅនឹងការប្រែប្រួលតម្រូវការ និងបរិបទ ឬទេ?
- តើមានប្រការចែងសម្រាប់អនុញ្ញាតឱ្យធ្វើកែសម្រួលគោលដៅ ដោយផ្អែកលើរបាយការណ៍វឌ្ឍនភាព ការវាយតម្លៃ និងលទ្ធផលពីការពិគ្រោះយោបល់ ឬទេ?
- តើមានផែនការផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធអំពីការកែសម្រួលគោលដៅនៃផែនការសកម្មភាពជាតិ ដែលបន្សុីគ្នានឹងផែនការសកម្មភាពតំបន់អាស៊ាន ឬទេ?

## ៤.បង្កើតយន្តការសម្រាប់ការពិនិត្យតាមដាន និងធ្វើរបាយការណ៍

យន្តការស្ថាប័នសម្រាប់ការពិនិត្យតាមដានវឌ្ឍនភាពនៃផែនការសកម្មភាពជាតិ គឺសំខាន់ណាស់ ព្រោះយន្តការនេះបង្ហាញឱ្យឃើញច្បាស់លាស់ពីគណនេយ្យភាព។ ការរៀបចំវេទិកាសម្ព័ន្ធដែលមានសក្តានុពល គឺមានភាពសម្បូរបែប ទៅតាមក្រុមការងារ ឬគណៈកម្មាធិការអន្តរស្ថាប័នដែលចូលរួមពីតំណាងមកពីរដ្ឋាភិបាល និងសង្គមស៊ីវិល។ យន្តការពិនិត្យតាមដានមួយអាចស្ថិតក្នុងវេទិកាសម្ព័ន្ធមានស្រាប់របស់រដ្ឋាភិបាល ឬជាអាជ្ញាធរដែលត្រូវបានបង្កើតឡើងតាមផ្លូវច្បាប់ (established statutory authority) ឬបំពេញមុខងារឯករាជ្យ។

ក្នុងការជានាការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព យន្តការនេះនឹងបង្កើនគណនេយ្យភាពលើការពិនិត្យតាមដានផែនការសកម្មភាពជាតិ។ ការចាត់តាំងអ្នកសម្របសម្រួលផ្នែកគោលនយោបាយ និងរដ្ឋបាល អាចជួយធ្វើឱ្យមានសុខដុមរមនាដល់កិច្ចខិតខំប្រឹងប្រែងចម្រុះ ដាក់បញ្ចូលព័ត៌មាន និងការសម្របសម្រួលទំនាក់ទំនងផ្ទៃក្នុង និងខាងក្រៅ។

យន្តការរាយការណ៍ស្ដីពីផែនការសកម្មភាពជាតិ គួរផ្ដល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់ និងរៀបចំបានគ្រប់ជ្រុងជ្រោយ ដោយមានការកំណត់ច្បាស់ពីតួនាទី ដើម្បីរក្សាគណនេយ្យភាព និងការសម្របសម្រួលឱ្យរលូន។ ចំណុចនេះពាក់ព័ន្ធនឹងការកំណត់បុគ្គលដែលត្រូវទទួលខុសត្រូវលើការប្រមូលទិន្នន័យ ការដាក់របាយការណ៍submission) ការវិភាគ និងការធ្វើរបាយការណ៍។ កិច្ចការនេះអាចរួមបញ្ចូលការកំណត់តួនាទីសម្របសម្រួលវគ្គឆ្លុះបញ្ចាំង និងការចងក្រងឧទាហរណ៍ជាក់ស្ដែង។

ចិរវេលានៃផែនការសកម្មភាពជាតិជះឥទ្ធិពលលើភាពញឹកញាប់នៃការប្រមូលទិន្នន័យ ដូចជា ពេលដែលត្រូវប្រមូលទិន្នន័យលទ្ធផលចុងក្រោយ ទិន្នន័យពាក់កណ្ដាលអាណត្តិ និងទិន្នន័យលទ្ធផលក្នុងឆ្នាំ។ ការបញ្ជាក់ពីចន្លោះពេលសម្រាប់ការធ្វើរបាយការណ៍ ជួយធានាលើការធ្វើរបាយការណ៍បានទាន់ពេលវេលា និងស៊ីសង្វាក់គ្នា។ ការបន្សុីគ្នាក្នុងការធ្វើរបាយការណ៍ឱ្យស្របនឹងវដ្ដដែលមានស្រាប់ ដូចជា វដ្ដនេះការធ្វើរបាយសម្រាប់អនុសញ្ញា CEDAW ឬក្របខណ្ឌពាក់ព័ន្ធផ្សេងទៀត នឹងធានាសង្គត់ភាព និងភាពទាន់ពេលវេលាក្នុងការដាក់បញ្ជូនទិន្នន័យ។

ការប្រើប្រាស់ទម្រង់បែបបទសាមញ្ញ និងស្ដង់ដារ សម្រាប់ការដាក់បញ្ជូនទិន្នន័យ ផ្ដល់ភាពងាយស្រួលដល់អ្នកអនុវត្តន៍ និងភាគីពាក់ព័ន្ធក្នុងការធ្វើរបាយការណ៍ពីវឌ្ឍនភាព និងលទ្ធផលរកឃើញ។ ទម្រង់បែបបទគួរស្របទៅតាមគំរូដែលមានស្រាប់ និងប្រើប្រាស់ដោយក្រសួងពាក់ព័ន្ធ។ ការបញ្ចូលផ្នែកជាក់លាក់មួយស្ដីពីការអនុវត្តផែនការសកម្មភាពជាតិ ទៅក្នុងទម្រង់គំរូដែលមានស្រាប់ អាចបង្ការមិនឱ្យមានភាពត្រួតគ្នា។ ទម្រង់បែបបទមានលក្ខណៈជាលិខិតស្នាម ឬអេឡិចត្រូនិកនោះទេ ទម្រង់បែបបទទាំងនោះគួរកំណត់ទៅតាមអ្វីដែលសមស្របបំផុតនឹង ការធ្វើរបាយការណ៍ និងបរិបទជាតិ។ ឧបករណ៍ដែលផ្ដល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់ ក្នុងការរក្សាទុក និងវិភាគទិន្នន័យ ដូចជា Google forms និង spreadsheet ក្នុងកម្មវិធី Excel ផ្ដល់ភាពងាយស្រួល និងអាចប្រើប្រាស់បានដោយមនុស្សភាគច្រើន និងអាចសម្រួលដល់ការគ្រប់គ្រងទិន្នន័យ។

**ការគ្រប់គ្រងភាពមានកម្រិតនៃទិន្នន័យបែងចែកតាមភេទ**

ខាងក្រោមនេះជាដំណោះស្រាយមួយចំនួន សម្រាប់ភាពមិនពេញលេញក្នុងការប្រមូលទិន្នន័យបែងចែកតាមភេទ ដោយរដ្ឋាភិបាល ៖

- ការកសាងការយល់ដឹង និងការបណ្ដុះបណ្ដាល ៖ ធ្វើយុទ្ធនាការកសាងការយល់ដឹង និងផ្ដល់វគ្គបណ្ដុះបណ្ដាលសម្រាប់មន្ត្រីរដ្ឋាភិបាលដែលទទួលខុសត្រូវលើការប្រមូលទិន្នន័យ និងធ្វើរបាយការណ៍។ ធ្វើយ៉ាងណាឱ្យពួកគេយល់ពីសារៈសំខាន់នៃទិន្នន័យបែងចែកតាមភេទ សម្រាប់ប្រសិទ្ធភាពនៃផែនការសកម្មភាពជាតិ និងការបន្សុីផែនការនោះទៅនឹងការប្ដេជ្ញាចិត្តជាអន្តរជាតិ ដូចជា អនុសញ្ញា CEDAW។ ផ្ដល់ការណែនាំស្ដីពីរបៀបប្រមូល និងវិភាគទិន្នន័យទាំងនោះ។

- គំរូរបាយការណ៍ដែលផ្ដល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់ ៖ បង្កើតគំរូរបាយការណ៍ដែលមានស្ដង់ដារ និងផ្ដល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់ ដែលជំរុញឱ្យទីភ្នាក់ងាររដ្ឋាភិបាលដាក់បញ្ចូលទិន្នន័យបែងចែកតាមភេទទៅក្នុងរបាយការណ៍ជាប្រចាំរបស់ខ្លួន ដើម្បីឱ្យក្លាយទៅជាទម្លាប់។

- បណ្ដាញជើងឯកខាងទិន្នន័យ (data champion network) ៖ បង្កើតបណ្ដាញ "ជើងឯកខាងទិន្នន័យ" នៅក្នុងទីភ្នាក់ងាររដ្ឋាភិបាលដែលធ្វើការស្វែងរកមតិគាំទ្រ ឱ្យមានទិន្នន័យបែងចែកតាមភេទ និងចែករំលែកការអនុវត្តល្អបំផុតក្នុងចំណោមសហការី។

- ការសហការជាមួយសង្គមស៊ីវិល ៖ ចាប់ដៃគូសហការជាមួយអង្គការសង្គមស៊ីវិលក្នុងមូលដ្ឋាន ដើម្បីប្រមូលទិន្នន័យបែងចែកតាមភេទ តាមរយៈការស្ទង់មតិក្នុងសហគមន៍ ឬសកម្មភាពផ្សព្វផ្សាយក្នុងមូលដ្ឋាន និងទាញប្រយោជន៍ពីបណ្ដាញ និងជំនាញមានស្រាប់របស់ពួកគេ។

- ការពិនិត្យឡើងវិញ និងការផ្តល់យោបល់ត្រឡប់ជាប្រចាំ ៖ ធ្វើការពិនិត្យឡើងវិញជាប្រចាំលើដំណើរការប្រមូលទិន្នន័យ និងស្នើសុំយោបល់ត្រឡប់ពីបុគ្គលិក ដើម្បីកំណត់រកឧបសគ្គក្នុងការបែងចែកទិន្នន័យតាមភេទ។ ប្រើប្រាស់យោបល់ត្រឡប់ដែលទទួលបាន ដើម្បីកែសម្រួល និងកែលម្អនីតិវិធីប្រមូលទិន្ន ន័យ។

- ក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយ ៖ ធានាថា ក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយជាតិ គាំទ្រការប្រមូល និងការប្រើប្រាស់ទិន្នន័យបែងចែកតាមភេទ។ ចំណុចនេះអាចពាក់ព័ន្ធនឹងការធ្វើវិសោធនកម្មបទបញ្ញត្តិជាធរមាន ដើម្បីពង្រឹងសារៈសំខាន់នៃការប្រមូលទិន្នន័យដែលគិតគូពីយេនឌ័រ។

**ការបំពេញបន្ថែមលើទិន្នន័យបែបបរិមាណ**

លើកកម្ពស់យន្តការរាយការណ៍ តាមរយៈការបញ្ចូលឧទាហរណ៍ជាក់ស្តែងជាមួយនឹងទិន្នន័យបែបបរិមាណ។ ចំណុចនេះពាក់ព័ន្ធនឹងការដាក់បញ្ចូលសូចនាករជាចំនួន និងតួលេខជាមួយនឹងករណីសិក្សាបែបគុណភាព។ ករណីសិក្សាជួយបកស្រាយនិន្នាការដែលលេចឡើងក្នុងទិន្នន័យ និងជួយបន្ថែមបរិបទ និងភាពស៊ីជម្រៅ។ វាអាចគូសបញ្ជាក់ពីលទ្ធផលរបស់គម្រោងលើក្រុមងាយរងគ្រោះ បង្ហាញពីការរួមចំណែករបស់ដៃគូ និងផ្តល់ការយល់ដឹងខុសគ្នាពីផលជះនៅក្នុងមូលដ្ឋាន។

យន្តការរាយការណ៍គ្រប់ជ្រុងជ្រោយមិនត្រឹមតែជួយដល់ការប្រមូលទិន្នន័យប្រកបដោយប្រសិទ្ធភាពប៉ុណ្ណោះទេ ថែមទាំងលើកកម្ពស់ការពិភាក្សាប្រកបដោយអត្ថន័យ ក្នុងការធ្វើសេចក្តីសម្រេច និងការកែលម្អជាបន្តបន្ទាប់លើគំនិតផ្តួចផ្តើមរបស់ផែនការសកម្មភាពជាតិ។ ដំណើរការធ្វើរបាយការណ៍បានក្លាយជាកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដែលជំរុញឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន និងពន្លឿនគោលដៅនៃផែនការសកម្មភាពជាតិ។

### ការបង្កើតយន្តការក្នុងស្ថាប័នសម្រាប់ការពិនិត្យតាមដាន៖ ស្វ័យវាយតម្លៃ

១.ការទទួលខុសត្រូវច្បាស់លាស់ និងគណនេយ្យភាព
- តើមានការកំណត់តួនាទី និងការទទួលខុសត្រូវច្បាស់លាស់ក្នុងយន្តការស្ថាប័នសម្រាប់ការពិនិត្យតាមដាវឌ្ឍនភាពនៃផែនការសកម្មភាពជាតិ ឬទេ?
- តើមានការបញ្ជាក់ច្បាស់ពីគណនេយ្យភាពសម្រាប់ការពិនិត្យតាមដាន ឬទេ?

២.ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព
- តើមានការទទួលស្គាល់ពីតួនាទីដ៏សំខាន់របស់យន្តការត្រួតពិនិត្យក្នុងការត្រួតពិនិត្យដោយប្រសិទ្ធភាពលើការអនុវត្តផែនការសកម្មភាពជាតិ ឬទេ?
- តើយន្តការនេះទទួលបានធនធានគ្រប់គ្រាន់ដើម្បីគ្របដណ្តប់លើវិសាលភាពរបស់ផែនការជាតិ ដែលបន្សុីគ្នានឹងចក្ខុវិស័យធំទូលាយរបស់ផែនការសកម្មភាពតំបន់អាស៊ាន ឬទេ?

៣.ការសម្របសម្រួល និងការផ្សព្វផ្សាយ
- តើមានការចាត់តាំងអ្នកសម្របសម្រួលផ្នែកនយោបាយ និងផ្នែករដ្ឋបាល ដើម្បីសុខដុមរមនាលើកិច្ចខិតខំប្រឹងប្រែង ដាក់បញ្ចូលព័ត៌មាន និងសម្រួលដល់ការផ្សព្វផ្សាយផ្ទៃក្នុង និងខាងក្រៅ ឬទេ?
- តើអ្នកសម្របសម្រួលនោះមានសមត្ថភាពពេញលេញក្នុងការចាត់ចែងកិច្ចការចម្រុះ និងពង្រឹងកិច្ចសហការប្រកបដោយប្រសិទ្ធភាព ឬទេ?
- តើអ្នកសម្របសម្រួលនោះយល់ពីសារៈសំខាន់នៃការបន្សុីគ្នាទៅនឹងគោលការណ៍ និងគោលដៅនៃផែនការសកម្មភាពតំបន់អាស៊ាន ឬទេ?
- តើអ្នកសម្របសម្រួលនោះអាចធ្វើរបាយការណ៍ដោយប្រសិទ្ធភាពអំពីវឌ្ឍនភាពនៃផែនការសកម្មភាពជាតិ នៅកម្រិតអាស៊ាន និងរួមចំណែកដល់ការពិនិត្យតាមដានថ្នាក់តំបន់បានដែរ ឬទេ?

# ៥.ទទួលស្គាល់ពីគុណតម្លៃនៃការពិនិត្យតាមដានលើយោបល់ត្រឡប់ នៅក្នុងដំណើរការអនុវត្តគោលនយោបាយ

ការពិនិត្យតាមដាន មានសារៈសំខាន់ជាងការវាយតម្លៃ។ ការពិនិត្យតាមដានមានសារៈសំខាន់សម្រាប់ដំណើរការអនុវត្តគោលនយោបាយ និងជំរុញឱ្យមានការត្រួតពិនិត្យផ្ទៃក្នុងយ៉ាងស៊ីជម្រៅ ដែលត្រូវមានការសួរសំណួរ សំខាន់ៗមួយចំនួន ៖ តើយុទ្ធសាស្ត្រអ្វីខ្លះដែលផ្តល់សមិទ្ធផលវិជ្ជមាន? តើត្រូវកែលម្អអ្វីខ្លះ? ដំណើរការនេះ អាច ផ្តល់យោបល់ត្រឡប់ដែលបង្ហាញពីទាំងភាពជោគជ័យ និងបញ្ហាប្រឈមតាមរយៈការកំណត់ផ្នែកដែលត្រូវកែលម្អ និងការជួយដល់ការបង្កើតយុទ្ធសាស្ត្រដែលមានភាពបត់បែន។

ការពិនិត្យតាមដានបង្កើនភាពអង់អាចរបស់អាជ្ញាធរ តាមរយៈការផ្តល់ទិន្នន័យសម្បូរបែប និងការអនុវត្តល្អបំផុតដែលបង្ហាញពីការអនុវត្តគោលនយោបាយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ចំណេះដឹងទាំងនេះជួយជំរុញការស្វែងរកមតិគាំទ្រដល់គម្រោង ឬមូលបទជាក់លាក់។ នៅពេលប្រឈមនឹងអ្នកជេញដោល ឬភាគីពាក់ព័ន្ធ ភស្តុតាងទាំងនេះអាចជួយដល់សេចក្តីសម្រេចនានា។ បន្ថែមពីនេះ ការពិនិត្យតាមដានជួយបង្ហាញពីទិសដៅគោលនយោបាយនាពេលអនាគត ដោយផ្អែកលើឱកាសដែលមាន និងបញ្ហាប្រឈមដែលលេចឡើង។ ការចូលរួមក្នុងដំណើរការនេះដោយចេតនា អាចបង្កើនការប្តេជ្ញាចិត្តចំពោះនិរន្តរភាព ក៏ដូចជាទាក់ទាញការគាំទ្រពីម្ចាស់ជំនួយដែលមានចក្ខុវិស័យរួមក្នុងការជំរុញឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងមូលដ្ឋាន។

### ស្វ័យវាយតម្លៃលើការផ្តល់យោបល់ត្រឡប់ នៅក្នុងដំណើរការអនុវត្តគោលនយោបាយ

១.ការដាក់បញ្ចូលយោបល់ត្រឡប់ទៅក្នុងការកសាងគោលនយោបាយ
- តើមានយន្តការរាយការណ៍ជាប្រចាំនៅក្នុងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ដែលផ្តល់ព័ត៌មានថ្មីៗ ដល់អ្នកធ្វើសេចក្តីសម្រេចចិត្តស្តីពីវឌ្ឍនភាព លទ្ធផលចុងក្រោយ និងបញ្ហាប្រឈមក្នុងពេលអនុវត្តផែនការសកម្មភាពជាតិ ឬទេ?
- តើព័ត៌មានថ្មីៗទាំងនេះត្រូវបានកែសម្រួលដោយរបៀបណា ដើម្បីជួយដល់ការកែសម្រួលគោលនយោបាយ ដោយផ្អែកលើចំណេះដឹងជាក់ស្តែង?

២.ការកែសម្រួលគោលនយោបាយដោយផ្អែកលើយោបល់ត្រឡប់
- តើមានការពង្រឹងអភិក្រមបែបសហការ ក្នុងករណីដែលយោបល់ត្រឡប់ដែលប្រមូលបានពីប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ពីភាគីពាក់ព័ន្ធ និងអ្នកជំនាញក្នុងការធ្វើសេចក្តីសម្រេច ឬទេ?
- តើការពិភាក្សាផ្តល់មតិយោបល់ត្រឡប់ត្រូវបានដាក់បញ្ចូលដោយរបៀបណាទៅក្នុងការពិនិត្យគោលនយោបាយ ដើម្បីទាញប្រយោជន៍ពីទស្សនៈយល់ឃើញចម្រុះ និងបង្កើនប្រសិទ្ធភាពគោលនយោបាយ?

៣.ការធ្វើសេចក្តីសម្រេចចិត្តបែបរួមគ្នា ដោយផ្អែកតាមយោបល់ត្រឡប់
- តើប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ត្រូវបានបង្កើតឡើងដើម្បីបង្ហាញតម្រូវការចំពោះមុខ និងបញ្ហាប្រឈមនាពេលខាងមុខ ដែលបានរកឃើញក្នុងពេលអនុវត្ត ឬទេ? តើបញ្ហាទាំងនេះត្រូវបានដោះស្រាយដោយរបៀបណានៅក្នុងការកែសម្រួលគោលនយោបាយ?
- តើមានយន្តការសម្រាប់ផ្តល់ដំណោះស្រាយឆាប់រហ័សលើបញ្ហាសំខាន់ៗដែលលេចចេញពីការផ្តល់យោបល់ត្រឡប់ ដើម្បីបង្ការភាពរាំងស្ទះដែលអាចលេចឡើង ឬទេ?

៤.ការបំពេញតម្រូវការចំពោះមុខ ដោយផ្អែកតាមយោបល់ត្រឡប់
- តើប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ត្រូវបានបង្កើតឡើងដើម្បីបង្ហាញតម្រូវការចំពោះមុខ និងបញ្ហាប្រឈមនាពេលខាងមុខ ដែលបានរកឃើញក្នុងពេលអនុវត្ត ឬទេ? តើបញ្ហាទាំងនេះត្រូវបានដោះស្រាយដោយរបៀបណានៅក្នុងការកែសម្រួលគោលនយោបាយ?
- តើមានយន្តការសម្រាប់ផ្តល់ដំណោះស្រាយឆាប់រហ័សលើបញ្ហាសំខាន់ៗដែលលេចចេញពីការផ្តល់យោបល់ត្រឡប់ ដើម្បីបង្ការភាពរាំងស្ទះដែលអាចលេចឡើង ឬទេ?

## ៦.ផ្តល់ធនធានដល់ផែនការពិនិត្យតាមដាន និងវាយតម្លៃ

ដើម្បីឱ្យការអនុវត្តមានប្រសិទ្ធភាព ផែនការពិនិត្យតាមដាន និងវាយតម្លៃត្រូវការធនធានគ្រប់គ្រាន់ និងធនធានមនុស្សសមស្រប។ គួរបង្កើតគណៈកម្មាធិការ ឬក្រុមការងារមួយសម្រាប់ត្រួតពិនិត្យផែនការនេះ និងមានបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាល នៅក្នុងនាយកដ្ឋានពាក់ព័ន្ធ។ គួរកំណត់ច្បាស់ពីការទទួលខុសត្រូវ និងចែងក្នុងការទទួលខុសត្រូវការងារ និងគោលការណ៍ណែនាំសម្រាប់នាយកដ្ឋានពាក់ព័ន្ធ។ ការបណ្តុះបណ្តាលស្តីពីការប្រមូលទិន្នន័យ ការវិភាគ ការធ្វើរបាយការណ៍ និងស្តង់ដារចាំបាច់ គួរប្រើអភិក្រមដែលមានសង្គតភាព។ ការមាននីតិវិធីគ្រប់ជ្រុងជ្រោយសម្រាប់ការងារទិន្នន័យក៏សំខាន់ដែរ ចំណែកការធ្វើព័ត៌មានបច្ចុប្បន្នភាពជាប្រចាំនឹងធានាសុក្រឹតភាព និងភាពពាក់ព័ន្ធ។

ខាងក្រោមនេះជាយុទ្ធសាស្រ្តមួយចំនួនសម្រាប់ក្រសួងពាក់ព័ន្ធផ្តល់ធនធានដល់ការពិនិត្យតាមដាន និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព ៖

១. ដាក់បញ្ចូលសកម្មភាពជាក់លាក់សម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ ទៅក្នុងផែនការសកម្មភាពជាតិ ៖ ជំហានជាក់លាក់ និងអាចធ្វើបាន សម្រាប់ការពិនិត្យតាមដាន ការធ្វើរបាយការណ៍ និងការសម្របសម្រួល គួររៀបរាប់ពីក្តីរំពឹងទុកចំពោះក្រសួងនីមួយៗ ពាក់ព័ន្ធនឹងការប្រមូលទិន្នន័យ ភាពញឹកញាប់នៃការធ្វើរបាយការណ៍ និងការសហការជាមួយស្ថាប័នរដ្ឋាភិបាលផ្សេងទៀត។ នៅពេលមានការលម្អិតពីការទទួលខុសត្រូវទាំងនេះនៅក្នុងផែនការសកម្មភាពជាតិ វានឹងផ្តល់ភាពងាយស្រួលជាងមុនដល់ក្រសួងពាក់ព័ន្ធក្នុងការបែងចែកធនធានចាំបាច់ ដើម្បីបំពេញការប្តេជ្ញាចិត្តរបស់ខ្លួន។

២. ថវិកាសម្រាប់ការប្រមូល និងវិភាគទិន្នន័យ ៖ ជាញឹកញាប់ សកម្មភាពពិនិត្យតាមដាន និងវាយតម្លៃ ទាមទារធនធានហិរញ្ញវត្ថុសម្រាប់ការប្រមូលទិន្នន័យ ការវិភាគ និងការធ្វើរបាយការណ៍។ ក្រសួងពាក់ព័ន្ធគួរវិភាជថវិការបស់ខ្លួនសម្រាប់គោលបំណងទាំងនេះ (ដូចជា ការវិនិយោគលើបច្ចេកវិទ្យា ឧបករណ៍ និងការបណ្តុះបណ្តាលចាំបាច់ដើម្បីធានាការគ្រប់គ្រងទិន្នន័យប្រកបដោយប្រសិទ្ធភាព)។

៣. ការកសាងសមត្ថភាព ៖ ការកសាងសមត្ថភាពរបស់ក្រសួងពាក់ព័ន្ធក្នុងការពិនិត្យតាមដាន និងវាយតម្លៃ ជាការវិនិយោគដ៏សំខាន់។ វិភាគធនធានសម្រាប់កម្មវិធីបណ្តុះបណ្តាល និងកសាងសមត្ថភាព ដើម្បីបង្កើនជំនាញរបស់បុគ្គលិកដែលទទួលខុសត្រូវលើការពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីឱ្យពួកគេអាចចូលរួមសហការប្រកបដោយប្រសិទ្ធភាព។

៤. យន្តការផ្តល់យោបល់ត្រឡប់ ៖ អនុវត្តយន្តការផ្តល់យោបល់ត្រឡប់នៅក្នុងផែនការសកម្មភាពជាតិដើម្បីបង្ហាញពីចំណេះដឹងរបស់ក្រសួងពាក់ព័ន្ធ ស្តីពីធនធានដែលត្រូវការចាំបាច់សម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ។ ការពិនិត្យ និងការវាយតម្លៃតាមកាលកំណត់ អាចជួយកំណត់ផ្នែកដែលត្រូវការធនធានបន្ថែម ឬការកែសម្រួល។

៥. ការស្វែងរកមតិគាំទ្រឱ្យមានការវិភាជធនធាន ៖ ក្រសួងពាក់ព័ន្ធអាចស្វែងរកមតិគាំទ្រឱ្យមានការវិ ភាជធនធានសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ តាមរយៈការគូសបញ្ជាក់ពីសារៈសំខាន់នៃសកម្មភាពទាំងនេះ សម្រាប់ភាពជោគជ័យនៃផែនការសកម្មភាពជាតិ។ ការបង្ហាញភស្តុតាងស្តីពីផលជះនៃការពិនិត្យតាមដាន និងវាយតម្លៃ លើការសម្រេចបានគោលបំណងនៃផែនការសកម្មភាពជាតិ អាចជាទឡ្ហីករណ៍ដ៏គួរឱ្យជឿជាក់ សម្រាប់ការធានាប្រភពមូលនិធិចាំបាច់។

## ៧.បញ្ហាប្រឈមដែលបន្តលេចឡើង និងដំណោះស្រាយដែលមានប្រសិទ្ធភាព នៅក្នុងការពិនិត្យតាមដាន និងការធ្វើរបាយការណ៍

ភស្តុតាងជាសកលបង្ហាញពីបញ្ហាប្រឈមដែលបន្តលេចឡើងនៅក្នុងការពិនិត្យតាមដាន និងវាយតម្លៃផែនការសកម្មភាពជាតិ។ បញ្ហាប្រឈមទាំងនេះមានរៀបរាប់លម្អិតក្នុងរូបទី ១១ រួមជាមួយនឹងដំណោះស្រាយដែលមានប្រសិទ្ធភាពបំផុតសម្រាប់បញ្ហាប្រឈមនីមួយៗ។ ជារួម ការដោះស្រាយបញ្ហាប្រឈមក្នុងការពិនិត្យតាមដាន និងការធ្វើរបាយការណ៍ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ទាមទារអភិក្រមពហុវិស័យដែលរួមបញ្ចូលធន្ទៈនយោបាយ ការពិនិត្យតាមដានដោយផ្អែកតាមទិន្នន័យ និងការពង្រឹងស្ថាប័ន។

### រូបទី ១១ ៖ បញ្ហាប្រឈមមួយចំនួនដែលបន្តលេចឡើងនៅក្នុងការពិនិត្យតាមដាន និងការធ្វើរបាយការណ៍

បញ្ហាប្រឈម | ធនធានមានកម្រិត

ដំណោះស្រាយ

វិភាជធនធានប្រកបដោយយុទ្ធសាស្ត្រដើម្បីធានាដំណើរការពិនិត្យតាមដានគ្រប់ជ្រុងជ្រោយដែលគ្រប  ដណ្តប់លើបុគ្គលិកជំនាញ ឧបករណ៍បច្ចេកទេស និងជំនួយថវិកា។

---

បញ្ហាប្រឈម | មជ្ឈការ

ដំណោះស្រាយ

កំណត់មន្ត្រីបង្គោលឱ្យទទួលខុសត្រូវលើការរៀបចំ សម្របសម្រួល និងគ្រប់គ្រងដំណើរការពិនិត្យតាមដាន ដើម្បីធានាសង្គត់ភាព និងគណនេយ្យភាព។

---

បញ្ហាប្រឈម | ភាពមិនច្បាស់លាស់ក្នុងការសម្របសម្រួល

ដំណោះស្រាយ

រៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយសមស្របដែលបង្ហាញព័ត៌មានសំខាន់ៗ ចាត់តាំងភាគីទទួលខុសត្រូវ និងរៀបរាប់ពីមធ្យោបាយផ្សព្វផ្សាយដែលមានប្រសិទ្ធភាព។

---

បញ្ហាប្រឈម | កង្វះការរៀនសូត្រក្នុងការធ្វើរបាយការណ៍

ដំណោះស្រាយ

បង្កើតវេទិកាមួយដែលលើកទឹកចិត្តឱ្យមានកិច្ចសហការឆ្លងនាយកដ្ឋាន និងផ្តល់លទ្ធភាពឱ្យភាគីនានា ដូចជា សង្គមស៊ីវិល ចែករំលែកការអនុវត្តល្អបំផុត ដើម្បីបង្កើតវប្បធម៌នៃការបន្តរៀនសូត្រ។

---

បញ្ហាប្រឈម | ភាពលំបាកក្នុងការប្រមូលទិន្នន័យ

ដំណោះស្រាយ

ធ្វើឱ្យនីតិវិធីប្រមូលទិន្នន័យមានលក្ខណៈសាមញ្ញ ដើម្បីធានាថា ពេលវេលា និងកិច្ចខិតខំប្រឹងប្រែងដែលបានលះបង់ ផ្តល់ចំណេះដឹងគួរជាទីគាប់ចិត្ត។ ផ្តល់ការបណ្តុះបណ្តាលគ្រប់ជ្រុងជ្រោយដើម្បីបង្កើនសុក្រឹតភាពនៃការប្រមូលទិន្នន័យ និងការផ្សព្វផ្សាយ។

---

បញ្ហាប្រឈម | សូចនាករដែលមានលក្ខណៈស្មុគស្មាញ

ដំណោះស្រាយ

ដាក់បញ្ចូលសូចនាករទៅក្នុងអាណត្តិ និងសកម្មភាពរបស់ទីភ្នាក់ងារពាក់ព័ន្ធ ដើម្បីឱ្យសូចនាករទាំងនោះមានភាពពាក់ព័ន្ធ និងបង្ហាញពីការរួមចំណែកដោយផ្ទាល់ដល់គោលបំណងធំ។

---

បញ្ហាប្រឈម | មិនសូវមានភាពច្បាស់លាស់ក្នុងការបកស្រាយសកម្មភាពនៅក្នុងផែនកា

ដំណោះស្រាយ

កំណត់អាទិភាពលើការអនុវត្តគោលនយោបាយ តាមរយៈការកំណត់រកឧបសគ្គក្នុងការអនុវត្ត។ បង្វែរពីការផ្តោតលើការពិនិត្យតាមដានដែលផ្តោតលើលទ្ធផលក្នុងឆ្នាំ ទៅជាការវាយតម្លៃផលជៈនៃសកម្មភាពក្នុងផែនការ។

---

បញ្ហាប្រឈម | កង្វះការវាយតម្លៃផលជះ

ដំណោះស្រាយ

បំពេញបន្ថែមលើការវាស់វែងបែបបរិមាណ ជាមួយនឹងសូចនាករបែបគុណភាព ដើម្បីវាយតម្លៃជារួមលើការផ្លាស់ប្តូរដែលចង់បាន ដោយផ្តល់ការយល់ដឹងកាន់តែចម្រុះស្តីពីផលជះ។

# ៨.បន្សុំក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃដែលមានស្រាប់ ទៅនឹងគោលការណ៍ថ្នាក់តំបន់

ចំណុចសកម្មភាពខាងក្រោមពាក់ព័ន្ធខ្លាំងនឹងប្រទេសដែលបានបង្កើតផែនការសកម្មភាពជាតិ អមជាមួយនឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃគ្រប់ជ្រុងជ្រោយ និងមានភាពបត់បែន។ ការផ្តល់មតិយោបល់ផ្សេងៗអាចជួយឱ្យបន្សុំគ្នានឹងផែនការសកម្មភាពតំបន់អាស៊ាន។

- ការរួមបញ្ចូលសូចនាករជាយុទ្ធសាស្ត្រ ៖ កំណត់សូចនាករសមិទ្ធកម្មសំខាន់ៗនៅក្នុងក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃដែលមានស្រាប់ដែលអាចបន្សុំទៅនឹងគោលបំណងថ្នាក់តំបន់។ បញ្ចូលសូចនាករថ្នាក់តំបន់មួយចំនួនទៅក្នុងសូចនាករថ្នាក់ជាតិដែលបានកំណត់។

- ការតាមដានស្របគ្នា ៖ អនុវត្តប្រព័ន្ធតាមដានស្របគ្នានៅក្នុងក្របខណ្ឌដែលមានស្រាប់ ដើម្បីពិនិត្យតាមដានវឌ្ឍនភាពដែលពាក់ព័ន្ធនឹងផែនការសកម្មភាពតំបន់អាស៊ាន ដើម្បីធានាការតាមដានដោយមិនដាក់បន្ទុកលើប្រព័ន្ធទាំងមូល។

- ការធ្វើរបាយការណ៍ដែលផ្តោតលើផែនការសកម្មភាពថ្នាក់តំបន់ ៖ រៀបចំរបាយការណ៍ ឬបង្កើតផ្នែកដាក់លាក់មួយនៅក្នុងរចនាសម្ព័ន្ធរាយការណ៍ដែលមានស្រាប់។ របាយការណ៍ទាំងនេះអាចគូសបញ្ជាក់ពីវឌ្ឍនភាព បញ្ហាប្រឈម និងសមិទ្ធផលដែលពាក់ព័ន្ធនឹងផែនការសកម្មភាពតំបន់អាស៊ាន ក៏ដូចជាធានាការអនុលោមតាមក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃទាំងមូល។

- សិក្ខាសាលាជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ ៖ រៀបចំសិក្ខាសាលា ឬក្រុមការងារជាមួយភាគីពាក់ព័ន្ធ ដើម្បីរិះរកវិធីថ្មីៗដើម្បីប្រមូលទិន្នន័យដែលពាក់ព័ន្ធនឹងផែនការសកម្មភាពតំបន់អាស៊ាន នៅក្នុងដំណើរការពិនិត្យតាមដាន និងវាយតម្លៃដែលមានស្រាប់ ដោយមិនបង្កការរំខានខ្លាំងដល់ប្រព័ន្ធដែលមានស្រាប់។

- ការប្រមូលទិន្នន័យសម្រាប់គោលបំណង ២ ៖ អនុវត្តដំណើរការប្រមូលទិន្នន័យដែលមានស្រាប់ឱ្យអស់ពីលទ្ធភាព តាមរយៈការកែសម្រួលចំណុចទិន្នន័យដើម្បីជាជំនួយដល់ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃដែលមានស្រាប់ និងលក្ខខណ្ឌតម្រូវថ្នាក់តំបន់។ ចំណុចនេះនឹងកាត់បន្ថយភាពត្រួតគ្នា។

- ក្រុមបំពេញមុខងារចម្រុះ ៖ បង្កើតក្រុមបំពេញមុខងារចម្រុះដែលផ្តោតតែលើការប្រមូលទិន្នន័យ និងការធ្វើរបាយការណ៍សម្រាប់ផែនការសកម្មភាពតំបន់អាស៊ាន ក៏ដូចជាសហការជាមួយក្រុមពិនិត្យតាមដាន និងវាយតម្លៃដែលមានស្រាប់។ ចំណុចនេះនឹងធានាបានអភិក្រមចំគោលដៅ។

- ការពិនិត្យតាមដានជាប្រចាំលើក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ ៖ កំណត់ពេលពិនិត្យតាមដានជាប្រចាំលើក្របខណ្ឌនេះ ដើម្បីស្វែងរកឱកាសពង្រឹង និងបង្កើនជាអតិបរមានូវការដាក់បញ្ចូលទិន្នន័យដែលពាក់ព័ន្ធនឹងផែនការសកម្មភាពតំបន់អាស៊ាន ដោយមិនដាក់បន្ទុកខ្លាំងលើប្រព័ន្ធដែលមានស្រាប់។

- ភាពបត់បែនក្នុងការកែសម្រួល ៖ រៀបចំក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃប្រកបដោយភាពបត់បែន ដើម្បីសម្របទៅតាមការប្រែប្រួលអាទិភាពក្នុងតំបន់ ឬបញ្ហាប្រឈមក្នុងតំបន់ ដើម្បីធានាថា ក្របខណ្ឌនេះនៅតែឆ្លើយតបនឹងការប្រែប្រួលតម្រូវការ។

- ការរ៉ាយរ៉ាប់ដំណើររឿង ៖ ប្រើប្រាស់បច្ចេកទេសរ៉ាយរ៉ាប់ដំណើររឿងដើម្បីបង្ហាញទិន្នន័យស្តីពីផែនការសកម្មភាពតំបន់អាស៊ាន នៅក្នុងរបាយការណ៍ដែលមានស្រាប់ ដើម្បីបង្កើនការចូលរួម និងការយល់ដឹងរបស់ភាគីពាក់ព័ន្ធ។

# ៩.គណនាចំណាយ និងរៀបចំថវិកាសម្រាប់ផែនការសកម្មភាពជាតិ

លំហាត់គណនាចំណាយសម្រាប់ផែនការសកម្មភាពជាតិគួរចាប់ផ្តើមធ្វើក្រោយការបញ្ចប់ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ និងការកំណត់ច្បាស់ពីតួនាទី និងការទទួលខុសត្រូវ និងការបង្កើតរចនាសម្ព័ន្ធសម្របសម្រួល និងអនុវត្ត។ ការគណនាចំណាយ និងថវិកាសម្រាប់ផែនការសកម្មភាពជាតិ ជួយដល់ការប្រែក្លាយស្តង់ដារស្ត្រី សន្តិភាព និងសន្តិសុខ ទៅជាសកម្មភាពដែលអាចអនុវត្តបាន អាចវាស់វែងបាន និងអាចទទួលខុសត្រូវបាន ស្របតាមអាទិភាពជាតិ (ប្រអប់ទី ១១)[72]។ ជំហានទាំងនេះផ្តល់មូលដ្ឋានព័ត៌មានដល់យុទ្ធសាស្ត្រកៀរគរមូលនិធិ និងជួយឱ្យទទួលបានការសន្យាផ្តល់ថវិកាពីរដ្ឋាភិបាល[73]។ មន្ត្រីអនុវត្តន៍គួរយល់ច្បាស់ពីឧបករណ៍ផ្សេងៗសម្រាប់ការគណនាចំណាយ[74]។

## ប្រអប់ទី ១១ ៖ សារៈសំខាន់នៃកញ្ចប់ថវិកាសម្រាប់ផែនការសកម្មភាពជាតិ

> នៅឆ្នាំ ២០១៧ ក្នុងចំណោម ៦៨ ប្រទេសដែលមានផែនការសកម្មភាពជាតិ មានតែ ១៦ ប្រទេសប៉ុណ្ណោះដែលមានកញ្ចប់ថវិកា។ ក្នុងឆ្នាំ ២០១៧ Gajendra Kuma Thakur រដ្ឋលេខាធិការក្រសួងសន្តិភាព និងស្ថាបនាឡើងវិញនៃប្រទេសនេប៉ាល់ បានថ្លែងក្នុងសិក្ខាសាលាស្តីពីការគណនាចំណាយ និងការរៀបចំថវិកាសម្រាប់ផែនការសកម្មភាពជាតិ ក្នុងន័យបំផុសចំណាប់អារម្មណ៍ថា "ផែនការដែលគ្មានថវិកា ប្រៀបដូចជាថយន្តដែលគ្មានប្រេងឥន្ធនៈ"។
>
> ប្រភព ៖ GNWP, 2017b

ជម្រើសទី ១ សម្រាប់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់កម្មវិធីសកម្មភាពជាតិសំខាន់ៗ គឺការដាក់បញ្ចូលកម្មវិធីទាំងនេះទៅក្នុងផែនការ និងថវិការបស់ក្រសួង នាយកដ្ឋាន និងស្ថាប័នសាធារណៈផ្សេងទៀត ដែលធ្វើការងារពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ។ ចំណុចនេះនឹងលើកកម្ពស់ភាពម្ចាស់ការថ្នាក់ជាតិ និងផ្តល់ភាពប្រាកដប្រជាស្តីពីធនធានដែលមាន ឱ្យតែថវិកាប្រចាំឆ្នាំរបស់ការិយាល័យពាក់ព័ន្ធមានមូលនិធិដែលត្រូវ។ វិភាជធនធានហិរញ្ញវត្ថុជាសូចនាករដ៏ល្អសម្រាប់ការវាយតម្លៃការអនុវត្តផែនការ[75]។ ចំណុចចាប់ផ្តើមសម្រាប់ការបន្សីគ្នានឹងការវិភាជថវិការបស់រដ្ឋាភិបាល ទាមទារការវិភាគ និងការរៀបចំផែនការល្អិតល្អន់ ព្រមទាំងមានទំនាក់ទំនងជាប្រចាំជាមួយមន្ត្រីពាក់ព័ន្ធ។

យោងតាមការស្ទង់មតិរដ្ឋសមាជិកអង្គការសហប្រជាជាតិចំនួន ២៣ ប្រទេស រូបទី ១២ បង្ហាញពីប្រភពមូលនិធិផ្សេងៗសម្រាប់ផែនការសកម្មភាពជាតិ[76]។

### រូបទី ១២ ៖ សមាសភាគទូទៅនៃជំនួយមូលនិធិសម្រាប់ផែនការសកម្មភាពជាតិ




ខាងក្រោមនេះជាសំណួរសំខាន់ៗមួយចំនួនដែលត្រូវលើកឡើងក្នុងពេលគណនាចំណាយ ៖

- តើសកម្មភាពនេះអាចទទួលបានមូលនិធិពីក្រសួងណាមួយ ឬទេ?
- ប្រសិនបើក្រសួងនោះមិនអាចផ្តល់ជំនួយមូលនិធិដល់សកម្មភាពនេះបាន តើអាចមានការរៀបចំប្រភពហិរញ្ញប្បទានផ្សេងទៀតដែរ ឬទេ?

ការគណនាចំណាយសម្រាប់ផ្នែកអាទិភាពមួយនៃផែនការសកម្មភាពជាតិ ចាប់ផ្តើមពីការជ្រើសរើសលទ្ធផលក្នុងឆ្នាំ រួមជាមួយនឹងសកម្មភាពពាក់ព័ន្ធ និងចំណាយដែលពាក់ព័ន្ធ និងការប៉ាន់ស្មានចំណាយក្នុងមួយឯកតានៃផ្នែកនីមួយៗ។ បន្ទាប់ពីបានកំណត់ និងបញ្ចូលចំណាយក្នុងមួយឯកតា និងចំនួនឯកតាដែលចង់បាន ទៅក្នុងគម្រូឯកសារនៅក្នុងតារាងទី ៩ វានឹងគណនាចំណាយសរុបដោយស្វ័យប្រវត្តិ គិតជារូបិយវត្ថុក្នុងស្រុក និងរូបិយវត្ថុមួយផ្សេងទៀត (ឧ. ប្រាក់ដុល្លារអាមេរិក ឬប្រាក់អឺរ៉ូ)។ ក្រៅពីនេះ ចាំបាច់ត្រូវបញ្ជាក់ព័ត៌មានស្តីពីទីភ្នាក់ងារអនុវត្តន៍សំខាន់ៗដែលទទួលខុសត្រូវលើសកម្មភាពជាក់លាក់ និងប្រភពមូលនិធិសម្រាប់សកម្មភាពនីមួយៗនៅក្នុងប្រអប់តារាង ២ ចុងក្រោយ[77]។

តារាងទី ៩ ៖ ការគណនាចំណាយក្នុងមួយឯកតានៃសកម្មភាពសម្រាប់បញ្ចូលទៅក្នុងថវិកា

| ឯកតា | ចំណាយក្នុងមួយឯកតា | ចំនួនឯកតា | ចំណាយសរុប (គិតជារូបិយវត្ថុក្នុងស្រុក) | ការបម្លែងទៅជាប្រាក់ដុល្លារអាមេរិក | ចំណាយសរុបគិតជាដុល្លារអាមេរិក | ភាគរយនៃចំណាយសរុប | ទីភ្នាក់ងារ អនុវត្ត/ក្រសួង/ទីភ្នាក់ងារ | ការពណ៌នាប្រភពមូល និធិ (ជាតិ/ផ្ទៃក្នុង/ ផ្សេងៗ) |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |

## ចំណុចសំខាន់ៗ ៖

ការគណនាចំណាយជាការពិនិត្យតថភាពក្នុងការរៀបចំថវិកាគ្រប់គ្រងជ្រុងជ្រោយ និងជាក់ស្តែង សម្រាប់ផែនការសកម្មភាពជាតិ។ បើគ្មានការកំណត់ចំណាយ និងការលៃលកធនធានដែលត្រូវការចាំបាច់ សកម្មភាពនឹងមិនអាចអនុវត្តបានឡើយ ហើយផែនការសកម្មភាពជាតិនឹងនៅត្រឹមតែជាផែនការ។ ការគណនាចំណាយជួយធានាធនធានជាក់លាក់សម្រាប់ការអនុវត្ត កំណត់អាទិភាពលើសកម្មភាពជាក់លាក់ និងកំណត់រកគម្លាតធនធាន ក៏ដូចជាចំណុចរាំងស្ទះចំពោះមុខ ឬចំណុចរាំងស្ទះដែលអាចលេចឡើង។ ការគណនាចំណាយបង្កើនភាពម្ចាស់ការ និងគណនេយ្យភាពក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ ដែលទទួលខុសត្រូវលើការអនុវត្តសកម្មភាពនីមួយៗ។

# ១០.កំណត់រកប្រភពហិរញ្ញប្បទានថ្មីៗ

ហិរញ្ញប្បទានថ្មីៗអាចគាំទ្រដល់ការកៀរគរធនធានសម្រាប់ផែនការសកម្មភាពជាតិ។ ជម្រើសមួយគឺការដាក់បញ្ចូលសមាសភាគសំខាន់ៗនៃការរៀបចំថវិកាដែលឆ្លើយតបនឹងយេនឌ័រ ទៅក្នុងការរៀបចំថវិកាសម្រាប់ផែនការសកម្មភាពជាតិ។ ការរៀបចំថវិកាដែលឆ្លើយតបនឹងយេនឌ័រមិនមែនជាលំហាត់ស្របគ្នានោះទេ។ វាពាក់ព័ន្ធនឹងការវិភាគយេនឌ័រក្នុងថវិកា ដើម្បីធានាការរៃអង្គាស និងបែងចែកធនធានហិរញ្ញវត្ថុទៅតាមតម្រូវការជាក់លាក់ និងតួនាទីរបស់ស្ត្រី និងបុរស[78]។ ចំណុចនេះតម្រូវឱ្យមានការប្រមូលទិន្នន័យបែងចែកតាមភេទដែលគ្រប់ជ្រុងជ្រោយ ស្តីពីលទ្ធផលផ្នែកហិរញ្ញវត្ថុ និងការផ្តល់បច្ចេកទេស។

ការចរចាជាមួយមន្ត្រីបង្គោលនៅក្នុងក្រសួងហិរញ្ញវត្ថុ និងក្រសួងផែនការអភិវឌ្ឍ ដែលធ្វើការងារពាក់ព័ន្ធនឹងកំណែទម្រង់ការគ្រប់គ្រងវិស័យសាធារណៈ អាចជំរុញការអនុវត្តការរៀបចំថវិកាដែលឆ្លើយតបនឹងយេនឌ័រ ក្នុងពេលវិភាជថវិកា និងការតាមដានការចំណាយលើអន្តរាគមន៍ស្ត្រីស្ត្រី សន្តិភាព និងសន្តិសុខ។ ការពិគ្រោះយោបល់ជាមួយស្ថាប័នសាធារណៈដែលទទួលខុសត្រូវលើផែនការអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងក្របខណ្ឌហិរញ្ញវត្ថុថ្នាក់ជាតិ (ក្នុងចំណោមក្របខណ្ឌគោលនយោបាយផ្សេងទៀត) ជាជម្រើសបន្ថែមផ្សេងទៀតសម្រាប់ការបញ្ជ្រាបការវិភាគថវិកាសម្រាប់ផែនការសកម្មភាពជាតិតាមស្ថាប័ន ទៅក្នុងកញ្ចប់ថវិការបស់ក្រសួង ទីភ្នាក់ងារ និងនាយកដ្ឋានពាក់ព័ន្ធ។

ខាងក្រោមនេះជាមធ្យោបាយសំខាន់ៗមួយចំនួន ៖

- ការដាក់បញ្ចូលកម្មវិធីផែនការសកម្មភាពជាតិក្នុងពេលរៀបចំផែនការសម្រាប់កម្មវិធីស្ត្រីពីស្ត្រី សន្តិភាព និងសន្តិសុខរបស់អង្គការអន្តរជាតិធំៗ។
- ការរៀបចំសំណើសម្រាប់កម្មវិធី និងគម្រោង ដោយផ្អែកលើភាពជាដៃគូជាមួយអ្នកផ្តល់ជំនួយមូលនិធិក្នុងវិស័យឯកជន។
- ការវាយតម្លៃតម្រូវការរួមគ្នាជាមួយអង្គការសង្គមស៊ីវិល ត្រូវបានចែករំលែកជាមួយតួអង្គជាតិ និងអន្តរជាតិដើម្បីទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ។
- ការទាញប្រយោជន៍ពីហិរញ្ញប្បទានអាកាសធាតុ ដើម្បីគាំទ្រដល់ក្រុមជួបការលំបាកដែលប្រឈមនឹងការគំរាមកំហែងដោយអាកាសធាតុ។
- សក្តានុពលសម្រាប់មូលបត្របំណុលសង្គម និងមូលបត្របំណុលអភិវឌ្ឍ (social and development impact bonds) ដែលទាញប្រយោជន៍ពីមូលធនឯកជនដើម្បីផ្តល់មូលនិធិដល់គម្រោងសង្គម ដូចជា គម្រោងដែលពាក់ព័ន្ធនឹងរបៀបវារៈស្ត្រីពីស្ត្រី សន្តិភាព និងសន្តិសុខ[79]និងឧបករណ៍ហិរញ្ញវត្ថុអ៊ីស្លាម ដូចជា sukuks។
- កិច្ចសហប្រតិបត្តិការត្បូង-ត្បូង សម្រាប់បណ្តាប្រទេសនានាដើម្បីចែករំលែកចំណេះដឹង ជំនាញ និងគំនិតផ្តួចផ្តើមដែលទទួលបានជោគជ័យ។
- ពន្ធបៃតង (green taxes) សម្រាប់ផ្តល់មូលនិធិដល់ការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងបញ្ហាពាក់ព័ន្ធដែលអាចបង្កផលប៉ះពាល់លើរបៀបវារៈស្ត្រីពីស្ត្រី សន្តិភាព និងសន្តិសុខ។
- បង្កើតមូលបត្របំណុលអនិកជនដើម្បីកៀរគរប្រាក់សន្សំរបស់ពួកគេសម្រាប់ការអភិវឌ្ឍ[80]
- យកពន្ធលើសំបុត្រយន្តហោះ ដើម្បីកៀរគរមូលនិធិសម្រាប់សកម្មភាពជាក់លាក់ដែលបានកំណត់ក្នុងផែនការសកម្មភាពជាតិ។ មធ្យោបាយនេះបានផ្តល់ចំណូលជាង ១,៥ ពាន់លានដុល្លារដល់ប្រទេសមួយចំនួន ដូចជា បេណាំង កាម៉េរូន ម៉ាលី ម៉ូរីទូស និងនីហ្គ័រ[81]។
- ការផ្គូរផ្គងមូលនិធិតាម ៣ វិធី ដែលផ្គូរផ្គងរវាងម្ចាស់ជំនួយជាមួយក្រុមហ៊ុនធំៗ ជាមួយមូលនិធិ និងជាមួយអង្គការផ្សេងទៀតរួមមាន អង្គការសហប្រជាជាតិ[82]។

ជារួម នៅពេលពិចារណាពីការបង្កើតផែនការសកម្មភាពជាតិស្ត្រីពីស្ត្រី សន្តិភាព និងសន្តិសុខ រដ្ឋសមាជិកអាស៊ានអាចផ្តោតជាចម្បងលើការកសាងយល់ដឹងពាក់ព័ន្ធនឹងរបៀបវារៈស្ត្រីពីស្ត្រី សន្តិភាព និងសន្តិសុខ និងសង្កត់ធ្ងន់ពីសារៈសំខាន់នៃការបង្កើតផែនការសកម្មភាពជាតិនៅថ្នាក់ជាតិ។ ក្នុងពេលព្រាងផែនការសកម្មភាពជាតិ វាជាការសំខាន់ដែលត្រូវកំណត់ឱ្យច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នសម្របសម្រួលដែលមានទស្សនវិស័យរួម និងបង្កើតយន្តការមួយសម្រាប់រក្សាការទទួលខុសត្រូវរបស់អ្នកអនុវត្តន៍។ ក្រៅពីនេះ ផែនការសកម្មភាពជាតិគួរពង្រឹងដោយក្របខណ្ឌតក្កភាពដែលរៀបរាប់ពីលទ្ធផលចុងក្រោយជាក់លាក់ ស្របតាមផែនការសកម្មភាពតំបន់អាស៊ានស្ត្រីពីស្ត្រី សន្តិភាព និងសន្តិសុខ ក៏ដូចជាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិស្ត្រីពីស្ត្រី សន្តិភាព និងសន្តិសុខ។ លើសពីនេះ ការចូលរួមយ៉ាងសកម្មរបស់អង្គការសង្គមស៊ីវិល និងការបង្កើតក្របខណ្ឌពិនិត្យតាមដាន និងការធ្វើរបាយការណ៍ និងឧបករណ៍សម្រាប់ការអនុវត្ត ក៏សំខាន់ផងដែរ។ ចំណុចចុងក្រោយ ផែនការសកម្មភាពជាតិដែលបង្កផលជះកម្រិតខ្ពស់ គឺ ចាំបាច់ត្រូវមានកញ្ចប់ថវិកាដែលគ្របដណ្តប់គ្រប់ជ្រុងជ្រោយលើធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានបច្ចេកទេស ដែលត្រូវការចាំបាច់សម្រាប់ការអនុវត្តសកម្មភាពដែលបានកំណត់ ប្រកបដោយប្រសិទ្ធភាព។

# ការអនុវត្តផែនការសកម្មភាពជាតិ

ក្រោយបញ្ចប់ដំណើរការពង្រាងផែនការសកម្មភាពជាតិ សកម្មភាពបន្ទាប់សម្រាប់ការអនុវត្តផែនការសកម្មភាពជាតិ រួមមានការផ្តល់សុពលភាព ការអនុវត្តដោយរដ្ឋបាលថ្នាក់ជាតិ និងការប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ។ ការប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ ផ្តល់សញ្ញាជាផ្លូវការសម្រាប់ការត្រៀមអនុវត្តកិច្ចផែនការសម្មភាព និងសកម្មភាពពាក់ព័ន្ធ ។ ជំហានទី ៣ រំលេចសារៈសំខាន់នៃការបន្តកសាងការយល់ដឹង និងអភិវឌ្ឍសមត្ថភាពរបស់ ភាគីពាក់ព័ន្ធសំខាន់ៗ និងការចងក្រងការអនុវត្តល្អ និងមេរៀនក្នុងពេលអនុវត្ត ដើម្បីពង្រឹងការរៀនសូត្រ និងផ្តល់មូលដ្ឋានព័ត៌មានដល់ការអន្តរាគមន៍នាពេលអនាគត។

## ១.ផ្តល់សុពលភាពដល់សេចក្តីព្រាងផែនការសកម្មភាពជាតិ អនុម័ត និងប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ

ក្រោយបញ្ចប់ការព្រាងផែនការសកម្មភាពជាតិ និងបញ្ចូលមតិយោបល់ពីដៃគូពាក់ព័ន្ធ សមាជិកគណៈកម្មាធិការធ្វើសេចក្តីព្រាងផែនការអាចធ្វើការកោះប្រជុំដើម្បី[83]៖

- ពិនិត្យមើលគោលបំណង និងសកម្មភាពនានាដើម្បីឱ្យមានសុខដុមរមនានឹងក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយជាតិដែលមានស្រាប់ ក៏ដូចជាផែនការសកម្មភាពតំបន់អាស៊ាន
- ធានាថាមានការពណ៌នាច្បាស់លាស់ដើម្បីគាំទ្រដល់ក្របខណ្ឌគំរូតក្កភាព ( ឡុកហ្វ្រេម )
- ធានាថា តួនាទីសំខាន់ៗរបស់ភាគីទទួលខុសត្រូវ ស្របនឹងអាណត្តិ និងអាទិភាពរបស់ពួកគេ
- ពិនិត្យថា មានការរៀបចំថវិកាជាមួយនឹងធនធានគ្រប់គ្រាន់ និង/ឬការបន្សុីគ្នានឹងថវិកាដែលមានស្រាប់ និងវិភាជធនធានរបស់ភាគីទទួលខុសត្រូវ
- ផ្តល់សុពលភាពដល់យន្តការពិនិត្យតាមដាន និងវាយតម្លៃដែលបានស្នើឡើង ដើម្បីធានាថា យន្តការនោះមានភាពជាក់ស្តែង និងអាចអនុវត្តបាន ក៏ដូចជាធានាថា សូចនាករដែលបានកំណត់ អាចបង្ហាញច្បាស់ពីការងាររបស់ស្ថាប័នផ្សេងៗ ហើយទិន្នន័យគឺអាចរកបាន ឬអាចប្រមូលបាន។

បន្ទាប់ពីគណៈកម្មាធិការធ្វើសេចក្តីព្រាងផែនការបានពិនិត្យមើល និងអនុម័តសេចក្តីព្រាងរួចហើយ គួរធ្វើយ៉ាងណាឱ្យមានការអនុម័តពីរដ្ឋាភិបាល តាមរយៈក្រសួងដែលដឹកនាំការអនុវត្តផែនការសកម្មភាពតំបន់អាស៊ាន ក៏ដូចជាតាមរយៈភាគីពាក់សំខាន់ៗទាំងអស់។

លក្ខណៈពិសេសៗនៃការប្រកាសផ្សព្វផ្សាយផែនការសកម្មភាពជាតិ ប្រែប្រួលទៅតាមបរិបទប្រទេសនីមួយៗ។ ជាទូទៅ ការប្រកាសជាផ្លូវការនេះគួររៀបចំជាព្រឹត្តិការណ៍លេចធ្លោតាមប្រព័ន្ធផ្សព្វផ្សាយ ដោយមានការចូលរួមដោយមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល និងតំណាងរបស់ក្រុមគោលដៅផ្សេងៗ។ ការប្រកាសជាផ្លូវការនេះគួរមានការផ្សព្វផ្សាយតាមប្រព័ន្ធឃោសនា និងការផ្សព្វផ្សាយជាសាធារណៈស្តីពីលទ្ធផលចុងក្រោយ និងកម្មវិធីសំ ខាន់ៗ អមជាមួយនឹងការបន្តកសាងការយល់ដឹងស្តីពីវឌ្ឍនភាព និងផែនការបន្ត។

រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលអាចផលិត និងចែកចាយឯកសារដែលផ្តល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់ ដូចជា ខិតប័ណ្ណ និងបដា ដល់សាលារៀន អង្គការតាមសហគមន៍ និងសាធារណជន។

កិច្ចខិតខំប្រឹងប្រែងអនុវត្តតាំងពីដំបូង

ការអនុវត្តផែនការសកម្មភាពជាតិពឹងផ្អែកខ្លាំងទៅលើការឆ្លើយតបនឹងតថភាពជាតិ[84]។ ខាងក្រោមនេះជា អនុសាសន៍មួយចំនួន សម្រាប់ការអនុវត្តសកម្មភាពនៅឆ្នាំដំបូង[85]៖

- ការចាត់តាំងមន្ត្រីបង្គោលជាផ្លូវការ នៅក្នុងស្ថាប័នសម្របសម្រួល និងអនុវត្ត ដើម្បីដំណើរការកម្មវិធី
- ការបង្កើតផែនការអនុវត្ត ដែលបញ្ចូលជាផ្លូវការនូវសកម្មភាពអាទិភាពទៅក្នុងផែនការរបស់ក្រសួងសាមីនិងមានធនធានបច្ចេកទេស និងធនធានហិរញ្ញវត្ថុសម្រាប់ឱ្យមន្ត្រីបង្កើតជាចលនករ និងកសាងកិច្ចសហការ។
- ការកំណត់តួនាទី និងការទទួលខុសត្រូវរបស់តួអង្គថ្នាក់ជាតិ និងតួអង្គថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។
- ការប្រមូលទិន្នន័យដើមគ្រាសម្រាប់ការពិនិត្យតាមដាន ការធ្វើរបាយការណ៍ និងការវាយតម្លៃ ដើម្បីវាស់វែងវឌ្ឍនភាព ដូចជា ការគូសបង្ហាញពីសូចនាករដែលបានបង្កើតឡើងសម្រាប់របាយការណ៍ផ្សេងទៀត។ ឧ. ចំណុចដៅ ១៦.៧ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ពាក់ព័ន្ធដោយផ្ទាល់នឹងការបង្កើត និងការអនុវត្តផែនការសកម្មភាពជាតិ។
- ការរៀបចំយុទ្ធសាស្ត្រកៀរគរធនធានដើម្បីទាញប្រយោជន៍ពីប្រភពហិរញ្ញប្បទានថ្មីៗ និងលើកកម្ពស់ការរៀបចំផែនការ និងការរៀបចំថវិកាដែលឆ្លើយតបនឹងយេនឌ័រ ដើម្បីលើកកម្ពស់គណនេយ្យភាព និងប្រសិទ្ធភាពក្នុងការវិភាជធនធានហិរញ្ញវត្ថុ។
- ការប្រើប្រាស់ការគាំទ្រផ្នែកបច្ចេកទេសដែលផ្តល់ដោយមន្ត្រីបង្គោលយេនឌ័ររបស់អាស៊ាន និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតដែលធ្វើការពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ។
- ការចូលរួមក្នុងគំនិតផ្តួចផ្តើមឈានមុខរបស់អាស៊ានដែលពាក់ព័ន្ធនឹងផែនការសកម្មភាពតំបន់អាស៊ាន។
- ការកំណត់រកការគាំទ្រសំខាន់ៗដល់ការស្វែងរកមតិគាំទ្រ និងការកសាងសមត្ថភាព ដើម្បីធានាការអនុវត្តផែនការសកម្មភាពជាតិ ឱ្យបានជាប្រាកដ។

ខាងក្រោមនេះជាលក្ខខណ្ឌមួយចំនួនដែលជួយដល់ការអនុវត្តផែនការសកម្មភាពជាតិប្រកបដោយប្រសិទ្ធភាព[86]៖

- ការប្តេជ្ញាចិត្តកម្រិតខ្ពស់របស់រដ្ឋាភិបាល
- ភាពជាដៃគូជិតស្និទ្ធជាមួយសង្គមស៊ីវិល សហគមន៍សិក្សាស្រាវជ្រាវ និងអង្គការថ្នាក់តំបន់ និងអង្គការពហុភាគី
- ស្ថាប័នសម្របសម្រួលអន្តរទីភ្នាក់ងារ (អន្តរក្រសួង) ដែលមានប្រសិទ្ធភាព និងប្រសិទ្ធផល
- វិភាជថវិកាគ្រប់គ្រាន់ពីថវិកាជាតិសម្រាប់សកម្មភាពអាទិភាព
- នីតិវិធីប្រកបដោយគណនេយ្យភាព ជាមួយនឹងសូចនាករគ្រប់គ្រាន់សម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ
- ការផ្តល់គ្រឿងលើកទឹកចិត្តជាវិជ្ជមានដើម្បីជំរុញការប្រតិបត្តិដល់អ្នកអនុវត្តន៍កម្រិតខ្ពស់
- ការកសាងសមត្ថភាពរបស់ភាគីពាក់ព័ន្ធជាបន្តបន្ទាប់
- ការប្រមូលការអនុវត្តល្អដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់អ្នកតាក់តែងគោលនយោបាយ និងសម្រាប់ការផ្សព្វផ្សាយយ៉ាងទូលំទូលាយ។

## ២.កសាងការយល់ដឹងស្តីពីផែនការសកម្មភាពជាតិ រក្សាការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល និងលើកកម្ពស់សមត្ថភាពរបស់ភាគីពាក់ព័ន្ធសំខាន់ៗ

ការកសាងការយល់ដឹង គឺសំខាន់ក្នុងការស្វែងរកការគាំទ្រដល់ការអនុវត្តផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ឧ. យុទ្ធនាការអប់រំ វេទិកាសាធារណៈ និងការគ្របដណ្តប់ក្នុងប្រព័ន្ធផ្សព្វផ្សាយ)។ យើងអាចនាំយកសំឡេងរបស់ស្ត្រីដែលរងផលប៉ះពាល់ដោយសារជម្លោះ តាមរយៈបង្ហាញរឿងរ៉ាវជាក់ស្តែងរបស់ និងសង្កត់ធ្ងន់ពីសារៈសំខាន់នៃការដាក់បញ្ចូលស្ត្រីទាំងនោះទៅក្នុងគ្រប់

ដំណាក់កាលនៃការចរចាសន្តិភាព ដំណើរការក្រោយពេលជម្លោះ ដំណើរការកសាងសន្តិភាព និងដំណើរការរក្សាសន្តិភាព។ ក្រៅពីនេះ ការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធចម្រុះ ដូចជា អង្គការសង្គមស៊ីវិល រដ្ឋាភិបាល និងស្ថាប័នអន្តរជាតិ គឺមានសារៈសំខាន់ណាស់។ តាម រយៈកិច្ចសហការ និងកិច្ចសន្ទនា យើងអាចកសាងបណ្តាញដ៏រឹងមាំសម្រាប់ទ្រទ្រង់ការអនុវត្តផែនការសកម្មភាពជាតិ ដើម្បីធានាការប្រកាន់ខ្ជាប់សិទ្ធិ និងការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រី នៅក្នុងការកសាងសន្តិភាព។

អភិក្រមថ្មីមួយសម្រាប់ការបំផុសចំណាប់អារម្មណ៍ និងកៀរគរការគាំទ្រ គឺការប្រើប្រាស់បច្ចេកវិទ្យា និងវេទិកាក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម។ ការទាញប្រយោជន៍ពីការផ្សព្វផ្សាយតាមប្រព័ន្ធឌីជីថល ធ្វើឱ្យអង្គការ/ស្ថាប័ន និងបុគ្គលម្នាក់ៗអាចចូលដល់ក្រុមគោលដៅទូលំទូលាយ និងអាចផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងសិទ្ធិស្ត្រី ផលប៉ះពាល់នៃជម្លោះមកលើស្ត្រី និងសារៈសំខាន់នៃសមភាពយេនឌ័រក្នុងការកសាងសន្តិភាព។

ក្រោយការប្រកាសផ្សព្វផ្សាយផែនការសកម្មភាពជាតិមិនយូរប៉ុន្មាន កម្មវិធីកសាងការយល់ដឹង និងផ្សព្វផ្សាយ នឹងជួយជំរុញការផ្សព្វផ្សាយព័ត៌មានលម្អិតស្តីពីលក្ខណៈសំខាន់ៗនៃផែនការសកម្មភាពជាតិ ដល់ដៃគូអនុវត្តន៍។

ដំណើរការនេះអាចរួមបញ្ចូល ៖

- ការរៀបចំកិច្ចសន្ទនា ឬកិច្ចពិភាក្សាក្រុមរបស់មន្ត្រីសំខាន់ៗនៅកម្រិតរដ្ឋាភិបាល ដែលដើរតួនាទីសំខាន់ក្នុងការអនុវត្តផែនការសកម្មភាពជាតិប្រកបដោយជោគជ័យ។
- ការរៀបចំកម្មវិធីកសាងសមត្ថភាពសម្រាប់ភាគីពាក់ព័ន្ធដែលមានសាវតារចម្រុះ។

ការរៀបចំការជជែកដេញដោលជាសាធារណៈ កិច្ចពិភាក្សាក្រុមអ្នកជំនាញ (panel discussion) និងការប្រជុំក្រុមធំ (town hall meeting) ដើម្បីសម្របសម្រួលកិច្ចសន្ទនាស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ លើកទឹកចិត្តឱ្យអ្នកតាក់តែងគោលនយោបាយ តំណាងអង្គការសង្គមស៊ីវិល និងអ្នកដឹកនាំសហគមន៍ ឱ្យចូលរួមយ៉ាងសកម្ម និងចែករំលែកទស្សនៈយល់ឃើញស្តីពីអត្ថប្រយោជន៍នៃផែនការសកម្មភាពជាតិ។

សហការជាមួយគ្រឹះស្ថានសិក្សា និងអ្នកស្រាវជ្រាវដើម្បីធ្វើការសិក្សា រៀបចំសិក្ខាសាលា និងបោះពុម្ពផ្សាយឯកសារស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ បង្កើតឱកាសឱ្យសិស្សនិស្សិត និងបញ្ញវន្តចូលរួមក្នុងគម្រោងស្រាវជ្រាវ និងផ្សព្វផ្សាយចំណេះដឹងស្តីពីសារៈសំខាន់នៃផែនការសកម្មភាពជាតិ។

ធ្វើការស្រាវជ្រាវដើម្បីប្រមូលភស្តុតាងស្តីពីលទ្ធផលវិជ្ជមាននៃការអនុវត្តផែនការសកម្មភាពជាតិ។ ចែករំលែកលទ្ធផលរកឃើញ និងទិន្នន័យតាមរយៈឯកសារបោះពុម្ពផ្សាយរបាយការណ៍ និងក្រាហ្វិកបង្ហាញព័ត៌មាន (infographics) ដើម្បីបង្ហាញពីសារៈសំខាន់នៃគោលនយោបាយ និងសកម្មភាពដែលឆ្លើយតបនឹងយេនឌ័រ ក្នុងការលើកកម្ពស់សន្តិភាព និងសន្តិសុខ។

កសាងភាពជាដៃគូជាមួយអង្គការអន្តរជាតិ សម្ព័ន្ធថ្នាក់តំបន់ និងភាគីពាក់ព័ន្ធផ្សេងទៀតដែលធ្វើការងារក្នុង វិស័យស្ត្រី សន្តិភាព និងសន្តិសុខ។

សហការគ្នាក្នុងគំនិតផ្តួចផ្តើមរួម ចែករំលែកការអនុវត្តល្អបំផុត និងគាំទ្រកិច្ចខិតខំប្រឹងប្រែងទៅវិញទៅមក ក្នុងការកសាងការយល់ដឹង និងការស្វែងរកមតិគាំទ្រឱ្យមានការអនុវត្តផែនការសកម្មភាពជាតិ។

ការជំរុញការចូលរួមរបស់អ្នកមានឥទ្ធិពល សកម្មជន និងសហគមន៍ឌីជីថល អាចជួយបង្កើតជាកិច្ចពិភាក្សាតាមអនឡាញ បន្លឺសារកាន់លឺឡើងៗ និងជំរុញការចូលរួមក្នុងគំនិតផ្តួចផ្តើមនានា។ ក្រៅពីនេះ ការដាក់បញ្ចូលមាតិកាជារូបភាព វីដេអូ និងមាតិកាបែបអន្តរកម្ម អាចទាក់ទាញក្រុមគោលដៅ និងជំរុញឱ្យពួកគេធ្វើសកម្មភាព។ ការប្រើប្រាស់មធ្យោបាយទំនើបៗទាំងនេះ អាចឱ្យយើងបង្កើនសំឡេងរបស់ស្ត្រីដែលរងផលប៉ះពាល់ដោយសារជម្លោះ បំផុសសមានចិត្ត និងកៀរគរកិច្ចខិតខំប្រឹងប្រែងជាសមូហភាពឆ្ពោះទៅរកការអនុវត្តផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ប្រកបដោយប្រសិទ្ធភាព។

### ចំណុចសំខាន់ៗ ៖

ការរក្សាការប្តេជ្ញាចិត្តផ្នែកនយោបាយ នឹងកំណត់បាននូវការអនុវត្តផែនការសកម្មភាពជាតិប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ កសាងការយល់ដឹងជាសាធារណៈស្តីពីការអនុវត្តការងារ និងរក្សាការប្តេជ្ញាចិត្តរបស់ដៃគូអនុវត្តន៍គឺសកម្មភាពសំខាន់ផងដែរ ។ ព្រឹត្តិការណ៍កសាងការយល់ដឹងជាប្រចាំ និងកម្មវិធីអភិវឌ្ឍន៍សមត្ថភាព ត្រូវផ្តោតលើក្រុមគោលដៅផ្សេងៗ។ ភាពជាប់លាប់នៃការពិនិត្យតាមដានសកម្មភាពទាំងនេះ នឹងជួយដល់ការផ្លាស់ប្តូរចាំបាច់ និងផ្តល់មូលដ្ឋានព័ត៌មានដល់អន្តរាគមន៍នាពេលអនាគត។

## ៣.ចងក្រងការអនុវត្តល្អ និងមេរៀន

ភាពជោគជ័យ និងបញ្ហាប្រឈមក្នុងការអនុវត្តផែនការសកម្មភាពជាតិគួរប្រមូល ដើម្បីជំរុញការរៀនសូត្រ និងផ្តល់មូលដ្ឋានដល់អន្តរាគមន៍នាពេលអនាគត។ ជំហានក្នុងការវិភាគទិន្នន័យ ឆ្លុះបញ្ចាំង រៀនសូត្រ និងអនុវត្តមេរៀន ទៅក្នុងការអនុវត្ត អមជាមួយនឹងការគាំទ្រសមស្រប។ ការចងក្រងការអនុវត្តល្អ និងមេរៀន ក៏អាចផុសចេញពីការពិនិត្យតាមដាន និងវាយតម្លៃផងដែរ។

ខាងក្រោមនេះជាសំណួរសំខាន់ៗមួយចំនួនសម្រាប់ការចងក្រងបទពិសោធន៍ ៖

- តើការអនុវត្តល្អអ្វីខ្លះដែលធានាការសម្របសម្រួលយ៉ាងរលូន និងកិច្ចសហការឆ្លងវិស័យ ក្នុងការអនុវត្ត?
- តើមានការអនុវត្តល្អ និងមេរៀនអ្វីខ្លះ ដែលលេចចេញពីការដាក់បញ្ចូលយេនឌ័រទៅក្នុងផែនការ និងប្រតិបត្តិការក្នុងវិស័យសន្តិសុខ?
- តើត្រូវដាក់បញ្ចូលព័ត៌មានល្អបំផុតអ្វីខ្លះទៅក្នុងការចងក្រងការអនុវត្តល្អ និងមេរៀន សម្រាប់ផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធផ្សេងទៀត?
- តើអ្វីខ្លះជាមធ្យោបាយដែលមានប្រសិទ្ធភាពបំផុតសម្រាប់ការផ្សព្វផ្សាយព័ត៌មានទាំងនេះ?
- តើព័ត៌មានទាំងនេះអាចពង្រឹងការផ្ទុកចំណេះដឹងរបស់ស្ថាប័ន (institutional memory) និងផ្តល់មូលដ្ឋានដល់អន្តរាគមន៍នាពេលអនាគតដោយរបៀបណា?
- តើព័ត៌មានទាំងនេះអាចបង្កើនការចូលរួមរវាងភាគីរដ្ឋាភិបាលជាមួយប្រជាជនទូទៅ និងកសាងទំនុកចិត្ត និងការផ្សព្វផ្សាយអំពីការទប់ស្កាត់ ការដោះស្រាយ និងការស្តារឡើងវិញពីជម្លោះ នៅក្នុងបរិបទជាតិ/បរិ បទមូលដ្ឋានមួយ ដោយរបៀបណា?
- តើករណីសិក្សាក្នុងតំបន់ស្តីពីការដាក់បញ្ចូលទស្សនៈយេនឌ័រទៅក្នុងបញ្ហាសន្តិសុខថ្មីៗ ដូចជា អំពើជួញដូរមនុស្ស ការគ្រប់គ្រងនិងឆ្លើយតបនឹងគ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុ និងភាពអាសន្នផ្នែកសុខភាពសាធារណៈ ត្រូវបានផ្សព្វផ្សាយនៅថ្នាក់ជាតិដោយរបៀបណា?

មេរៀនពីការអនុវត្តផែនការសកម្មភាពជាតិ[87,88] នៅតាមបណ្តាប្រទេសផ្សេងៗ អាចផ្តល់គំនិតល្អៗសម្រាប់ការអនុវត្តផែនការសកម្មភាពជាតិ។ សូមមើលឧទាហរណ៍ខាងក្រោម ៖

- ការកោះប្រជុំជាមួយតួអង្គរដ្ឋាភិបាលដែលមិនសូវបានសម្របសម្រួលការងាររបស់ខ្លួនពីមុនមក ដូចជា មន្ត្រីមកពីក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងក្រសួងកិច្ចការនារី ដើម្បីលើកឡើងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

- ការដាក់បញ្ចូលធាតុផ្សំសំខាន់ៗនៃផែនការសកម្មភាពជាតិ ទៅក្នុងដំណើរការគោលនយោបាយជាតិ និងដំណើរការរៀបចំផែនការស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ចំណុចនេះនឹងពង្រីកភាពម្ចាស់ការ បង្កើនការអនុវត្ត និងធានាប្រភពមូលនិធិ។
- ការប្រើប្រាស់ផែនការសកម្មភាពជាតិដើម្បីជំរុញការចូលរួមរបស់តួអង្គរដ្ឋាភិបាលនៅកម្រិតផ្សេងៗ និងធ្វើការជាមួយប្រជាជនទូទៅ ដើម្បីកសាងទំនុកចិត្ត និងផ្សព្វផ្សាយអំពីបញ្ហាស្ថិរភាព និងសន្តិសុខ។
- ការដាក់បញ្ចូលសូចនាករបែបគុណភាពដែលអាចតាមដានបរិវត្តកម្ម និងការប្រើប្រាស់របាយការណ៍ដែលផ្តោតលើលទ្ធផល និងការផ្តល់ព័ត៌មានហិរញ្ញវត្ថុពិស្តារ ដើម្បីស្វែងយល់ពីកម្រិតនៃការវិនិយោគលើផែនការសកម្មភាពជាតិ នាំទៅរកសមិទ្ធផលវិជ្ជមាន។
- ការធានាថា ការវិភាគទិន្នន័យ ការឆ្លុះបញ្ចាំង ការរៀនសូត្រ និងការអនុវត្តមេរៀន មានការគាំទ្រសមស្រប និងការពិនិត្យតាមដាន និងវាយតម្លៃ និងមិនត្រូវបានចាត់ទុកត្រឹមតែជាឧបករណ៍គណនេយ្យភាពទេ។
- ការធ្វើរបាយការណ៍ និងការផ្សព្វផ្សាយរឿងរ៉ាវស្តីពីផលជះនៃផែនការសកម្មភាពជាតិ។

ជារួម ដើម្បីអនុវត្តផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខប្រកបដោយប្រសិទ្ធភាព ចាំបាច់ត្រូវមានការពង្រឹងសមត្ថភាពរបស់ស្ថាប័នសម្របសម្រួលលើរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងការធានាប្រភពមូលនិធិ។ កង្វះប្រភពមូលនិធិដែលមាននិរន្តរភាព ធ្វើឱ្យរាំងស្ទះខ្លាំងដល់ការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ដើម្បីឱ្យផែនការសកម្មភាពជាតិមានប្រសិទ្ធភាព ចាំបាច់ត្រូវមានការវិភាជថវិកាជាក់លាក់សម្រាប់សកម្មភាពដែលពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ ប្រភពហិរញ្ញប្បទានដែលអាចព្យាករណ៍បាន និងមាននិរន្តរភាព ក៏ដូចជាការគ្រប់គ្រងសមស្រប និងការតាមដានមូលនិធិ។

ចំណុចផ្សេងទៀតដែលត្រូវពិចារណា មានដូចជា ការជំរុញការចូលរួមប្រកបដោយអត្ថន័យរបស់អង្គការស្ត្រី ក្រុមសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀត នៅក្នុងការកសាង ការអនុវត្ត និងការពិនិត្យតាមដានផែនការសកម្មភាពជាតិ។ ចំណុចនេះនឹងជួយធានាការដាក់បញ្ចូលទស្សនៈយល់ឃើញចម្រុះ និងភាពម្ចាស់ការលើផែនការសកម្មភាពជាតិ។

ការពិចារណាដ៏សំខាន់មួយទៀតគឺការបង្កើតក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ ដែលបន្សុីគ្នានឹងក្របខណ្ឌពិនិត្យតាមដាន និងធ្វើរបាយការណ៍របស់រដ្ឋាភិបាល ដើម្បីតាមដានវឌ្ឍនភាព កត់ត្រាមេរៀន និងវាស់វែងផលជះនៃផែនការសកម្មភាពជាតិ។ ចំណុចនេះទាមទារការប្រមូលទិន្នន័យបែងចែកតាមភេទ ការបង្កើតសូចនាករ និងការពិនិត្យតាមដានជាប្រចាំលើដំណើរការអនុវត្តន៍ ដើម្បីកំណត់រកគម្លាត និងកែសម្រួលយុទ្ធសាស្ត្រ។ អ្វីដែលសំខាន់ផងដែរនោះគឺការវិនិយោគលើការកសាងការយល់ដឹង និងការអភិវឌ្ឍសមត្ថភាពរបស់ភាគីពាក់ព័ន្ធ ដូចជា មន្ត្រីរដ្ឋាភិបាល កងកម្លាំងសន្តិសុខ និងអង្គការសង្គមស៊ីវិល។ ការធ្វើដូច្នេះនឹងជួយពង្រឹងការយល់ដឹងរបស់ពួកគេស្តីពីបញ្ហាយេនឌ័រ ជំរុញប្រសិទ្ធភាពក្នុងការអនុវត្តយុទ្ធសាស្ត្រដែលឆ្លើយតបនឹងយេនឌ័រ និងលើកម្ពស់ការសម្របសម្រួលក្នុងចំណោមតួអង្គផ្សេងៗ។

# សទ្ទានុក្រម

ភ្នាក់ងារ ៖ សំដៅលើសមត្ថភាព និងលទ្ធភាពចូលរួមក្នុងសកម្មភាពក្រោម អំណាច និងគ្រប់គ្រង របស់ដែលបុគ្គលម្នាក់បាន ការដឹងពីចេនាសម្ព័ន្ធ និងបទដ្ឋានសង្គមដែលអាចជះឥទ្ធិពល រឹតត្បិត ឬតម្រឹមតម្រង់សកម្មភាព និងជម្រើសរបស់បុគ្គល[89]។ ក្នុងបរិបទនៃរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ភ្នាក់ងារត្រូវបានលើកកម្ពស់តាមរយៈការចូលរួមពេញលេញ និងស្មើភាពរបស់ស្ត្រី នៅក្នុងកិច្ចខិតខំប្រឹងប្រែងទាំងអស់ ដើម្បីរក្សា និងលើកកម្ពស់សន្តិភាព និងសន្តិសុខ។

អំពើហិង្សាផ្លូវភេទដែលពាក់ព័ន្ធនឹងជម្លោះ ៖ សំដៅលើអំពើរំលោភសេពសន្ថវៈ ទាសភាពផ្លូវភេទ ពេស្យាកម្មដោយបង្ខំ ការបង្ខំឱ្យពរពោះ ការបង្ខំឱ្យរំលូតកូន ការបង្ខំឱ្យក្រៀវ (enforced sterilization) អាពាហ៍ពិពាហ៍ដោយបង្ខំ និងទម្រង់ផ្សេងទៀតនៃអំពើហិង្សាផ្លូវភេទដែលមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នា ដែលបង្កឡើងលើស្ត្រី បុរស ក្មេងស្រី ឬក្មេងប្រុស ដោយផ្ទាល់ ឬដោយប្រយោលនឹងជម្លោះ។ ពាក្យនេះក៏គ្របដណ្តប់លើអំពើជួញដូរមនុស្សផងដែរ នៅពេលដែលអំពើនេះកើតឡើងក្នុងស្ថានភាពជម្លោះដើម្បីបម្រើឱ្យគោលបំណងនៃអំពើហិង្សា/ការកេងប្រវ័ញ្ចផ្លូវភេទ[90]។

ការគិតគូពីជម្លោះ (conflict sensitivity) ៖ មានន័យថាជាការវាយតម្លៃយ៉ាងល្អិតល្អន់លើផលប៉ះពាល់អវិជ្ជមាននៃអន្តរាគមន៍នានាទន្ទឹមនឹងការពិចារណាពីថាមវន្តជម្លោះ។

យេនឌ័រ ៖ សំដៅលើតួនាទី និងទំនាក់ទំនងរបស់បុរស និងស្ត្រី ដែលកំណត់ដោយសង្គម។ ជាទូទៅ យេនឌ័រជាពាក្យដែលសំដៅលើភាពជាមនុស្សប្រុស និងភាពជាមនុស្សស្រី និងត្រូវបានកំណត់ដោយវប្បធម៌។ ដូច្នេះ តួនាទី និងឥរិយាបទដែលផ្អែកតាមយេនឌ័រប្រែប្រួលទៅតាមពេលវេលា និងតាមបរិបទវប្បធម៌។ យេនឌ័រមិនត្រូវបានកំណត់ដោយកត្តាជីវសាស្ត្រនោះឡើយ ប៉ុន្តែយេនឌ័រត្រូវបានសិក្សារៀនសូត្រទៅវិញទេ។ ស្ត្រី និងបុរស ក្មេងប្រុស និងក្មេងស្រី ត្រូវបានបង្រៀនថាពីតួនាទី និងអាកប្បកិរិយាជាក់លាក់មួយចំនួនដែលសមស្រប ទៅតាមភេទរបស់ពួកគេ[91]។

បទដ្ឋានយេនឌ័រ ៖ ជាវិធានក្រៅផ្លូវការ និងជាក្តីរំពឹងទុករួមក្នុងសង្គមដែលញែកអាកប្បកិរិយា ដោយផ្អែកតាមយេនឌ័រ។ ទោះបីជាផ្អែកតាមបរិបទជាក់លាក់មែន ប៉ុន្តែជាញឹកញាប់ បទដ្ឋានយេនឌ័រកំណត់ថា តួនាទីសមស្របរបស់ស្ត្រី គឺស្ថិតក្នុងជីវិតឯកជន ដូចជា តួនាទីថែទាំ និងកំណត់ថា តួនាទីសមស្របរបស់បុរស គឺស្ថិតក្នុងជីវិតសាធារណៈ ដូចជា ការងារទទួលបានប្រាក់ឈ្នួល តួនាទីដឹកនាំ និងតួនាទីធ្វើសេចក្តីសម្រេចចិត្ត[92]។

ការវិភាគយេនឌ័រ ៖ ក្របខណ្ឌ និងវិធីសាស្ត្រមួយសម្រាប់ជាមគ្គុទេសក៍ដល់ការប្រមូលព័ត៌មាន និងទិន្នន័យ និងការវិភាគ ដើម្បីស្វែងយល់កាន់តែច្បាស់អំពីទំនាក់ទំនងក្នុងចំណោមស្ត្រី ក្មេងស្រី បុរស និងក្មេងប្រុសម្នាក់ៗ លើលទ្ធភាពរបស់ពួកគេក្នុងការទទួលបានធនធាននិងការធ្វើសេចក្តីសម្រេចចិត្ត សិទ្ធិរបស់ពួកគេ ក៏ដូចជាឧបសគ្គនិងឱកាសសម្រាប់ពួគេ ធៀបនឹងបុគ្គលផ្សេងទៀត[93]។

អំពើហិង្សាទាក់ទងនឹងយេនឌ័រ ៖ ជាអំពើហិង្សាលើបុគ្គលម្នាក់ ឬក្រុមណាមួយ ដោយសារយេនឌ័ររបស់ពួកគេ។ អំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមបញ្ចូលអំពើហិង្សាលើស្ត្រី និងក្មេងស្រី ក៏ដូចជាអំពើហិង្សាលើបុរស និងក្មេងប្រុស។

តុល្យភាព ឬយុគភាពយេនឌ័រ ៖ សកម្មភាពដែលបានធ្វើឡើងដើម្បីធានាភាពជាតំណាងពេញលេញ និងស្មើភាពរបស់ស្ត្រី និងបុរសនៅក្នុងស្ថាប័ន និងការធ្វើសេចក្តីសម្រេចផ្នែកសន្តិសុខ ដូចជា នៅក្នុងទីភ្នាក់ងារអនុវត្តន៍ កងទ័ព ឬគណៈកម្មាធិការត្រួតពិនិត្យរដ្ឋសភា[94]។

សមភាពយេនឌ័រ ៖ ភាពស្មើភាពគ្នាក្នុងស្ថានភាព សិទ្ធិ និងឱកាស និងភាពមានតម្លៃស្មើគ្នា ដោយមិនគិតថាតើបុគ្គលម្នាក់ជាបុរស ឬស្ត្រី ជាក្មេងប្រុស ឬជាក្មេងស្រីនោះទេ។

ការបញ្ជ្រាបយេនឌ័រ ៖ ពាក់ព័ន្ធនឹងការវាយតម្លៃ និងការលើកឡើងពីផលប៉ះពាល់សម្រាប់ស្ត្រី និងក្មេងស្រី បុរស និងក្មេងប្រុសដោយសារសកម្មភាពណាមួយដែលបានគ្រោងឡើង ដូចជា ច្បាប់ គោលនយោបាយ ឬកម្មវិធី នៅគ្រប់ដំណាក់កាលនៃអន្តរាគមន៍ ចាប់ពីការរៀបចំរហូតដល់ការតាមដាន និងការវាយតម្លៃ និងនៅគ្រប់កម្រិត សូម្បីតែនៅពេលដែលសមភាពយេនឌ័រ មិនមែនជាចំណុចផ្តោតសំខាន់នៃអន្តរាគមន៍មួយ[95]។
អភិក្រមដែលឆ្លើយតបនឹងយេនឌ័រ ៖ ផ្អែកតាមការវិភាគយេនឌ័រ និង/ឬកិច្ចព្រមព្រៀង។ ការឆ្លើយតបនឹង យេនឌ័រ ដែលជាទស្សនទាន និងជាការអនុវត្តមួយ មានគោលបំណងបង្កើនសមត្ថភាពប្រតិបត្តិការ និងសមត្ថភាពអនុវត្ត ដើម្បីដោះស្រាយវិសមភាពយេនឌ័រ ការផាត់ចេញ និងភាពខុសគ្នា តាមរយៈសកម្មភាព ឬកិច្ចខិតខំប្រឹងប្រែងអនុវត្ត ដែលអាចធ្វើទៅបាន និងស្ថិតក្រោមការពិនិត្យតាមដាន និងវាយតម្លៃ[96]។

អន្តរាគមន៍ដែលគិតគូពីយេនឌ័រ ៖ ទទួលស្គាល់តម្រូវការជាក់លាក់ និងតថភាពរបស់បុរស និងស្ត្រី ក្មេងប្រុស និងក្មេងស្រី ដោយផ្អែកទៅតាមតួនាទីយេនឌ័ររបស់ពួកគេនៅក្នុងបរិបទមួយ។ យ៉ាងហោចណាស់ ការអន្តរាគមន៍ទាំងនេះគួរបញ្ចៀសការពង្រឹង ឬការពង្រីកវិសមភាពយេនឌ័រដែលមានស្រាប់។ ឱ្យតែអាចធ្វើបាន អន្តរាគមន៍ទាំងនេះគួរជៀសវាការពង្រឹង ឬធ្វើឱ្យអាក្រក់ឡើងនូវវិសមភាពដែលមានស្រាប់ រវាង និងក្នុងចំណោមស្ត្រី និងបុរស ដោយចាត់វិធានការលើកកម្ពស់យុត្តិធម៌យេនឌ័រ និងសមភាពយេនឌ័រ[97]។

ផែនការសកម្មភាពជាតិដែលផ្តល់ផលជះកម្រិតខ្ពស់ ៖ ផែនការសកម្មភាពជាតិដែលកើតចេញពីដំណើរការប្រកបដោយបរិយាបន្ន ដែលធានាការចូលរួមពេញលេញ និងប្រកបដោយអត្ថន័យរបស់ស្ត្រី នៅក្នុងដំណើរការ និងសេចក្តីសម្រេចដែលពាក់ព័ន្ធនឹងសន្តិសុខ។ វាមានកំណត់ពេលវេលាជាក់លាក់ និងយន្តការសម្រាប់គណនេយ្យភាពសាធារណៈ និងធានាប្រភពមូលនិធិសំខាន់ៗ។ ផែនការដែលផ្តល់ផលជះកម្រិតខ្ពស់ អាចជំរុញឱ្យរដ្ឋាភិបាល ស្ថាប័នពហុភាគី និងសង្គមស៊ីវិល ធ្វើការកែប្រែគោលនយោបាយដែលមានការសម្របសម្រួល និងអាចអនុវត្តបាន និងផ្តល់សមិទ្ធផលដែលមាននិរន្តរភាព។

សន្តិសុខមនុស្ស ៖ ទស្សនៈផ្អែកសន្តិសុខដែលគិតគូរពីមនុស្ស និងសង្កត់ធ្ងន់លើសុវត្ថិភាពប្រចាំថ្ងៃរបស់ប្រជាជន តាមរយៈការកែលម្អសេវា និងកម្មវិធីសាធារណៈដើម្បីប្រយុទ្ធប្រឆាំងភាពក្រីក្រ។ សន្តិសុខមនុស្សលើកឡើងពីបញ្ហាសំខាន់ៗ ដូចជា សុខភាព បរិស្ថាន សេដ្ឋកិច្ច សង្គម ការអប់រំ និងសហគមន៍។ សន្តិសុខមនុស្ស មិនត្រឹមតែផ្តោតលើការពារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនភាពអង់អាចរបស់ប្រជាជន និងសង្គមសម្រាប់ជាមធ្យោបាយធានាសន្តិសុខទៀតផង។ តាមរយៈការផ្តោតលើបុគ្គលម្នាក់ៗ គម្រូសន្តិសុខមនុស្សមានគោលបំណងដោះស្រាយបញ្ហាសន្តិសុខទាំងសម្រាប់បុរស និងស្ត្រី ដូចគ្នា។

បរិយាបន្ន[98]៖ បញ្ជាក់គោលគំនិតថា ក្រុមផ្សេងៗនៅក្នុងសង្គម គួរមានសំឡេងនៅក្នុងដំណើរការដែលបង្កផលប៉ះពាល់លើពួកគេ ដោយផ្តោតសំខាន់លើក្រុមងាយរងគ្រោះ។ ខណៈដែលការចូលរួម និងភាពជាតំណាងជាផ្នែកសំខាន់នៃបរិយាបន្ន ការខិតខំធានាការគោរពសិទ្ធិមនុស្ស និងពង្រឹងសមត្ថភាពរបស់សហគមន៍ងាយរងគ្រោះ អាចជាកត្តាសំខាន់សម្រាប់បរិយាបន្នប្រកបដោយអត្ថន័យ ដូចការអញ្ជើញឱ្យពួកគេចូលរួមក្នុងកិច្ចពិភាក្សា។

អន្តរជំនាន់ ៖ ការជំរុញការចូលរួមរបស់ក្រុមមនុស្សចាប់ពី ២ ជំនាន់ឡើងទៅ នៅក្នុងសកម្មភាពដែលអាចធ្វើឱ្យពួកគេពិចារណាពីទស្សនៈវិស័យផ្សេងៗ (តាមជំនាន់)។ សកម្មភាពនេះនឹងបង្កើនទំនាក់ទំនង តាមរយៈការកសាងកិច្ចសហការដើម្បីសម្រេចគោលដៅរួម និងការរៀនសូត្រពីគ្នាទៅវិញទៅមក។

ការធ្វើមូលដ្ឋានីយកម្ម ៖ សំដៅលើការលើកកម្ពស់ការដឹកនាំ ភាពម្ចាស់ការ និងការប្តេជ្ញាចិត្តថ្នាក់ជាតិលើការអនុវត្តការប្តេជ្ញាចិត្តស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងចំណោមតួអង្គថ្នាក់ជាតិសំខាន់ៗ។ ការធ្វើមូលដ្ឋានីយកម្មនឹងលើកកម្ពស់សមត្ថភាពរបស់សង្គមស៊ីវិលក្នុងការរក្សាការទទួលខុសត្រូវរបស់ប្រមុខដឹកនាំ និងអាជ្ញាធររដ្ឋាភិបាល អង្គការថ្នាក់តំបន់ អង្គការសហប្រជាជាតិ ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត លើកាតព្វកិច្ចរបស់ខ្លួន ក្រោមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ និងក្របខណ្ឌថ្នាក់តំបន់ដែលពាក់ព័ន្ធ ដូចជា ផែនការសកម្មភាពតំបន់ អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ជាតុផ្សំសំខាន់ៗរួមមានលិខិតុបករណ៍ច្បាប់ និងគោលនយោបាយដែលពង្រឹងការអនុវត្តនៅថ្នាក់ជាតិ ព្រមទាំងការសម្របសម្រួលលជាប្រព័ន្ធ និងកិច្ចសហប្រតិបត្តិការឆ្លងវិស័យក្នុងចំណោមភាគីពាក់ព័ន្ធ[99]។

សន្តិភាព ៖ មានន័យថាជាការគ្មានជម្លោះហិង្សា (សន្តិភាពអវិជ្ជមាន) និងការមានយុត្តិធម៌ និងសមធម៌ ក៏ដូចជាការគោរពសិទ្ធិមនុស្ស និងភពផែនដី (សន្តិភាពជាវិជ្ជមាន)[100]។

សង្គតិភាពគោលនយោបាយ ៖ ភាពស៊ីសង្វាក់គ្នា និងការសម្របសម្រួលគោលដៅ និងសកម្មភាពនៅក្នុងគោលនយោបាយថ្នាក់ជាតិ និងគោលនយោបាយថ្នាក់ក្រោមជាតិផ្សេងៗ ឬនៅពេលដែលគោលនយោបាយទាំងឡាយ "ស្របគ្នា និងដើរតាមទិសដៅតែមួយ" ជាជាងផ្តោតលើគោលដៅបញ្ច្រាស់គ្នា ឬផ្សេងគ្នា។

សន្តិសុខ ៖ ភាពគ្មានគ្រោះថ្នាក់ ឬការគំរាមកំហែង ដែលរួមបញ្ចូលការគំរាមកំហែងចំពោះសន្តិសុខមនុស្ស ដូចជា ការលេចឡើងនៃភាពជ្រុលនិយម និងអំពើហិង្សាជ្រុលហួសហេតុ អំពើជួញដូរមនុស្ស វិបត្តិអាកាសធាតុ វិបត្តិសុខភាពសកល។ល។

ភេទ ៖ សំដៅលើលក្ខណៈខុសគ្នាផ្នែកជីវសាស្ត្រ និងសរីរៈសាស្ត្រ របស់មនុស្សប្រុស និងមនុស្សស្រី។

អំពើហិង្សាផ្លូវភេទ និងទាក់ទងនឹងយេនឌ័រ ៖ អង្គការសុខភាពពិភពលោក កំណត់និយមន័យអំពើហិង្សាផ្លូវភេទជា "សកម្មភាពផ្លូវភេទទាំងឡាយ ដូចជា ការប៉ុនប៉ងរួមផ្លូវភេទ ការនិយាយ ឬការល្បួងឱ្យរួមផ្លូវភេទដោយមិនចង់ ឬការជួញដូរផ្លូវភេទស្ត្រី ដោយបង្ខិតបង្ខំ ការគំរាមបង្កគ្រោះថ្នាក់ ឬប្រើកម្លាំង ដោយនរណាម្នាក់ ដោយមិនគិតពីទំនាក់ទំនងជាមួយជនរងគ្រោះ ក្នុងទីតាំងណាមួយ ដូចជា ផ្ទះ និងកន្លែងធ្វើការ"។ ពាក្យនេះគ្របដណ្តប់លើការបង្ខំឱ្យរួមភេទ ការបង្ខិតបង្ខំខាងផ្លូវភេទ និងអំពើរំលោភសេពសន្ថវៈលើមនុស្សពេញវ័យ និងមនុស្សវ័យជំទង់ទាំងពីរភេទ និងការរំលោភបំពានផ្លូវភេទកុមារ[101]។

បទដ្ឋានសង្គម ៖ ការរំពឹងទុកជារួមលើបុគ្គលម្នាក់ៗ ឬក្រុមណាមួយ ពាក់ព័ន្ធនឹងអ្វីដែលមនុស្សគួរប្រព្រឹត្ត។ បទដ្ឋានដើរតួនាទីជាកត្តាជំរុញដ៏មានអនុភាពសម្រាប់គាំទ្រ ឬប្រឆាំងនឹងឥរិយាបថ ឬអាកប្បកិរិយានីមួយៗ ដោយសារតែបុគ្គលដែលមិនធ្វើតាមការរំពឹងទុករបស់ក្រុម ទទួលរងភាពអាម៉ាស់ ទណ្ឌកម្ម ឬការមិនទទួលយក ដោយអ្នកដទៃដែលសំខាន់ចំពោះពួកគេ[102]។

ភាពត្រឹមតែជានិមិត្តរូប (tokenism) ៖ ការខិតខំប្រឹងប្រែងជានិមិត្តរូប ក្នុងការប្រតិបត្តិការអនុវត្តប្រកបដោយបរិយាបន្ន ដើម្បីបង្ហាញឱ្យឃើញពីបរិយាបន្ន និងភាពមិនលម្អៀង។

# ឯកសារយោង


**ASEAN (Association for Southeast Asian Nations) Secretariat (2021)**. ASEAN Regional Study on Women, Peace and Security. Jakarta: ASEAN Secretariat.

——— **(2022).** ASEAN Regional Plan of Action on Women, Peace and Security. Jakarta: ASEAN Secretariat.

**Babic-Svetlin. K., et al. ( 2016).** "Localisation of Women, Peace, and Security Agenda: Case study of six local governments in Bosnia and Herzegovina." Sarajevo: Agency for Gender Equality, Ministry of Human Rights and Refuges, Government of Bosnia and Herzegovina

**CARE (n.d.).** "CARE International Accountability Framework." Website: https://www.care-international.org/files/files/CARE%20International%20Accountability%20Framework.pdf.

**Coomaraswamy, R., et al. (2015).** "Preventing Conflict, Transforming Justice, Securing the Peace: A global study on the implementation of Security Council resolution 1325." New York: UN Women.

**Coordinating Minister of People's Welfare of the Republic of Indonesia (2014).** The National Action Plan for the Protection and Empowerment of Women and Children During Social Conflicts of 2014–2019. Website: http://1325naps.peacewomen.org/wp-content/uploads/2020/12/Indonesia-National-Action-Plan.pdf

**The Dag Hammarskjöld Foundation (2021).** "Realising Inclusivity: The role of the United Nations in promoting inclusion at the country level." Uppsala: The Dag Hammarskjöld Foundation.

**DFID (Department for International Development), Government of the United Kingdom (2015).** "Addressing Violence against Women and Girls: Guidelines part B." London: Department for International Development.

——— **(2019).** "'How to' Guidance Note on Gender Equality: A practical guide to integrating gender equality into DFID and HMG policy and programming." London: Department for International Development.

**European Institute for Gender Equality (2021).** "Glossary and Thesaurus." Vilnius: European Institute for Gender Equality.

**Global Coalition on Youth, Peace and Security (2022).** "Implementing the Youth, Peace and Security Agenda at Country-level: A guide for public officials." New York: Office of the UN Secretary-General's Envoy on Youth.

**GNWP (Global Network of Women Peacebuilders) (2017a).** From Best Practice to Standard Practice: A toolkit on the localisation of the UN Security Council resolution 1325 on women and peace and security. New York: Global Network of Women Peacebuilders and UN Women.

——— **(2017b).** No Money, No NAP: Manual for costing and budgeting national action plans on UNSCR 1325. New York: Global Network of Women Peacebuilders.

**Heise, L. L. (2011).** "What Works to Prevent Partner Violence: An evidence overview." STRIVE.

**HM Government (2015).** "Integrating Gender Issues into Conflict, Stability and Security Fund (CSSF) Programming." London: HM Government.

**IFAD (International Fund for Agricultural Development) (2017).** Increasing Transparency for Greater Accountability – Action Plan. Rome: International Fund for Agricultural Development.

**IGWG (Interagency Gender Working Group) (2002).** "The Gender Integration Continuum." Washington, DC: Interagency Gender Working Group. Website: https://www.igwg.org/

**ILO (International Labour Organisation) (n.d.).** "Accountability and Transparency." Website: https://www.ilo.org/global/about-the-ilo/how-the-ilo-works/accountability-and-transparency/lang--en/index.htm.

**Inclusive Security and Women Waging Peace (2004).** Inclusive Security, Sustainable Peace: A Toolkit for Advocacy and Action. London.

**Jacevic, M. (2019).** "What Makes an Effective WPS National Action Plan?" Australian Strategic Policy Institute.

**——— (2022).** Towards Full Implementation of WPS Agenda in Viet Nam: Report to contribute to the possible development of Viet Nam's first national action plan on women, peace and security. Hanoi: UN Women.

**Kirby, P., and L. J. Shepherd (2016).** "Reintroducing Women, Peace and Security." International Affairs 92(2).

**Lippai, Z., and A. Young (2017).** "Creating National Action Plans: A guide to implementing resolution 1325." Washington, DC: Internal Security.

**Ministry of Women's Empowerment and Child Protection, Government of Indonesia (2022).** Technical Guidelines for the Preparation for Regional Action Plan for the Protection and Empowerment of Women and Children in Social Conflicts. Jakarta: Ministry of Women's Empowerment and Child Protection, Government of Indonesia.

**Myrttinen, H., et al. (2020).** "Implementing the Women, Peace and Security Agenda in the OSCE Region." Vienna: Organisation for Security and Co-operation in Europe and LSE Centre for Women, Peace and Security.

**Natividad, A. M. (2013).** "Empowerment and Participation." In Implementing the Philippine National Action Plan on UN Security Council Resolutions 1325 and 1820: A Civil Society Monitoring Report – March 2010 to January 2013. Quezon City: WE Act 1325.

**Office of the Presidential Adviser on the Peace Process, Republic of the Philippines (2017).** National Action Plan on Women, Peace and Security 2017-2022. Pasig City: Office of the Presidential Adviser on the Peace Process, Republic of the Philippines.

**Office of the Regional Chief Minister (2023).** Bangsamoro Regional Action Plan on Women, Peace and Security 2023-2028. Mindanao: Office of the Regional Chief Minister.

**Office of the Special Representative of the Secretary-General on Sexual Violence in Conflict (2017).** Report of the Secretary-General on Conflict-related Sexual Violence. S/2017/249, eighth annual report. United Nations.

**Peace Women (2012).** Women, Peace and Security Handbook: Compilation and analysis of United Nations Security Council resolution language 2000-2012." New York: Women's International League for Peace and Freedom.

**Perez, J., and B. Orozco. (2013).** "Policies, Mechanisms and Capacity Building for Women in Conflict Areas." In Implementing the Philippine National Action Plan on UN Security Council Resolutions 1325 and 1820: A Civil Society Monitoring Report – March 2010 to January 2013. Quezon City: WE Act 1325.

**Piscano, F. Y. 2013.** "Promotion and Mainstreaming of Gender Perspective in All Aspects of Conflict Prevention, Conflict Resolution and Peacebuilding." In Implementing the Philippine National Action Plan on UN Security Council Resolutions 1325 and 1820: A Civil Society Monitoring Report – March 2010 to January 2013. Quezon City: WE Act 1325.

**Sarajevo Open Centre, OSCE (Organisation for Security and Co-operation in Europe) and SIDA (Swedish International Development Agency) (2020).** "What Is the Gender of Security? 20 years of the Security Council resolution 1325 'women, peace and security' and its implementation in Bosnia and Herzegovina." Sarajevo.

**United Nations (2017).** "Annex to the Letter Dated 1 March 2018 from the Permanent Representatives of Germany, Namibia and Spain to the United Nations Addressed to the Secretary-General." A/72/782–S/2018/178. New York: United Nations.

**UN Women (n.d.).** "Asia-Pacific Regional Symposium National Action Plans on Women, Peace and Security," UN Women Regional Office for Asia and the Pacific.

**UN Women (2012).** "Women and Peace and Security: Guidelines for national implementation." New York: UN Women.

**UN Women (2018).** "Report of the Expert Group Meeting on Women's Meaningful Participation in Negotiating Peace and the Implementation of Peace Agreements." New York: UN Women.

**UN Women (2021).** "Corporate Evaluation of UN Women's Support to National Action Plans on Women, Peace and Security." New York: UN Women.

**UN Women (2023).** "Women, Peace and Security in Indonesia – Country Brief." Jakarta: UN Women.

**USAID (United States Agency for International Development) (n.d.).** "Localisation: Catalysing and Supporting Local Change." Website: https://www.usaid.gov/localisation.

——— **(2022).** "Localisation at USAID: The Vision and Approach." Washington, DC: United States Agency for International Development.

**Veneracion-Rallonza, M. L. (2013).** "Services and Programs for Women in Conflict-Affected Areas." In Implementing the Philippine National Action Plan on UN Security Council Resolutions 1325 and 1820: A Civil Society Monitoring Report – March 2010 to January 2013. Quezon City: WE Act 1325.

**WIIS (Women in International Security) (2020).** "1325 and Beyond: Winning essays." Washington, DC: Women In International Security.

**WILPF (Women's International League for Peace and Freedom) (n.d.).** "National Action Plans at a Glance." Website: http://1325naps.peacewomen.org/.

1 Babic-Svetlin et al., 2016.
2 ASEAN Secretariat, 2021.
3 Resolutions 1325 (2000), 1820 (2008), 1888 (2008), 1889 (2009), 1960 (2010), 2106 and 2122 (2013), 2241 (2015), and 2467 and 2493 (2019).
4 UN Women, n.d.
5 WIIS, 2020.
6 Ibid.
7 UN Women, n.d.
8 Jacevic, 2022.
9 UN Women, 2012.
10 USAID, n.d.
11 GNWP, 2018a.
12 ASEAN Secretariat, 2022.
13 Jacevic, 2022.
14 ASEAN Secretariat, 2022.
15 Ibid.
16 Ibid.
17 Ibid.
18 Sarajevo Open Centre, OSCE and SIDA, 2020.
19 ASEAN Secretariat, 2022.
20 Ibid.
21 GNWP, 2017a.
22 UN Women, 2012.
23 Ibid.
24 ASEAN Secretariat, 2022, p. 44.
25 Ibid.
26 UN Women, 2012.
27 ASEAN Secretariat, 2022, p. 13.
28 Coomaraswamy et al., 2015.
29 Ibid.
30 UN Women, 2012.
31 Ibid.
32 Jacevic, 2022.
33 រួមបញ្ចូលតំណាងមកពីក្រសួង ទីភ្នាក់ងារ និងនាយកដ្ឋានដែលពាក់ព័ន្ធក្នុងការពន្លឿនបញ្ហាដែលពាក់ព័ន្ធនឹងស្ត្រី សន្តិភាព និងសន្តិសុខ សង្គមស៊ីវិល អង្គការសាសនា រួមទាំងអ្នកដឹកនាំបែបប្រពៃណី អង្គការតាមសហគមន៍ដែលដឹកនាំដោយសកម្មជនជាស្ត្រី វិស័យឯកជន គ្រឹះស្ថានសិក្សា ប្រព័ន្ធផ្សព្វផ្សាយ។ល។.
34 Jacevic, 2022.
35 Adapted from GNWP, 2017a.
36 Adapted from the Global Coalition on Youth, Peace, and Security, 2022.
37 Ibid.
38 Ibid.
39 Ibid.
40 Ibid.
41 Ibid.
42 Ibid.
43 Ibid.

44 Ibid.

45 Lippai and Young, 2017.

46 Jacevic, 2022.

47 ផ្អែកលើការសិក្សាជាសកលរបស់អង្គការសហប្រជាជាតិស្តីពីការអនុវត្តសេចក្តីសម្រេចលេខ ១៣២៥ របស់អង្គការសហប្រជាជាតិ ធាតុផ្សំសំខាន់ៗដែលបង្កើតបានជាផែនការសកម្មភាពជាតិដែលបង្កផលប៉ះពាល់កម្រិតខ្ពស់ គឺ ដំណើរការរៀបចំបែបបរិយាបន្ន និងការបង្កើតប្រព័ន្ធសម្របសម្រួលការអនុវត្ត និងឆន្ទៈនយោបាយដ៏រឹងមាំ និងមាននិរន្តរភាព ធនធានដែលត្រូវបានកំណត់ និងបែងចែកសម្រាប់ការអនុវត្ត និងផែនការពិនិត្យតាមដាន និងវាយតម្លៃដោយផ្អែកតាមលទ្ធផល។ សូមមើល Coomaraswamy et al., 2015.។

48 Ibid.

49 Ibid.

50 គំនិតផ្តួចផ្តើមនេះកើតចេញពីការប្តេជ្ញាចិត្តរបស់ប្រទេសអេស្ប៉ាញក្នុងអំឡុងពេលនៃការពិនិត្យឡើងវិញកម្រិតខ្ពស់លើការអនុវត្តសេចក្តីសម្រេចលេខ ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខ។.

51 United Nations, 2017.

52 លទ្ធផលពីការស្ទង់មតិសមាជិកគណៈកម្មាធិការស្ត្រីអាស៊ាន ដែលបានធ្វើឡើងនៅខែ សីហា ឆ្នាំ ២០២៣ ក្នុងពេលរៀបចំកញ្ចប់ឧបករណ៍នេះ។.

53 ASEAN Secretariat, 2021.

54 Jacevic, 2022.

55 ដកស្រង់ចេញពី Lippai and Young, 2017។ សង្គមស៊ីវិលរួមបញ្ចូលតួអង្គយ៉ាងច្រើន ដូចជា អ្នកពាក់ព័ន្ធក្នុងប្រព័ន្ធផ្សព្វផ្សាយ គ្រឹះស្ថានសិក្សា អង្គការមិនមែនរដ្ឋាភិបាលដែលផ្តោតលើសន្តិភាព និងអង្គការដែលផ្តោតទាំងស្រុង និងដោយផ្ទាល់លើស្ត្រី និងក្មេងស្រី។ មួយចំនួនជាអ្នកអនុវត្តន៍ មួយចំនួនជាអ្នកតស៊ូមតិ និងមួយចំនួនទៀតជាអ្នកអនុវត្តន៍ផង អ្នកតស៊ូមតិផង។ ការជ្រើសរើសអង្គការសង្គមស៊ីវិល គួរផ្អែកលើភាពគ្របដណ្តប់ធំទូលាយ ដើម្បីធានាថា អង្គការដែលបានជ្រើសរើស ពិតជាតំណាងឱ្យភាគីពាក់ព័ន្ធគោលដៅនៅក្នុងប្រទេស។

56 Inclusive Security and Women Waging Peace, 2004.

57 Jacevic, 2022.

58 UN Women, 2021.

59 សម្រាប់សេចក្តីណែនាំលម្អិត ស្តីពីការកំណត់រកបញ្ហាយេនឌ័រក្នុងការវាយតម្លៃបរិបទនៃស្ថានភាពដែលរងផលប៉ះពាល់ដោយសារជម្លោះ សូមចូលទៅកាន់ ៖ https://www.unwomen.org/sites/default/files/Headquarters/Attachments/Sections/Library/Publications/2012/10/WPSsourcebook-03B-WomensPeaceSecurityPriorities-en.pdf and https://www.unwomen.org/sites/default/files/Headquarters/Media/Publications/UNIFEM/0201_GenderAndConflictAnalysis_en.pdf

60 UN Women, 2012.

61 លទ្ធផលចុងក្រោយទី ១ នៃសសរស្តម្ភទី ១ ស្តីពីការការពារ មានលទ្ធផលក្នុងឆ្នាំ ៣ ជាមួយនឹងសកម្មភាពអាទិភាពចំនួន ២៤។ លទ្ធផលចុងក្រោយទី ២ នៃសសរស្តម្ភទី ២ ស្តីពីការចូលរួម មានលទ្ធផលក្នុងឆ្នាំ ៤ ជាមួយនឹងសកម្មភាពអាទិភាពចំនួន ២៥។ លទ្ធផលចុងក្រោយទី ៣ និងលទ្ធផលចុងក្រោយទី ៤ នៃសសរស្តម្ភទី ៣ ស្តីពីការទប់ស្កាត់ មានលទ្ធផលក្នុងឆ្នាំ ៤ ជាមួយនឹងសកម្មភាពអាទិភាពចំនួន ១៧ ចំណែកលទ្ធផលចុងក្រោយទី ៥ នៃសសរស្តម្ភទី ៤ ស្តីពីការសង្គ្រោះ និងស្តារឡើងវិញ មានលទ្ធផលក្នុងឆ្នាំ ៣ ជាមួយនឹងសកម្មភាពអាទិភាពចំនួន ២០។

62 សកម្មភាពអាទិភាពនីមួយៗគួរត្រូវបានបង្កើតឡើង និងអនុវត្ត ដើម្បីស្វែងយល់ និងឆ្លើយតបនឹងសមត្ថភាព និងតម្រូវការចម្រុះរបស់ស្ត្រី និងក្មេងស្រីគ្រប់រូប និងដើម្បីលើកកម្ពស់ការចូលរួមពេញលេញ និងបរិយាបន្ន នៅក្នុងសន្តិភាព និងសន្តិសុខនៅគ្រប់ដំណាក់កាលទាំងអស់។

63 CARE, n.d.

64 Lippai and Young, 2017.

65 IFAD, 2017.

66 Adapted from ILO, n.d.

67 Adapted from Myrttinen et al., 2020.
68 Jacevic, 2022.
69 Ibid.
70 Ibid។ នៅពេលបង្កើតចេញពីដំណើរការបែបពិគ្រោះយោបល់ និងគាំទ្រដោយឆន្ទៈនយោបាយ និងការចូលរួមជាអន្តរជាតិ អភិក្រមនេះមិនត្រឹមតែផលិតជាឯកសារកាន់តែល្អប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកសាងនិម្មាបនកម្មរឹងមាំសម្រាប់ផែនការសកម្មភាពជាតិទៀតផង ដែលនឹងសម្រួលដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។.
71 Ibid.
72 GNWP, 2017b.
73 Ibid.
74 Ibid.
75 Ibid.
76 Ibid.
77 Ibid.
78 សក្តានុពលនៃជំនួយមូលនិធិពីកិច្ចសន្យាផ្អែកលើលទ្ធផលចុងក្រោយក្នុងផ្នែកសង្គម និងការអភិវឌ្ឍ (social and development impact bonds) ដែលទាញប្រយោជន៍ពីមូលធនឯកជនដើម្បីផ្តល់មូលនិធិដល់គម្រោងសង្គមដែលកំពុងត្រូវបានអនុវត្តដោយភាគីពាក់ព័ន្ធផ្សេងៗ ដូចជា គម្រោងដែលពាក់ព័ន្ធនឹងរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ ក៏ដូចជាឧបករណ៍ហិរញ្ញវត្ថុអ៊ីស្លាម ដូចជា sukuks។
79 ASEAN Secretariat, 2022.
80 Ibid.
81 Ibid.
82 Ibid.
83 ក្នុងប្រទេសមួយចំនួន មិនមានការពិនិត្យឡើងវិញដូច្នេះទេ។
84 ASEAN Secretariat, 2022.
85 Ibid.
86 UN Women, 2012.
87 Jacevic, 2019.
88 UN Women, 2021.
89 Global Coalition on Youth, Peace, and Security, 2022.
90 Office of the Special Representative of the Secretary-General on Sexual Violence in Conflict, 2017; DFID, 2015.
91 DFID, 2019.
92 UN Women, 2018.
93 DFID (2015), "Addressing Violence against Women and Girls, guideline's part B", Department for International Development, London, U.K.
94 HM Government, 2015.
95 IGWG, 2002.
96 UN Women, 2018.
97 IGWG, 2002.
98 The Dag Hammarskjöld Foundation, 2021.
99 GNWP, 2017a.
100 Global Coalition on Youth, Peace, and Security, 2022.
101 DFID, 2015.
102 Heise, 2011.
103 Peace Women, 2012.

អាស៊ាន ៖ សហគមន៍ដែលនាំមកនូវឱកាសសម្រាប់ប្រជាជនទាំងអស់

ISBN 978-623-5429-33-5 (PDF)